00856223

E1/138.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Oct-2012, 10:27
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី១២៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក រ៉ូជ័រ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វេង ហ៊ត់

លោក ច័ន្ទ តារាស្មី

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោកស្រី ម៉ុច សុវណ្ណារី

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី បេនី យេ *(Ms. Beini YE)*

កញ្ញា លីម៉ា ញៀន *(Ms. Lyma NGUYEN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី ស្វ សុទ្ធារី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ច័ន្ទ តារាស្មី | ខ្មែរ |
| លោក វ៉េង ហ៊ត់ | ខ្មែរ |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ុច សុវណ្ណារី | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោកស្រី ឡាយ បូនី (TCCP-64) | ខ្មែរ |
| លោក គង់ គីម ហៅ កើ (TCW-362) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ឡាយ បូនី** (TCCP-64)

សួរបន្តដោយលោកស្រី ម៉ុច សុវណ្ណារី ផ្តើមពី៖ ........ ទំព័រ ២
សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្តើមពី៖ ........ ទំព័រ ៧
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី៖ ........ ទំព័រ ១៩
សួរដោយលោក ច័ន្ទ តារាស្មី ផ្តើមពី៖ ........ ទំព័រ ៣២
សួរដោយលោក សុន អរុណ ផ្តើមពី៖ ........ ទំព័រ ៣៤
សួរដោយលោក ហ្សាស្តេ ប៉ៅ ផ្តើមពី៖ ........ ទំព័រ ៤១

**ការសួរសំណួរទៅសាក្សី៖ លោក គង់ គីម ហៅ គើ** (TCW-362)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖ ........ ទំព័រ ៦១
សួរដោយលោក វ៉េង ហ៊ាត់ ផ្តើមពី៖ ........ ទំព័រ ៦៥
សួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖ ........ ទំព័រ ៧៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយសវនាការនៅថ្ងៃនេះអង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី -- សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី។ ហើយក៏សូមជម្រាបទាំងមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងលោកស្រី ឡាយ បូនី ផងថា សូមឲ្យនិយាយបន្ថយល្បឿនក្នុងការនិយាយ ឲ្យនិយាយឲ្យបានយឺតៗ ដើម្បីអាចបកប្រែទាន់។ ព្រោះពីម្សិលមិញនេះមានការកត់សម្គាល់ថា មានការនិយាយហ្នឹងលឿនពេក។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

[០៩:០៤:១៩]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លែកលែងជនជាប់ចោទ អៀង សារី អវត្តមានដោយមូលហេតុសុខភាព។ ប៉ុន្តែយោងតាមពាក្យសុំលះបង់សិទ្ធិរបស់ជនជាប់ចោទ ឯកសារលេខ E237 ជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងដំណើរការសវនាការនៃការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ និងសាក្សីបម្រុងដែលនឹងផ្តល់សក្ខីកម្មបន្ទាប់ពីបញ្ចប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺសាក្សីដែលមានរហស្សនាម TCW-362។

លោក អាកទួរ វែកគែន មេធាវីអន្តរជាតិការពារក្តីឲ្យលោក ខៀវ សំផន អវត្តមានដោយមូល-ហេតុមានធុរៈផ្ទាល់ខ្លួន។

ដោយឡែកសាក្សី TCW-362 មានវត្តមាននៅបន្ទប់រង់ចាំរួចហើយ ហើយក្រឡាបញ្ជីនឹងរៀបចំនីតិវិធីសម្បថសម្រាប់សាក្សីរូបនេះ នៅចំពោះមុខលោកតាដំបងដែកមុននឹងសាក្សីចូលមកផ្តល់សក្ខីកម្ម។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប ដូចជាលោក នួន ជា, អៀង សារី និងលោក ខៀវ សំផន

ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។

សាក្សីរូបនេះនឹងមានមេធាវីប្រឹក្សាលោកមេធាវី លឹម ប៊ុនហេង។ សូមអរគុណ។

[០៩:០៥:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី។

សូមអញ្ជើញ!

**លោកស្រី ម៉ុច សុវណ្ណារី៖**

សូមអរគុណលោកប្រធាន។ ជាដំបូងសូមគោរពដល់លោកប្រធាន អង្គជំនុំជម្រះ ក៏ដូចជាអង្គសវនាការទាំងមូល ហើយជម្រាបសួរដល់អ្នកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរបន្តដោយលោកស្រី ម៉ុច សុវណ្ណារី៖**

**ស៖** កាលពីម្សិលមិញយើងបានបញ្ឈប់នៅត្រង់ ការដែលអង្គហេតុ ដែលគេជម្លៀសអ្នកស្រីចេញពីស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល រហូតដល់ខេត្តបាត់ដំបង។ អ៊ីចឹងនៅពេលព្រឹកនេះ ខ្ញុំចង់សួរបន្តដល់អ្នកស្រីទៀតថា តើអ្នកស្រីអាចបញ្ជាក់បានទេ ពីពេលវេលាជាក់លាក់ ដែលអ្នកស្រីត្រូវបានគេបញ្ជូនចេញពីស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល?

**លោកស្រី ឡាយ បូនី៖**

**ឆ៖** សូមគោរពលោកប្រធាន និងអង្គសវនាការ ទាំងមូលចាស។ ខ្ញុំសូមឆ្លើយនូវសំណួរ នៅពេលនោះខ្ញុំហាក់ដូចជាមិនចាំពេលវេលាច្បាស់លាស់ទេ ប៉ុន្តែគ្រាន់ថាប្រហែលជាក្នុងខែឧសភា។ ចាសប្រហែលជាក្នុងខែឧសភា គេបាន -- ព្រោះពេលនោះមានភ្លៀងធ្លាក់ខ្លះហើយ ជារដូវសាបស្ទូង។ ដូច្នេះពេលនោះខ្ញុំបានចេញទៅស្ទូង ចេញទៅសាបសំណាប ហើយគេទៅប្រាប់ខ្ញុំដល់ស្រែ គេតាមខ្ញុំថា ឥឡូវឲ្យខ្ញុំមករៀបចំអីវ៉ាន់ ដើម្បីផ្លាស់ប្ដូរទៅនៅខេត្តបាត់ដំបងវិញចាស។

[០៩:០៧:២៨]

**ស៖** ចាស សូមអរគុណ។ ហើយសំណួរបន្ទាប់ទៅទៀតនេះ ខ្ញុំនឹងយោងទៅលើឯកសារដដែលកាលពីម្សិលមិញ។ ហើយក៏សូមអនុញ្ញាតពីលោកប្រធានដើម្បីបញ្ចាំងឯកសារនេះ នៅលើអេក្រង់

កុំព្យូទ័រ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់អ្នកស្រីដដែល គឺនៅត្រង់ទំព័រដែលមានលេខ ERN ជាភាសាខ្មែរ 00373249, ERN ជាភាសាអង់គ្លេស 00379159 និងERN ជាភាសាបារាំង 00422452 ដល់ 52។ នៅក្នុងសម្រង់នៅកន្លែងនេះ គឺអ្នកស្រីបានអះអាងនៅចំពោះសហចៅក្រមស៊ើបអង្កេតថា "យើងត្រូវបានគេដឹកតាមរទេះគោពីផ្ទះទៅមាត់ទន្លេ ដើម្បីជិះកប៉ាល់ធំមួយទៅខេត្តកំពង់ឆ្នាំង"។ ហើយខ្ញុំសូមបន្តទៀត "ហើយយើងត្រូវបានគេដឹកចេញពីខេត្តកំពង់ឆ្នាំង ដោយឡានយោធាចិន"។ អ៊ីចឹងត្រង់ចំណុចនេះ ខ្ញុំមានសំណួរតូចៗប៉ុន្មានសំណួរ ដើម្បីសួរអ្នកស្រី ធ្វើការបញ្ជាក់ទៅដល់តុលាការ។ សំណួរទី១ ក្នុងផ្នែកនេះ ខ្ញុំចង់សួរអ្នកស្រីថា នៅពេលដែលអ្នកស្រីទៅដល់មាត់ទន្លេ តើអ្នកស្រីបានឃើញមានការកប៉ាល់ដឹកចំនួនមនុស្សហ្នឹងប្រហែលជាប៉ុន្មានកប៉ាល់ដែរ?

[០៩:០៨:៤៩]

**ឆ៖** នៅពេលដែលខ្ញុំធ្វើដំណើរតាមរទេះគោទៅដល់មាត់ទន្លេ ខ្ញុំឃើញកប៉ាល់ពីរបី។ ចាស ប៉ុន្តែកប៉ាល់នុ៎ងធំៗណាស់ ដឹកចំនួនមនុស្សកប៉ាល់មួយរាប់រយនាក់ចាស។ ហើយខ្ញុំ -- យោធាក៏បានជំរុញយើងទាំងអស់គ្នាឲ្យជញ្ជូនអីវ៉ាន់ឡើងដាក់លើកប៉ាល់នោះភ្លាមៗតែម្តងចាស។ ការធ្វើដំណើរមានភាពរហ័សរហួសណាស់ ព្រោះជៀសវាងការយឺតយ៉ាវ ព្រោះវាធ្វើម៉េច លៃយ៉ាងម៉េចទៅដល់កំពង់ឆ្នាំងឲ្យដល់ពេលល្ងាចចាស។

**ស៖** សូមសួរបញ្ជាក់អ្នកស្រីបន្តទៀតថា កប៉ាល់ដែលអ្នកស្រីជិះហ្នឹង តើចំនួនមនុស្សនៅក្នុងហ្នឹង តើប្រហែលជាប៉ុន្មានដែរ? តើចង្អៀតទេកប៉ាល់ដែលអ្នកស្រីជិះហ្នឹង?

**ឆ៖** ចាស កប៉ាល់ដែលខ្ញុំជិះហ្នឹងគឺថា មិនចង្អៀតប៉ុន្មានទេ។ ចាស ល្មមអាចសម្រាកបាននៅពេលយប់ ព្រោះធ្វើដំណើរទៅត្រូវសម្រាកៗ ដល់អ៊ីចឹងអាចសម្រាកអីប្រាសដេក ប្រាសអីបានធម្មតាចាស។

**ស៖** អ៊ីចឹងអ្នកស្រីអាចបញ្ជាក់បានទេថា ក្នុងកប៉ាល់ដែលអ្នកស្រីជិះហ្នឹងមានចំនួនមនុស្សប្រហែលជាប៉ុន្មាននាក់ដែរ? ប្រហែល?

**ឆ៖** ចាស ប្រហាក់ប្រហែលថាក្រោម១០០ចុះ ទាំងក្មេង ទាំងចាស់ ទាំងតូច ទាំងធំ ចាស។

**ស៖** ខ្ញុំមានសំណួរបន្តទៀតចង់សួរអ្នកស្រី។ តើមនុស្សដែលត្រូវបានគេជម្លៀសចេញ ដែលជិះកប៉ាល់ជាមួយនឹងអ្នកស្រីហ្នឹងសុទ្ធតែជាមនុស្សដែលយកចេញពីស្រុកខ្សាច់កណ្តាល ឬក៏យ៉ាងណាដែរ?

**ឆ៖** ចាស មនុស្សទាំងអស់នោះ សុទ្ធតែយកចេញពីស្រុកខ្សាច់កណ្តាល គ្រាន់តែឃុំខុសគ្នា។

ពីឃុំផ្សេងៗគ្នាចាស។

[០៩:១១:១១]

**ស៖** អម្បាញ់មិញអ្នកស្រីបានមានប្រសាសន៍ថា នៅពេលដែលអ្នកស្រីឡើងទៅដល់កប៉ាល់ហ្នឹង គឺមានយោធាខ្មែរក្រហមកាន់អាវុធ ហើយគេបានរុញអ្នកស្រីឲ្យឡើងទៅលើកប៉ាល់ហ្នឹង។ អ៊ីចឹងខ្ញុំចង់សួរថា តើអ្នកស្រីដឹងទេថា យោធាទាំងអស់ហ្នឹងមកពីណា ហើយអ្នកណាជាអ្នករៀបចំយោធាទាំងអស់ហ្នឹង?

**ឆ៖** ខ្ញុំមិនបានដឹងថាយោធាទាំងអស់នេះ មកពីណាទេ តែគ្រាន់តែដឹងថាគេមកពីភាគ អ្នកភាគ។ គឺដឹងតែថ្នាក់លើមកពីភាគអ៊ីចឹងតែម្ដងចាស។

**ស៖** ខ្ញុំសូមនាំអ្នកស្រីទៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់អ្នកស្រីដដែល នៅក្នុងទំព័រដែលមានលេខ ERN ជាភាសាខ្មែរ 00373250, ជាភាសាអង់គ្លេស 00379160, ជាភាសាបារាំង 00422452។ នៅក្នុងផ្នែកនេះ អ្នកស្រីបានមានប្រសាសន៍ថា "យើងត្រូវបានគេបញ្ជូនទៅវត្តកោះជុំ ខេត្តពោធិ៍សាត់ ដែលមានចម្ងាយ១៣គីឡូម៉ែត្រពីទីរួមខេត្តពោធិ៍សាត់ ហើយមានរទេះគោត្រៀមដឹក -- ចាំដឹកជញ្ជូនប្រជាជនទៅតាមភូមិដទៃទៀត"។ អ៊ីចឹងខ្ញុំចង់សួរអ្នកស្រីនៅត្រង់ចំណុចនេះថា តើអ្នកស្រីដឹងទេថា អ្នកណាគេជាអ្នកត្រៀមរទេះគោទាំងអស់នោះ?

[០៩:១២:៥១]

**ឆ៖** នៅពេលនោះ នាងខ្ញុំមិនបានដឹងថាអ្នកណាជាអ្នករៀបចំចាំទទួលទេ ប៉ុន្តែខ្ញុំគ្រាន់ដើរស៊ើបសួរទៅ រទេះអស់ទាំងនោះមកពីតាមសហករណ៍។ សហករណ៍នេះ សហករណ៍នោះ នៅតំបន់២៣ តំបន់២២ គឺថាគេចាំមកទទួលយក ស៊ើបសួរថា ឥឡូវបើយើង គេសួរគេថាមកពីខាងណា? គេថា មកពីកណ្ដៀង បើយើងចង់ទៅនៅកណ្ដៀងទៅៗ តែចំពោះខ្ញុំ ខ្ញុំអត់ស្គាល់ភូមិសាស្ត្រសោះ ឮតែគេថា អ៊ីចឹងខ្ញុំអត់មានគំនិតថាទៅណាទៀតទេចាស។

**ស៖** នៅពេលដែលខ្មែរ -- កម្មាភិបាលខ្មែរក្រហមនៅស្រុកខ្សាច់កណ្ដាលប្រាប់អ្នកស្រីឲ្យចេញមក គេថាគេនឹងបញ្ជូនអ្នកស្រីទៅខេត្តបាត់ដំបង សម្បូរសប្បាយ សម្បូរស្បៀង។ អ៊ីចឹង ខ្ញុំចង់សួរថា តើមានពេលណាមួយនៅក្នុងរបបខ្មែរក្រហមហ្នឹង ពេលបន្ទាប់ពីអ្នកស្រីទៅដល់ខេត្តពោធិ៍សាត់ហ្នឹងហើយ តើខ្មែរក្រហមហ្នឹងមានបានបញ្ជូនអ្នកស្រីបន្តទៅដល់ខេត្តបាត់ដំបង ដូចដែលគេបានសន្យាដែរឬទេ?

[០៩:១៤:០៩]

**ឆ៖** គេមិនបានធ្វើតាមការសន្យាអះអាងរបស់គេទេចាស។ ហើយខ្ញុំក៏គិតឃើញថា គេនិយាយនេះ និយាយធ្វើម៉េចឲ្យតែយើងចេញពីកន្លែងមួយទៅកន្លែងឲ្យបានរហ័សរហួនរួសរាន់តែម្ដង។ គេអត់គិតថា គេថាទៅឯណេះហើយ គេដាក់ឯណោះអី ខុសគោលការណ៍អី គេអត់មានបានគិតអ៊ីចឹងទេចាស។

**ស៖** អ៊ីចឹង ខ្ញុំចង់សួរបន្តទៀតថា នៅក្នុងសហករណ៍នៅក្នុងខេត្តពោធិ៍សាត់ដែលអ្នកស្រីបានទៅដល់ហ្នឹង តើនៅទីនោះ សម្បូរស្បៀងដូចអ្វីដែលគេបានប្រាប់ទេ?

**ឆ៖** បើនិយាយឲ្យចំទៅ គឺថារបបខ្មែរក្រហមនេះ តាំងពីខ្ញុំចេញពីភ្នំពេញទៅ គឺថាឲ្យតែខែស្ទូង គឺជាខែអត់រហូតដល់បែកមកវិញ គឺថាឲ្យតែខែស្ទូង គឺខែអត់បាយ។ ពេលដែលខ្ញុំចេញទៅ ជារដូវភ្លៀង ហើយខែស្ទូងទៀត ពេលនោះគឺអត់បាយតែម្ដង។ ប៉ុន្តែដោយសារខ្ញុំមានការដោះដូរអង្ករខ្លះជាប់នឹងខ្លួនទៅ។ ទើបចេះតែបណ្ដោះហូបរាល់ថ្ងៃបន្តិចៗអ៊ីចឹងទៅ ចាស។

**ស៖** អ៊ីចឹងអ្នកស្រីមានដឹងពីស្ថានភាពរបស់ប្រជាជនដែលត្រូវបានគេជម្លៀសផ្សេងទៀត ថាតើជីវភាពការរស់នៅរបស់ពួកគេដែលទៅដល់ហ្នឹង ថាតើគេមានអាហារបរិភោគ របបអាហារបរិភោគគ្រប់គ្រាន់ទេ?

**ឆ៖** នៅពេលនោះ ពេលដែលខ្ញុំទៅនៅត្រឹមសហករណ៍កោះជុំហ្នឹង គឺថាខ្ញុំបានដឹងតែភូមិជិតខ្ញុំមានភូមិថ្មីមួយ គឺថាគេជម្លៀសប្រជាជនថ្មីដូចនាងខ្ញុំអ៊ីចឹងទៅនៅភូមិនោះ។ ហើយភូមិនោះគឺត្រូវកាត់ឫស្សីព្រិច។ កាប់ដើមឫស្សីព្រិច វាតធ្វើភូមិថ្មី។ ដល់អ៊ីចឹងទៅ ស្របនឹងពេលអត់មានអង្ករហូប ស្របនឹងពេលធ្វើការធ្ងន់ផង អ្នកដែលជម្លៀសទៅនៅភូមិថ្មីជិតភូមិខ្ញុំនៅហ្នឹង គឺត្រូវស្លាប់រង្គាល។ មួយគ្រួសារស្លាប់នៅសល់តែម្នាក់ សល់ពីរនាក់។ ខ្លះស្លាប់អស់រលីងក៏មានដែរ ចាស។

[០៩:១៦:៥៩]

**ស៖** ដើម្បីបញ្ចប់ត្រង់ចំណុចនេះ ខ្ញុំចង់សួរអ្នកស្រីថា នៅពេលដែលអ្នកស្រី ក៏ដូចជាប្រជាជនដែលត្រូវបានគេជម្លៀសទៅដល់សហករណ៍នៅទីនោះភ្លាមហ្នឹង ថាតើកម្មាភិបាលខ្មែរក្រហមនៅទីនោះគេមានការយកចិត្តទុកដាក់យ៉ាងម៉េចខ្លះ ចំពោះក្រុមរបស់អ្នកស្រីដែលទៅដល់ហ្នឹង? តើគេយកចិត្តទុកដាក់ទេ?

**ឆ៖** នៅពេលនោះ គឺថាដូចជាគ្មានយកចិត្តទុកដាក់អីទេ គ្រាន់តែថាចងក្រងជាក្រុម ជាកងឲ្យយើងនៅទៅ។ ហូបបាយនៅការដ្ឋានរួម មួយកំប៉ុងបួននាក់។ ហើយថ្ងៃឡើង ព្រឹកឡើងរុញទៅ ចាត់តាំងទៅ អ្នកនេះទៅធ្វើការខាងនេះ អ្នកនេះទៅធ្វើការខាងនោះជាធម្មតា។ ប៉ុន្តែដល់តែពេលឈឺ គឺថ្នាំពេទ្យមិនមានទាល់តែសោះ។ ចាស ទាំងថ្នាំពេទ្យមិនមាន ទាំងហូបចុក របបជីវភាពប្រចាំថ្ងៃហ្នឹងក៏ខ្វះខាត។

**ស៖** នេះជាសំណួរចុងក្រោយដែលខ្ញុំនឹងសួរដល់អ្នកស្រី។ តើអ្នកស្រីបានសង្កេតឃើញទេថា គោលនយោបាយរបស់ខ្មែរក្រហម ដែលគេធ្វើការជម្លៀសអ្នកស្រីពីដំបូងចេញពីទីក្រុងភ្នំពេញទៅដល់ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បន្ទាប់មកទៀតពីស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល រហូតដល់ស្រុកបាកាន ខេត្តពោធិ៍សាត់។ តើអ្នកស្រីមានបានសង្កេតឃើញទេថា គោលនយោបាយនេះអាចដោះស្រាយបានដែរឬទេនូវបញ្ហាកង្វះស្បៀងអាហារនៅក្នុង -- សម្រាប់ប្រជាជននៅក្នុងប្រទេសកម្ពុជានៅពេលនោះ?

[០៩:១៨:៤២]

**ឆ៖** បើជាគំនិតរបស់ខ្ញុំ ខ្ញុំគិតថា បើសិនជាគេមានគំនិតផ្គត់ផ្គង់ និងឧបត្ថម្ភយើង វាអត់ខ្វះខាតទេចាស ព្រោះនៅពេលនោះ នៅភ្នំពេញអីមានអង្ករ មានអី ជំនួយអីនៅសល់ពេញពាសហ្នឹង។ ហើយយើងទើបតែចុះទៅភ្លាមអ៊ីចឹង ទោះយើងនៅភ្នំពេញក៏ហូប ចុះទៅឯណោះក៏ហូប។ ប៉ុន្តែដោយសារគេគិតថា យកយើងអ្នកភ្នំពេញហ្នឹង យកអ្នកថ្មី មិនមែនត្រឹមតែអ្នកភ្នំពេញទេ អ្នកទីកន្លែងគ្រប់ឲ្យតែជាអ្នកថ្មី យកទៅលត់ដំ ដើម្បីឲ្យស៊ាំនឹងការងារ ថាស្លាប់ប៉ុន្មានស្លាប់ទៅ រស់ប៉ុន្មានទុកដើមហ្នឹងធ្វើតទៅទៀតចាស។

**លោកស្រី ម៉ុច សុវណ្ណារី៖**

ចាស ខ្ញុំសូមអរគុណអ្នកស្រីដែលបានយកចិត្តទុកដាក់នៅក្នុងការឆ្លើយសំណួររបស់ខ្ញុំ ហើយក៏សូមអរគុណដល់លោកប្រធាន និងអង្គជំនុំជម្រះដែលផ្តល់ឱកាសដល់នាងខ្ញុំនៅក្នុងការសួរសំណួរ។ ហើយជាបន្តទៅទៀតនេះ នាងខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីនឹងផ្ទេរវេទិកានេះជូនទៅដល់សហភាតាអន្តរជាតិរបស់នាងខ្ញុំ អ្នកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត។ សូមអរគុណ។

[០៩:១៩:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ភាគីទាំងអស់ជាទីគោរព! ជម្រាបសួរអ្នកស្រី។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ខ្ញុំសូមសួរសំណួរមួយចំនួន។ ខ្ញុំសូមត្រឡប់មកនិយាយ ជាដំបូងនិយាយអំពីការជម្លៀសវគ្គ ដំណាក់កាលដំបូងដែលអ្នកស្រីត្រូវបានគេជម្លៀសចេញពីភ្នំពេញដែរនោះ។ អ្នកស្រីបានពន្យល់ពីខ្សែដំណើររបស់អ្នកស្រី តើៗគិតទាំងពេលសម្រាកជាច្រើនដំណាក់កាលនោះ តើការជម្លៀសចេញហ្នឹងស៊ីពេលអស់ប៉ុន្មានដែរអ្នកស្រី?

**លោកស្រី ឡាយ បូនី៖**

**ឆ៖** ពេលនោះ ខ្ញុំដូចជាចាំមិនច្បាស់ទេចាស គ្រាន់តែថាខ្ញុំចេញនៅថ្ងៃទី១៧ មេសា ធ្វើដំណើរឆ្លងកាត់ចុះឡើង ខ្ញុំទៅដល់ស្រុកខ្សាច់កណ្ដាលនៅៗចុង -- នៅខែ៦ ខែ៧ ប្រហែលជាមួយខែចុះ ខ្ញុំទៅដល់ស្រុកខ្សាច់កណ្ដាលចាស។ ដេកចុះឡើងអីហ្នឹងបានចេញធ្វើការហ្នឹងនៅខែ ឆ្លងផុតខែចូលឆ្នាំហើយចូលទៅដល់ខែ៥ ហើយ ត្រឹមតែទៅស្នាក់នៅហ្នឹង។

[០៩:២១:៣៦]

**ស៖** សូមអរគុណ។ អ្នកស្រីបានរៀបរាប់អំពីអ្វីដែលកើតឡើងនៅតាមផ្លូវ អ្វីដែលកើតឡើងចំពោះក្រុមគ្រួសាររបស់អ្នកស្រី ហើយនៅក្នុងចំណោមអ្នកដែលដើរនោះ តើចំពោះអ្នកដែលមិនអាចដើរបាននោះ តើមានរឿងអីកើតឡើងចំពោះពួកគាត់ដែរ?

**ឆ៖** ចំពោះអ្នកដែលមិនអាចដើរបាន តួយ៉ាងដូចជាអ្នកចេញពីមន្ទីរពេទ្យ គឺគេបានសម្រាកនៅលើគ្រែពេទ្យ គ្រែណាដែលមានកង់ៗ គឺគេរុញយកចេញមកទាំងគ្រែដោយដៃមានដាក់សេរ៉ូម ហើយបើអ្នកខ្លះចាស់ជរាសែងពីផ្ទះ គឺសែងដោយអង្រឹង ធ្វើស្នែងអង្រឹងហ្នឹងគេសែងតាមផ្លូវកូនចៅគេសែង។ ហើយបើសិនជាអ្នកខ្លះទៀតអត់មានស្នែងទេ ប្រើអៀវក ចាស ពាក់លើខ្នងខាងក្រោយ។

**ស៖** ហើយតើមានអ្នកដែលនៅតាមចិញ្ចើមថ្នល់ទេដែលគាត់ទៅមុខមិនរួចនោះ?

[០៩:២២:៥៥]

**ឆ៖** ចាស នៅពេលនោះមានដែរ ខ្ញុំឃើញផ្ទាល់នឹងភ្នែកចាស។ គឺស្ត្រីឆ្លងទន្លេ កំពុងតែដើរៗស្រែកថាឈឺពោះៗ អ៊ីចឹងទៅយើយូយអ៊ីចឹង ព្រោះពេលនោះខ្ញុំធ្វើដំណើរយឺតបំផុត គឺថាកន្លះម៉ោងអីនៅនឹងថ្កល់អត់មានទៅមុខរួចទេ ដល់អ៊ីចឹងខ្ញុំអាចមើលឃើញហេតុការណ៍គេស្រែកថា អ៊ូ! អ្នកនោះឈឺពោះហើយជួយផងធ្វើម៉េចហ៎! ឃើញរត់ផ្វែងឆ្ងាត់ដើររកយាយម៉បខ្មែរ ប៉ុន្តែមានស្ត្រីហ្នឹងគាត់បែបធ្លាប់ធ្វើពេទ្យពីសង្គមនៅតាម -- នៅទីក្រុងភ្នំពេញគាត់ក៏ទៅជួយបង្កើត។ ចាស បង្កើតហើយក៏បានឃើញដែលចងភួយរុំធ្វើដូចបន្ទប់អ៊ីចឹង ឈរតោងទាំងអស់គ្នាទៅបង្កើត។ ដល់ពេលបង្កើតកូនហ្នឹងហើយទៅក៏បានរៀបរយឲ្យគាត់សម្រាកអីស្រួលបួល មិនទាន់ធ្វើដំណើរទៅទៀតបានទេ។ ហ្នឹងក៏ឃើញសម្រាកនៅចិញ្ចើមថ្នល់សិនដែរចាស។

**ស៖** ឥឡូវនេះខ្ញុំសូមមកនិយាយអំពីកន្លែងមួយដែលអ្នកស្រីបានស្នាក់នៅទីនោះពីរបីខែ គឺឈ្មោះអញ្ចែងលើ អ្នកស្រីបានរៀបរាប់ថានៅទីនោះគឺថា អ្នកស្រីបានចូលរួមនៅកិច្ចប្រជុំមួយចំនួនហើយ តើក្នុងពេលប្រជុំនោះគេមានបានផ្តល់ព័ត៌មានទាក់ទងនឹងស្ថានភាពប្រទេស ទាក់ទងនឹងនយោបាយអន្តរជាតិអីដែរឬអត់? នយោបាយជាតិអីដែរឬទេ?

[០៩:២៤:២៩]

**ឆ៖** ចាស នៅពេលដែលខ្ញុំរស់នៅភូមិអញ្ចែងលើ ឃុំពុកឫស្សីហ្នឹង ខ្ញុំបានចូលរួមប្រជុំជីវភាពចូលធ្វើការងារដូចជាលីដើមចេក។ ពេលនោះ ខ្ញុំសូមបញ្ជាក់បន្តិចចាសកន្លែងហ្នឹងគឺថា ខ្ញុំឆ្លងទន្លេហើយបាន ២០ថ្ងៃចេញពីភ្នំពេញទៅ ប៉ុន្មានថ្ងៃក្រោយខ្ញុំក៏បានទៅដល់ភូមិអញ្ចែងលើ ដល់ពេលនោះទៅចូលរួមធ្វើការងារនឹងគេ ព្រោះខ្ញុំខ្លាចស្លាប់ណាស់ ខ្ញុំខំទៅចុះឈ្មោះសុំគេធ្វើការងារអ៊ីចឹងទៅ។ គេក៏ប្រើខ្ញុំឲ្យលីគល់ចេកធំៗ តែខ្ញុំអត់ប៉ានប្រាប់គេថា ខ្ញុំសរសៃខ្ចី ខ្ញុំមាន -- ទើបតែឆ្លងទន្លេអីហើយ ខ្ញុំអត់ប៉ានទេចាស។ ដល់ពេលយប់ឡើង ព្រោះពេលយប់ឡើង គឺត្រូវប្រជុំជីវភាព។ ប្រជុំជីវភាពហ្នឹង គេកសាងគ្នាអ្នកណាធ្វើការងារចេះ អ្នកណាធ្វើការងារចុះ។ ចំណែករឿងនយោបាយ រឿងប្រទេសជាតិ គឺអត់បានប្រាប់យើងថា យ៉ាងម៉េចៗគឺអត់ទេ។ គិតតែពីឲ្យយើងបង្កបង្កើនផល ធ្វើម៉េចឲ្យបានមួយហិកតាបីតោនធ្វើម៉េចឲ្យលើកទំនប់ ជីប្រឡាយហ្នឹង ឲ្យល្អ ទប់ទឹក ទប់អី ចាស មានតែផែនការប៉ុណ្ណឹងទេ ចាស។

**ស៖** សូមអរគុណ។ តើគេធ្លាប់ឲ្យអ្នកស្រីស្តាប់សុន្ទរកថាអ្នកនយោបាយដែរឬទេ?

[០៩:២៦:០៨]

**ឆ៖** ចាស ពេលនោះ ខ្ញុំអត់ដែលបានស្តាប់ទេ ចាស។

**ស៖** សូមអរគុណ។ អ្នកស្រីបានលើកឡើងជាច្រើនដងម្សិលមិញ ហើយក៏នៅចំពោះសហចៅក្រមស៊ើបអង្កេតដែរ គឺថាពាក្យដែលគេហៅប្រើ “ប្រជាជនថ្មី ឬក៏ប្រជាជន១៧ មេសា ហើយនិងប្រជាជនមូលដ្ឋាន”។ តើអ្នកស្រីអាចជម្រាបជូនតុលាការបានទេ ថាប្រជាជនថ្មី ហើយនិងប្រជាជនមូលដ្ឋាននេះ ខុសគ្នាយ៉ាងម៉េចដែរ? ការប្រព្រឹត្តទៅលើប្រជាជនចាស និងប្រជាជនថ្មីនេះ ខុសគ្នាយ៉ាងម៉េចដែរ? ហើយនិងការទាក់ទងនឹងរបបការងារជាដើមនោះ តើមានលក្ខណៈខុសគ្នាយ៉ាងណាដែរ?

**ឆ៖** រវាងប្រជាជនថ្មី និងប្រជាជនចាស់ហ្នឹង គឺថាបើធ្វើការប្រៀបធៀប ចាស ប្រជាជនចាស់គេរស់នៅក្នុងរបបខ្មែរក្រហមយូរហើយ។ គេបង្កបង្កើនផល គេមានស្រូវ មានអង្ករ ជាកម្មសិទ្ធិផ្ទាល់របស់គេ។ គេមានសម្ភារៈសព្វបែបយ៉ាង ដូចជាកាំបិត ពូថៅ ផ្គាក់ ចាស សម្ភារៈធ្វើស្រែចម្ការ គឺគេមានផ្ទាល់ខ្លួនគេអស់។ ចំណែកយើងជាជន ១៧មេសា នេះ ដែលទើបតែជម្លៀសទៅ ហើយថែមអង្គការហ្នឹងប្រាប់ទៀត ថាទៅតែ៣ថ្ងៃទេ ទៅយ៉ាងយូរ១អាទិត្យទេ ខ្លាចគេទម្លាក់គ្រាប់បែក។ អ៊ីចឹងធ្វើម៉េចឲ្យយើងចេញប្រញាប់ប្រញាប់ទៅ។ ម្ល៉ោះហើយ យើងអត់មានដោយអីវ៉ែអីវ៉ាន់អី ទៅដូចជាកាំបិតតូច កាំបិតធំអី យើងអត់មានទាល់តែសោះ។

[០៩:២៧:៤៦]

ហើយយើងជាពិសេស យើងជាអ្នកថ្មី យើងជាកូនចៅអ្នកមានហូបចុកគ្រប់គ្រាន់ ហើយយើងអ្នកធ្វើការ កូនចៅអ្នកធ្វើការទៀត។ ម្ល៉ោះហើយបទពិសោធន៍ក្នុងការធ្វើស្រែចម្ការ គឺយើងមិនមានទាល់តែសោះ។ ដល់ពេលទៅរស់នៅ គេប្រើយើងឲ្យទៅកាប់ៗ ព្រៃ កាប់ដើមឈើ ដើម្បីពង្វាតធ្វើស្រែធ្វើអី។ ម្ល៉ោះហើយ យើងអត់មានសម្ភារៈទេ យើងត្រូវដូរ។ ត្រូវធ្វើការដោះដូរយករបស់របរដែលយើងមានបន្តិចបន្តួចទៅដោះដូរ ពីអ្នកចាស់ហ្នឹង ដែលគេមានសព្វបែបយ៉ាង តាំងពីស្រូវអង្ករឡើង យើងត្រូវដោះដូរគេទាំងអស់។ ដល់ទៅយើងកាប់ទៅ ធម្មតាយើងអ្នកស្រណុក ដោយឲ្យយើងទៅនឿយមួយភ្លែតហ្នឹងភ្លាម វាមិនដូចគេអ្នកចាស់ ដែលគេនៅរាប់ឆ្នាំខែ រាប់ឆ្នាំហើយ។ ដល់អ៊ីចឹងទៅ គេចោទយើងថា យើងហ្នឹងធ្វើការចុងដៃចុងជើង។ យើងហ្នឹងប្រើសតិអារម្មណ៍ច្រើន យើងហ្នឹងមិនព្រមលត់ដំតាមគេ ប៉ុន្តែរយៈពេលខ្លីបំផុត ដែលយើងទៅចុះរួមការងារជាមួយគេ។

[០៩:២៨:៤៩]

ហើយអ្នកចាស់ គេធ្វើដូចយើងដែរ តែគេមួយភ្លែតហើយ ព្រោះបទពិសោធន៍របស់គេមានគ្រប់គ្រាន់អស់ហើយ។ ដល់អ៊ីចឹងទៅ វាគម្លាតអ្នករវាងអ្នកថ្មី និងអ្នកចាស់។ គេបែងចែកច្បាស់អ៊ីចឹងតែម្តង

អ្នកថ្មីចុះទៅប្រាវ -- អ្នកចាស់ចុះទៅធ្វើប្រាវៗ ដល់អ្នកថ្មីហ្នឹង គេអង្គុយសម្រាកអស់ចិត្ត តែឯងធ្វើមិនទាន់រួចផង ចាស។ ដល់អ៊ីចឹង វាមានការពិបាកណាស់ ទាល់តែយើងប្រឹងប្រែងមែនទែន។

**ស៖** តើប្រជាជនថ្មីនោះ ត្រូវបានគោរពដោយខ្មែរក្រហម ដូចជាប្រជាជនមូលដ្ឋានដែរឬទេ? ឬក៏មានភាពខុសគ្នា?

**ឆ៖** អត់បានគោរពដូចប្រជាជនចាស់ទេ។ ចាស ខ្មែរក្រហមគាត់ឲ្យតម្លៃ និងលើកកម្ពស់ប្រជាជនចាស់របស់គាត់អ៊ីចឹងតែម្តង ចាស។ ព្រោះគេបានកសាងខ្លួនហើយ យើងនៅទេ អ្នកថ្មីទើបនឹងទៅលត់ដំ។

[០៩:៣០:០៥]

**ស៖** សូមអរគុណ។ កាលពីម្សិលមិញអ្នកស្រីបាននិយាយថា កូនស្រីរបស់អ្នកស្រីឈ្មោះបូនីដា ឈឺនៅតាមផ្លូវនៅពេលដែលគេជម្លៀសប្រជាជនចេញ ពីព្រោះនាងញុំាពោតជំនួសឲ្យអង្ករនោះ។ តើមានរឿងអីកើតឡើងចំពោះនាងដែរ?

**ឆ៖** ចាស នៅពេលដែលនៅដល់ខ្សាច់កណ្តាល កូនស្រីខ្ញុំមានជំងឺរ៉ាំរ៉ៃតាំងពីទើបតែចេញពីភ្នំពេញមក គឺរាកមួល មួលឈាមចាស។ ទៅដល់ពេលនោះនាងអត់ៗបានជាទេ នាងនៅតែឈឺរឹតតែធ្ងន់ទៅ ព្រោះខ្ញុំអត់មានថ្នាំសង្កូវអីជួយព្យាបាលនាងទេ។ ពេលនោះគេប្រាប់ដែរ ឲ្យខ្ញុំទៅបេះទៅបោចស្លឹកនេះស្លឹកនោះ ប៉ុន្តែវាអត់ដូចថ្នាំពេទ្យ ញុំាទៅនាងអត់ជាទេ។ ក្រោយមកនៅក្នុងរវាងគ្រួសារខ្ញុំបួននាក់ហ្នឹង ប្តី, ខ្ញុំ និងកូនពីរនាក់ឈឺទាំងអស់គ្នា។ គ្រុនក្តៅញាក់ ផ្លាស់ប្តូរគ្នាញាក់តែម្តង។ ដល់រួចទៅម្តាយធំខ្ញុំ បងរបស់ម្តាយខ្ញុំនៅឃុំវិហារសួគ៌ នៅស្រុកខ្សាច់កណ្តាលហ្នឹងដែរ នៅឃុំវិហារសួគ៌ គាត់ធ្វើដំណើរមកលេង គាត់ធ្វើដំណើរមកសួរសុខទុក្ខអីអ៊ីចឹងទៅ។ ដល់គាត់ឃើញឈឺអ៊ីចឹង គាត់ថាអ៊ីចឹងគាត់ជួយយកកូនស្រីបងខ្ញុំហ្នឹងទៅនៅជាមួយគាត់ ទៅជួយមើលព្យាបាលក្រែងលោជា ព្រោះកាលណាក្នុងផ្ទះវាឈឺទាំងអស់គ្នាអ៊ីចឹង វាដាក់ទាំងអស់គ្នា។ អ៊ីចឹងបំបែកកូនស្រីខ្ញុំទៅ ហើយក៏យកទៅ។

[០៩:៣១:៤១]

តែក្រោយមកកូនខ្ញុំនឹងក៏ស្លាប់ ខ្ញុំអត់បានដឹងទេ ដល់តែពេលនឹកឃើញថា ប្រហែលជាកូនជាហើយ សុំច្បាប់គេទៅយកកូន។ ដល់ទៅដល់ឃុំវិហារសួគ៌ គេប្រាប់ថា “អ្អូ! កូនស្លាប់បាត់ហើយ តាំងពីយកមកបានប៉ុន្មានថ្ងៃចាស”។

**ស៖** ហើយនៅពេលនោះនោះ កូនអ្នកស្រីអាយុប៉ុន្មានដែរ?

**ធ៖** នៅពេលនោះកូនស្រីបងខ្ញុំអាយុប្រាំឆ្នាំចាស នាងកើតនៅចុងឆ្នាំ៧១។

**ស៖** នៅកន្លែងទី១ ដែលអ្នកស្រីស្នាក់នៅប្រហែលជា ២, ៣ខែ តើអ្នកស្រីបានឃើញ ឬក៏អ្នកស្រីបានឮអំពីការចាប់ខ្លួនមនុស្សដែរឬទេ? និងការបាត់ខ្លួនផងដែរ?

**ធ៖** ចាស ពិតជាបានឮចាស។ មុននឹងខ្ញុំមកនៅផ្ទះឯកជន ដែលអង្គការចែកដីម៉្តុំៗហ្នឹង គឺថាខ្ញុំបាននៅផ្ទះមិត្ត យន នៅផ្ទះរួមជាមួយនឹងគេ ក្នុងមួយផ្ទះហ្នឹងមានបួនប្រាំគ្រួសារ។ ហើយគេបានប្រាប់ខ្ញុំថា ឲ្យប្រយ័ត្ន លាក់អត្តសញ្ញាណឲ្យជិតទាំងអស់ ប្រាប់បងប្រាប់ប្អូនប្រាប់កូនចៅហ្នឹង កុំឲ្យនិយាយថាធ្វើការឲ្យសោះ។ ប្រាប់ថារត់ឡាំប្រើតា ឬរកស៊ីលក់នំបុ័ង លក់អីអ៊ីចឹងទៅ អាហ្នឹងអត់អីទេ។ ហើយតែប្រាប់ថាធ្វើការ ដឹងថាបាត់ខ្លួនហើយ។ ជាក់ស្តែងខ្ញុំលាក់ជិតរហូត។

[០៩:៣៣:៣៥]

ដល់ជាក់ស្តែងគ្រួសារមួយទៀត ជាបងប្អូនរបស់ យន ម្ចាស់ផ្ទះហ្នឹងតែម្តង ហើយគេចេញចូលស្រុកពីមុនៗជម្លៀសចេញពី មុនចូលឆ្នាំអីហ្នឹង គេចេញចូលដើរលេងនៅហ្នឹង គេស្គាល់ អ្នកស្រុកអ្នកភូមិហ្នឹងស្គាល់គាត់ទាំងអស់ ថាគាត់ជាទាហាន លន់ នល់។ នៅពេលនោះ មានយប់មួយនោះ ខ្ញុំឮស្រែកហៅ គេស្រែកហៅ ស្រែកហៅអ៊ីចឹងទៅ ម្ចាស់ផ្ទះឆ្លើយ ដល់រួចទៅក៏បាត់ស្ងាត់ទៀតទៅ។ អត់ទេដល់ព្រឹកឡើង ព្រឹកឡើងក៏ខ្សឹបខ្សៀវគ្នាថា “អ្ហ៎ យកទៅបាត់ហើយ! យកឈ្មោះអីទេ ខ្ញុំអត់ចាំឈ្មោះម្នាក់ហ្នឹង យកម្នាក់ហ្នឹងទៅបាត់ហើយ។ កុំមាត់! ហើយទៅធ្វើការអីធម្មតាទៅ”។ ហើយគ្រាន់តែខ្សឹបប្រាប់ទៀតថា “យើងសុទ្ធតែមានមនុស្សប្រុស មានបងប្រុសខ្ញុំ មានប្តីខ្ញុំជាប្រុស អ៊ីចឹងឲ្យត្រៀមឲ្យហើយរៀបខោអាវមួយចង្កេះពីរចង្កេះ ហើយនិងមុងមួយសម្រាប់ចងដេក ព្រោះតែគេមកហៅទាញតែបង្វេចហ្នឹងទៅទៅ បើអាល័យចាំរៀប រៀបអីវ៉ាន់អត់ទាន់ទេ”។ តែរហូតមកដល់ពេលនោះ ខ្ញុំក៏អត់ដែល -- ក្នុងគ្រួសារខ្ញុំក៏អត់មានបានបែកបាក់អ្នកណាទៀតដែរចាស។

**ស៖** ពេលដែលមានមនុស្សបាត់ខ្លួននោះ តើគេមានពន្យល់ពីមូលហេតុពីការបាត់ខ្លួនហ្នឹងទេ?

[០៩:៣៥:០៧]

**ធ៖** គេអត់និយាយតែម្តង គេគ្រាន់តែប្រាប់ថា យកទៅធ្វើការងារនៅកន្លែងផ្សេង។ គ្រាន់តែប្រាប់តែប៉ុណ្ណឹង ហើយតាំងពីហ្នឹងមក យើងក៏អត់ហ៊ានសួរ យើងក៏អត់ហ៊ានឆ្ងល់ អត់ហ៊ានមាត់អីទាំងអស់ គឺស្ងៀម។

**ស៖** សូមអរគុណ។ ហើយបន្ទាប់មកទៀត គេជម្លៀសអ្នកស្រីបន្តទៀត។ អ្នកស្រីទៅបាត់ដំបង ទៅពោធិ៍សាត់ តើប្រជាជន១៧ មេសា នៅពេលដែលគេជម្លៀសជាលើកទី២នេះ តើស្ថានភាពសុខភាពរបស់គាត់យ៉ាងម៉េចដែរ?

**ឆ៖** ចាស នៅពេលនុ៎ង សូម្បីតែខ្ញុំហ្នឹងក៏ឈឺដែរ ព្រោះនៅថ្ងៃដែលជម្លៀសទៅហ្នឹង ខ្ញុំមានដាំដំឡូងនៅមុខផ្ទះ ដល់អ៊ីចឹងទៅ រៀបជម្លៀសទៅសូម្បីតែឫស្សមួយសរសៃ ប៉ុនកូនដៃក៏ជីកយកទៅដែរ។ ព្រោះដាំវាអត់ទាន់ធំល្អ ម្ល៉ោះហើយគាស់យកទៅទាំងអស់ ស្ងោរមួយឆ្នាំងដាក់ទៅ ដល់ពេលយើងញ៉ាំទៅ តាមផ្លូវអត់មានបាយទឹកអី មានតែដំឡូងហ្នឹង ទៅជារាក ទៅជាហើមពោះ។ ហើយមិនថាគ្រួសារខ្ញុំទេ គ្រួសារគេក៏ដូចគ្នាដែរ ខ្លះឈឺក្បាល គ្រុនរងា ប៉ុន្តែមិនដឹងដោះស្រាយយ៉ាងម៉េចទេ ធ្វើតាមសមត្ថភាពដែលយើងមាន បោចស្លឹកឈើស្លឹកព្រៃហ្នឹង ប៉ះអីហូបហ្នឹង។ ចាស ធ្វើម៉េចសម្រន់សិនចាស។

[០៩:៣៧:០០]

**ស៖** ក៏ប៉ុន្តែតើអ្នកដែលគេជម្លៀសហ្នឹងភាគច្រើននោះ តើពួកគាត់មើលរូបរាងកាយហ្នឹងទៅវាយ៉ាងម៉េចដែរ គឺថា មើលទៅមានសាច់មានឈាមធម្មតា ឬក៏ស្គមស្គាំងអី?

**ឆ៖** កាលពីទើបជម្លៀសទៅថ្មីៗហ្នឹង សាច់ឈាមនៅធម្មតាទេចាំ ព្រោះនៅស្រុកខ្សាច់កណ្តាលនេះយើងទើបចេញពីភ្នំពេញ ម្ល៉ោះហើយរបស់របរអីវ៉ែអីវ៉ាន់អីយើងហាក់ដូចជាមានជាប់នឹងខ្លួនគួរសម។ អ៊ីចឹងយើងអាចទៅដោះដូរនៅខាងទន្លេ នៅខាងទន្លេតូចទន្លេអីជាស្រូវ អង្ករយកមកស្តុកទុក ហើយយើងញ៉ាំម្តងបន្តិចៗ។ ដល់ពេលយើងជម្លៀសទៅដល់ពោធិ៍សាត់ហ្នឹង ក៏នៅសល់អាកាកសំណល់ចាស់ហ្នឹងបន្តិចបន្តួចហ្នឹងសម្រាប់ញ៉ាំ សាច់ឈាមយើងមិនទាន់ស្រេកស្រុតទេចាំ។ ដល់តែនៅរយៈពេលយូរបន្តិចទៅ កុំថា -- យើងមិននឹកស្មានទេ សូម្បីតែមនុស្សក៏អន់ជាងសត្វជ្រូកទៅទៀត។ ចាស ខ្ញុំនៅសហករណ៍កោះជុំហ្នឹងគឺថា ខ្ញុំបានសល់របស់តិចតួចហ្នឹងយកទៅដូរបាយជ្រូក។ ចាស បាយជ្រូកហ្នឹងល្អជាងមនុស្សហូប គឺបាយ បាយយើង -- បបរយើងភក់ៗហើយ ដាក់បន្លែមួយៗទេចាស។ ចំណែកយើងជាមនុស្សនេះ អង្ករមួយកំប៉ុងបួននាក់ សួរថាហូបយ៉ាងម៉េច? អ៊ីចឹងយើងត្រូវបោចស្លឹកឈើ ស្លឹកព្រៃលាយហូប។ ដល់អ៊ីចឹងទៅប្អូនស្រីខ្ញុំទៅជាហើម ខ្ញុំអីហ្នឹងហើមអស់ហើយ ហូបបន្លែច្រើនពេកចាស។ ហើយអ៊ីចឹងបានយើងនឹកឃើញថា ចុះសត្វក៏មានតម្លៃជាងមនុស្សម្ល៉េះ គេឲ្យតម្លៃសត្វចាស។ ជ្រូកគេឲ្យហូប ហូបច្រើនជាងមនុស្ស។

[០៩:៣៨:៥៧]

**ស៖** សូមអរគុណ។ បន្ទាប់ពីការជម្លៀសលើកទី២ នេះ អ្នកស្រីបានទៅដល់កោះធំ តើអ្នកស្រីអាចជម្រាបជូនបានទេថា មានរឿងអ្វីកើតឡើងចំពោះកូនស្រីរបស់អ្នក -- កូនប្រុសរបស់អ្នកស្រីឈ្មោះ ស៊ីណារ៉េត -- ស៊ីណារិទ្ធ (សូមទោស)?

**ឆ៖** ពេលនោះខ្ញុំទៅដល់សហករណ៍កោះធំហ្នឹង ក៏គេបែងចែកជាក្រុមជាអី គេចែកដីឲ្យសង់ផ្ទះ។ នាងខ្ញុំសេសសល់អីវ៉ាន់ហ្នឹង ក៏ដូរជាឈើ ជាឫស្សី ជាស្លឹកអីសង់ផ្ទះ ហើយបំបែកជាបីគ្រួសារ។ ក្នុងគ្រួសារខ្ញុំមាន១២នាក់ហ្នឹង ទៅដល់នុ៎ងគឺការបំបែកជាបីគ្រួសារ។ បងប្រុសប្ដីប្រពន្ធ ខ្ញុំប្ដីប្រពន្ធកូននៅសល់កូនមួយ ហើយម្ដាយខ្ញុំនិងប្អូនខ្ញុំបួននាក់ចាំ៎។ ហើយដល់ពេលនោះ គឺថាយើងទៅធ្វើការរៀងៗខ្លួនហើយ។ ចាស លែងគិតអីហើយ គិតតែខំបង្កបង្កើនផលទៅ យប់ឡើងគេប្រជុំជីវភាពកសាង ហើយនាងខ្ញុំហ្នឹងត្រូវមាត់ជាងគេ។ ព្រោះខ្ញុំធ្វើអត់ត្រូវផែនការរបស់អង្គការទេចាស។ ម៉េចថាអត់ត្រូវ? ខ្ញុំជាកូនអ្នកភ្នំពេញ កូនអ្នកធ្វើការទៀត មិនមែនកូនអ្នករកស៊ីដឹកជញ្ជូន លីសែងឯណា កូនអ្នកធ្វើការ ហើយខ្ញុំក៏ជាអ្នករៀនសូត្រ ដល់ពេលមានប្ដី មានប្ដីក៏មានបណ្ដាសក្តិ។ ដល់ពេលជម្លៀសទៅ គេឲ្យខ្ញុំទៅរែកទឹក ធ្វើកងចម្ការ។ រែកទឹកនោះ ចម្ការធំណាស់ រែកតែពីរនាក់ទេ វ័យកណ្ដាលហ្នឹង។ ១ថ្ងៃធ្វើម៉េចរែកឲ្យបាន៥០អម្រែកក្នុងម្នាក់។ ហើយចម្ងាយពីទឹកទៅដល់ចម្ការហ្នឹង វា៥០ មានតែលើសពី៥០ម៉ែត្រ។ ដល់អ៊ីចឹង ហើយសមនឹងនាងខ្ញុំហ្នឹងវាអ្នកស្រណុកផង ហើយកូនខ្ចីផង ម្ល៉ោះហើយខ្ញុំធ្វើអត់គ្រប់ផែនការទេ គេកសាងរាល់តែល្ងាចហ្នឹង។ ប៉ុន្តែយើងដាក់ខ្លួនរហូត ហើយសន្យារហូតថានឹងធ្វើម៉េចត្រង់ត្រាប់តាមអង្គការឲ្យបានគ្រប់ផែនការចាស។

[០៩:៤១:១៨]

**ស៖** អ្នកស្រី ខ្ញុំដឹងថា ជាការលំបាកក្នុងការឆ្លើយឲ្យបានច្បាស់លាស់ទៅសំណួររបស់ខ្ញុំ។ សំណួររបស់ខ្ញុំអម្បាញ់មិញនោះ គឺថាចង់ដឹងថា តើមានរឿងអីកើតឡើងចំពោះកូនប្រុសរបស់អ្នកស្រីឈ្មោះ ស៊ីណារិទ្ធ?

**ឆ៖** ចាស នៅពេលនោះ កូនប្រុសរបស់ខ្ញុំចាប់ផ្ដើមឈឺមួយសាទៀត គឺរាកដែរ។ រាក ដល់ពេលនោះ ខ្ញុំក៏បានសុំ ដល់មើលទៅឈឺដាក់ថ្នាំអីអត់បាត់ ដាក់អាថ្នាំខ្មែរហ្នឹងស្លឹកឈើស្លឹកព្រៃអត់បាត់ទេ ក៏ខ្ញុំសុំយកកូនហ្នឹងទៅសម្រាកនៅពេទ្យកណ្ដៀង ពេទ្យស្រុកកណ្ដៀងហ្នឹង ហើយកូនខ្ញុំក៏បានស្លាប់នៅទីនោះទៅ។ ខ្ញុំក៏ត្រឡប់មកសហករណ៍វិញ ពេលនោះនៅតែពីរនាក់ប្ដីប្រពន្ធតទល់ទេចាស។

**សៈ** សូមទោស ខ្ញុំសូមនិយាយសង្កត់ធ្ងន់បន្តិច តើប្អូនស្រីរបស់អ្នកស្រីនោះកើតអ្វីដែរ ក្លាយជាអី ពេលក្រោយមក?

**ផៈ** ប្អូនស្រីពៅរបស់ខ្ញុំហ្នឹង នាងក៏ស្លាប់ដែរ កើតរោគហើម។ ចាស កើតរោគហើម ដល់រួចទៅអត់មានអីព្យាបាលទេ ក៏ស្លាប់ទៀតទៅចាស។

**សៈ** នៅពេលដែលអ្នកស្រីនៅកន្លែងទី២នុ៎ង តើមានគេតាមដានអ្នកស្រីដែរឬទេ?

**ផៈ** គេតាមដានរាល់យប់ចាស។ មូលហេតុដែលខ្ញុំដឹងថាគេតាមដានរហូតដល់ផ្ទះជិតៗហ្នឹង បាត់ខ្លួនរហូត។ បន្តិចបាត់អ្នកនេះ បន្តិចបាត់អ្នកនោះ។ ប៉ុន្តែយើងព្យាយាមដឹងខ្លួនថាយើងកុំនិយាយអីឲ្យសោះ ជញ្ជាំងមានត្រចៀក។

[០៩:៤៣:៤៣]

**សៈ** តើមានការបាត់ខ្លួនដែរឬទេ នៅពេលដែលអ្នកស្រីនៅកន្លែងទី២ហ្នឹង?

**ផៈ** ចាស នៅកន្លែងទី២ ហ្នឹង ខ្ញុំជម្រាបហើយថាមានការបាត់ខ្លួន។ មានអ្នកជិតខាងខ្ញុំ គេយកប្តីទៅបាត់។ ក្រោយមកអ្នកជិតខាងមួយទៀត គេយកទាំងប្តីទាំងប្រពន្ធទៅ។ ក្រោយមកទៀត គឺបងប្រុស បងស្រីខ្ញុំពីរនាក់ប្តីប្រពន្ធហ្នឹងត្រូវគេយកទៅទៀត។ ហើយបន្ទាប់មក គឺនាងខ្ញុំនិងប្តីប្រពន្ធហ្នឹងតែម្តងចាស។

**សៈ** អ្នកស្រីបាននិយាយថា ប្តីរបស់អ្នកស្រីជាទាហាន លន់ នល់ ហើយអ្នកស្រីក៏បានពន្យល់ផងដែរថា បន្ទាប់ពីជម្លៀសលើកទី១ ហ្នឹង គឺ យន អ្នកប្រាប់អ្នកស្រីថា សុំឲ្យអ្នកស្រីលាក់អំពីមុខរបរប្តីរបស់អ្នកស្រី។ ហើយនៅកន្លែងជម្លៀសទី២ហ្នឹង នៅកោះជុំនេះ តើខ្មែរក្រហមដឹងថា ប្តីរបស់អ្នកស្រីហ្នឹងធ្វើអ្វីដែរឬទេ កាលពីសម័យមុន?

[០៩:៤៤:៥៥]

**ផៈ** ចាស នៅពេលដែលខ្ញុំទៅដល់សហករណ៍កោះជុំហ្នឹង ខ្ញុំមិនដឹងថា គេដឹងដោយវិធីណាទេ ព្រោះពេលដែលគេយកខ្ញុំ និងប្តីខ្ញុំទៅមន្ទីរកសាងខ្លួននោះ ទើបខ្ញុំដឹងថាគេដឹងអត្តសញ្ញាណរបស់ខ្ញុំ ព្រោះទៅដល់នោះយោធាដែលយាមនៅមុខគុកហ្នឹង គាត់ចេញមកស្រប្លូនប្រាំនាក់ ទាត់ធាក់ប្តីខ្ញុំ វ៉ៃបែកឈាមរហាច ហើយថែមទាំងសួរថា "កាំភ្លើងខ្លី អែ្នងលាក់នៅឯណា កាំភ្លើងខ្លី"។ ទើបខ្ញុំភ្ញាក់ខ្លួនថា អ៊ូ! មិនដឹងជាគេដឹងយ៉ាងម៉េច? យើងអត់ដឹងដែរ ចាស។

**ស៖** តើអ្នកស្រីអាចជម្រាបជូនតុលាការបានដែរឬទេថា មានរឿងអ្វីកើតឡើងចំពោះប្ដីរបស់អ្នកស្រី?

**ឆ៖** នៅពេលដែលទៅដល់មន្ទីរឃុំឃាំងហ្នឹង គឺថាហេតុការណ៍ដែលកើតមាន គឺប្ដីខ្ញុំធ្ងន់ធ្ងរ ព្រោះប្ដីខ្ញុំគេចោទតែម្ដង ឯចំណែកខ្ញុំជាប្រពន្ធគ្រាន់តែទៅតាមប្ដី។ អ៊ីចឹងគេចងស្លាបសេកបញ្ចូលទៅក្នុងគុកងងឹត។ បន្ទប់ហ្នឹងងងឹតណាស់។ ចាស ដាក់ច្រវាក់ ហ្នឹងឮគេប្រាប់ទេ ប៉ុន្តែខ្ញុំអត់បានឃើញទេ គ្រាន់តែឃើញថា ទៅដល់ហ្នឹង គេច្រានបញ្ចូលទៅតែម្ដង។ ហើយខ្ញុំក៏នាំទៅកន្លែងមួយទៀតផ្សេងពីគាត់ហ្នឹង។ ពេលហ្នឹង យើងលែងជួបគ្នាហើយ រស់នៅបែកគ្នារហូត។ រហូតទាល់តែគេយកប្ដីខ្ញុំទៅសម្លាប់បាត់ទៅ ចាស។

[០៩:៤៦:៣៨]

**ស៖** តើអ្នកស្រីផ្ទាល់ហ្នឹងត្រូវបានគេចាប់ខ្លួនដែរ ដោយសារតែប្ដីរបស់អ្នកស្រីហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស ដោយសារតែប្ដីខ្ញុំហ្នឹង គេចោទ ចោទប្ដីខ្ញុំ គេត្រូវតែឲ្យប្រពន្ធហ្នឹងទៅតាម ទៅជាមួយគ្នា ចាស។ ហើយខ្ញុំទៅរស់នៅក្នុងគុកហ្នឹង គ្រាន់ថាពេលដែលចូលទៅដល់មន្ទីរកសាងខ្លួនហ្នឹង ប្ដីខ្ញុំគេយកទៅសួរចម្លើយ ព្រោះគេចោទ មានសំបុត្រចោទ។ ចំណែកខ្ញុំអត់ទេ គ្រាន់តែទៅតាមប្ដី គេដាក់ឃុំឃាំងដូចគ្នាអ៊ីចឹង តែទោសវាស្រាល អាចចេញទៅធ្វើការ អាចចេញទៅធ្វើការនៅខាងក្រៅបាន។ អាចទៅហូបបាយនៅការដ្ឋានបាន។ ធ្វើការព្រឹក ថ្ងៃត្រង់ហូបបាយនៅការដ្ឋាន ចំណែកប្ដីខ្ញុំនៅក្នុងគុកងងឹតហ្នឹង គឺថាបានរបបតែបបរតែមួយវែក អំបិលគ្រួសមួយគ្រាប់។

**ស៖** នៅពេលដែលអ្នកស្រីត្រូវបានគេចាប់ខ្លួនដែរនោះ ហើយនៅកន្លែងដែលអ្នកស្រីស្នាក់នៅនោះ តើអ្នកស្រីមានសង្កេតឃើញថា មានការបាត់ខ្លួន ឬមួយក៏ការសម្លាប់មនុស្សអីដែរឬទេ?

[០៩:៤៨:០៥]

**ឆ៖** កន្លែងហ្នឹងនៅកន្លែងណា ចាស? អាកន្លែងថាបាត់ខ្លួននេះ ក្រោយនេះអំមិញនេះចាស។ សូមអញ្ជើញមានប្រសាសន៍ម្ដងទៀត សំណួរចាស។

**ស៖** អ្នកស្រីបានជម្រាបជូនថា ប្ដីរបស់អ្នកស្រីត្រូវបានចាប់ខ្លួន ហើយនិងបានសម្លាប់ ហើយអ្នកស្រីក៏ត្រូវបានចាប់ខ្លួនដែរ ហើយអ្នកស្រីក៏ត្រូវបានចាប់ខ្លួនដែរ ហើយនិងនាំទៅក្នុងមន្ទីរឃុំឃាំងមួយ។ តើនៅមន្ទីរឃុំឃាំងនុ៎ង អ្នកស្រីមានបានសង្កេតឃើញថា មានការបាត់ខ្លួន ឬក៏សម្លាប់មនុស្ស

ដែរឬទេ?

**ឆ៖** ចាស ទៅដល់កន្លែងនោះ គឺជាការសម្លាប់តែម្តង។ ចាស ពេលខ្ញុំទៅដល់ភ្លាម គេរុញខ្ញុំចូលក្នុងបន្ទប់នោះ ខ្ញុំក៏សំងំ គឺថាហេតុការណ៍នោះ គឺថាមិនគួរឲ្យជឿ។ ចានបាយសម្រាប់ដាក់បាយហូប វាបែរទៅជាដាក់លាមក ដាក់ទឹកនោម។ គឺថាអ្នកទោសត្រូវជុះដាក់ក្នុងចានហ្នឹង ហើយយកទៅចាក់មានប្រអប់មួយនៅកណ្តាលបន្ទប់ហ្នឹង មានដូចជាប្រអប់ ដូចជាធុងអីមួយសម្រាប់ជុះហើយ យកទៅចាក់ហើយ។ ចាន ទុកចោលហ្នឹងទៅ ចាស។ ហើយខ្ញុំ ដល់ពេលវាស្អុយពេក ហើយអត់មានមនុស្សទេ នៅសល់មនុស្សប្រហែលជាពីរនាក់ បីនាក់ទេ អ្នកឈឺដែលទៅធ្វើការអត់រួច។ អ៊ីចឹងត្រូវនៅសម្រាកក្នុងគុកហ្នឹង។ ខ្ញុំខំយកច្រមុះមកផ្អិបនឹងប្រហោងទ្វារដកដង្ហើមឲ្យស្រួល។ ស្រាប់តែមួយសន្ទុះ យោធាមួយយោធាហ្នឹងបើកទ្វារចេញមក យោធាហ្នឹងគឺថា គេគ្រាន់ -- ខ្ញុំគ្រាន់តែដឹងថាជាកូនមេគុក ឈ្មោះតាឃិន ហ្នឹង។ ហើយយោធាហ្នឹងអូសកាំភ្លើងនៅ -- ដែលទាបតូចហ្នឹង មិនទាន់គ្រប់អាយុផង ស្ពាយកាំភ្លើងអូសដីចូលមកហៅមិត្តមួយហ្នឹង ថាឈ្មោះ ខេង "មើល៍មិត្តខេង ឯងចេញមកនេះភ្លាម! ម៉េចបានលួចត្រីអាំងគេ?" ថាចោទគ្នា ថាលួចត្រីអាំង។ គ្រាន់តែចេញទៅដល់ភ្លាម ខ្ញុំចេះតែតាមមើលរហូត។ យកជំពុះទង់ចាក់ចំចុងដង្ហើម ទាញខ្វាកមក ពោះវៀនធ្លាយទ្រេល។ ខ្ញុំខំខ្ទប់មាត់អត់ហ៊ានស្រែកទេចាស។ ព្រោះតែស្រែកទៅខ្លាចគេយកទាំងខ្ញុំទៅទៀត។

[០៩:៥០:០៦]

ដូច្នេះហើយ ខ្ញុំខ្ទប់មាត់ហើយអ្នកដែលដេកនៅក្នុងហ្នឹង ដែលឈឺហ្នឹងប្រាប់ថា ហ៊ឺ កុំយកចិត្តទុកដាក់ គេសម្លាប់តែអ៊ីចឹងរាល់ថ្ងៃ ទើសគឺសម្លាប់ៗ អត់មានថាចេញពីនេះទៅធ្វើអី គឺដឹងតែស្លាប់ហើយ។ ចាស ហើយខ្ញុំរស់នៅក្នុងមន្ទីរកសាងខ្លួនហ្នឹងជារៀងរាល់៣ថ្ងៃម្តង។ រាល់ពេល៣ថ្ងៃ គេហៅថា "ថ្ងៃធ្វើការ" គឺថ្ងៃទី១ ទី២ ថ្ងៃទី៣ ធ្វើការព្រឹក បាយហើយគេបញ្ចូលយើងឲ្យមកនៅសម្រាកនៅកន្លែងហ្នឹង គឺគេហៅ "ថ្ងៃធ្វើការ" យើងអត់ចេញទៅធ្វើការទេ មានយោធាមកបញ្ចោហើយ ហ៎! សូមវ័យកណ្តាល ៥០ សុំវ័យកុមារ ២០-៣០ អ៊ីចឹង សរុបទៅវាមាន១០០ជាង ២០០ ២០០ជាង គឺយកទៅ "ភាគ"។ ហើយពេលនោះ នាងខ្ញុំអត់ដឹងថា "ភាគ" ហ្នឹងជាស្អីទេ គ្រាន់តែឮគេបកស្រាយថា "ភាគ" ហ្នឹងសម្បូរហូបណាស់ នៅបាត់ដំបង មានស្រូវអង្ករច្រើន មានត្រី មានក្រូចអ៊ីចឹង អើ! ស្រុកពោធិ៍សាត់ -- ស្រុកបាត់ដំបង អ្នកណាក៏ល្បីរឿងក្រូច រឿងស្រូវហ្នឹងដែរចាស។ មានជួនកាល ខ្ញុំពិបាកពេកនៅនេះ ខ្ញុំសុំគេទៅទៀត សុំមេកង "ខ្ញុំសូមទៅផងមិត្តបង! ខ្ញុំសុំទៅភាគផង!" ហ៊ឺ! យាយឯងទៅធ្វើអីកសាងខ្លួនមិន

ទាន់បានទេ នៅសិននៅ ប៉ុន្តែចុងក្រោយមក ទើបខ្ញុំដឹងថា "ភាគ" នេះគឺជាការសម្លាប់មនុស្ស។ ហើយអត់មាននៅឆ្ងាយទេ នៅក្នុងមន្ទីរឃុំឃាំង មន្ទីរកែប្រែហ្នឹងតែម្តង ព្រោះយើងដឹងដោយសារមានក្លិនស្អុយជះមក ប៉ុន្តែអត់ថាអីទេ ក្រោយមកទាហាន ដែលមើលការពារយើងបណ្តើរយើងទៅធ្វើការ ដែលរស់នៅក្នុងមន្ទីរហ្នឹង គាត់មានទោស ក្លាយជាអ្នកទោសដូចយើងអ៊ីចឹង។

[០៩:៥១:៤៩]

ហើយគាត់បានខ្សឹបប្រាប់យើងថា "មិត្តឯងដឹងទេ តាំងពី -- អី ខ្ញុំថាតាំង -- ខ្ញុំ ៧៦ គេសម្លាប់អ៊ីចឹង ហ៊ឺ តាំងពី៧៥ តាំងពីបែកមក សម្លាប់អ៊ីចឹង ៣ថ្ងៃសម្លាប់ៗ។ ហើយអត់មានឯណាឆ្ងាយទេ នៅហ្នឹង។ ចុងឆ្នាំ -- ពាក់កណ្តាលឆ្នាំ៧៧ ប្រហែលជា ១០ម៉ឺននាក់ អ្នកដែលត្រូវសម្លាប់ហ្នឹងចាស។" ហើយបើតាមខ្ញុំវិភាគទៅក៏ប្រហាក់ប្រហែលហើយ ព្រោះមួយយប់ៗបញ្ជូនមកពីសហករណ៍ ពីតំបន់ផ្សេងៗ គឺថាគគ្រឹកគគ្រេងដូចផ្សារអូរឫស្សីអ៊ីចឹង។ បាន២, ៣ថ្ងៃ ខ្លះបានមួយយប់ ខ្លះបានមួយអាទិត្យ ស្ងាត់សូន្យទៅអស់រលីងចាស។ ហ្នឹងសុទ្ធតែយកទៅភាគហើយ។ ហើយៗជាក់ស្តែងគឺថា អីវ៉ែអីវ៉ាន់ខោអាវ អ្នកដែលនៅជាមួយគ្នានឹងខ្ញុំហ្នឹង គឺត្រឡប់មកឲ្យយើងប្រើវិញទាំងអស់ ព្រោះអ្នកហ្នឹងតែទៅវេចបង្វេចទៅហើយ។ ហើយដល់ពេលវេចបង្វេចទៅ មិនត្រូវដល់គេសម្លាប់ហើយ គេយករបស់របរអស់ហ្នឹងយកមកដាក់ឲ្យយើងប្រើវិញដដែល។ ទើបនាងខ្ញុំដឹងថា អូ៎! ជា "ភាគ" ហ្នឹងជាកន្លែងសម្លាប់ទេ។ ហេងដែរ គេចេះអត់យកទៅចាស។

[០៩:៥៣:១២]

**ស៖** សូមអរគុណអ្នកស្រី។ ដើម្បីបញ្ចប់ហ្នឹង ខ្ញុំសូមចោទសំណួរជាលក្ខណៈទូទៅមួយចំនួន ពេលដែលអ្នកស្រីនៅទីក្រុងភ្នំពេញ គេប្រាប់អ្នកស្រីថា "៣, ៤ថ្ងៃក្រោយមកហ្នឹង អ្នកស្រីនឹងត្រឡប់មកភ្នំពេញវិញ"។ តើពេលក្រោយមក តើគេមានបានពន្យល់ប្រាប់អ្នកស្រីទេថា ហេតុអ្វីក៏អ្នកស្រីមិនអាចមកភ្នំពេញវិញបាន?

**ឆ៖** គេអត់បានប្រាប់យើងទេ ហើយយើងក៏ម៉ិានសួរគេដែរ ព្រោះទៅដល់ឃើញបាត់ខ្លួនឃើញស្លាប់អ៊ីចឹង យើងគិតថា កុំឆ្ងល់ អង្គការឲ្យធ្វើអី ធ្វើហ្នឹងទៅ ធ្វើម៉េចឲ្យរស់។ ចាស អត់ឆ្ងល់ទាំងអស់ចាស។

**ស៖** ពេលអ្នកស្រីចាកចេញពីទីក្រុងភ្នំពេញហ្នឹង គេប្រាប់ថាៗ "ដោយសារអាចនឹងមានការទម្លាក់គ្រាប់បែកពីសំណាក់ពួកអាមេរិកាំង"។ នៅពេលអ្នកស្រីចេញពីកន្លែងទី១ គេប្រាប់ថា "គេនឹងនាំ

អ្នកស្រីទៅបាត់ដំបង។ ហើយអ្នកស្រីក៏បានជម្រាបផងដែរថា ខ្មែរក្រហមបង្កើតលេស ហើយគេមិនដែលគោរពកិច្ចសន្យារបស់គេទេ"។ ហើយអ្នកស្រី ចំពោះអ្នកស្រីផ្ទាល់ហ្នឹង តើមូលហេតុនៃការជម្លៀសប្រជាជនចេញពីកន្លែងមួយទៅកន្លែងមួយនេះ ជាអ្វីដែរ?

**ឆ៖** ខ្ញុំគិតហើយថា ការជម្លៀសពីប្រជាជនពីកន្លែងមួយទៅកន្លែងមួយហ្នឹង ដើម្បីធ្វើការលត់ដំ ហើយបើគេជាប្រាប់យើងត្រង់ថា ចេញពីនេះ ទៅនៅនោះទៅ យើងវាមានកម្មសិទ្ធិនោះ។ យើងមិនអាចដាច់ចិត្តចោលផ្ទះ ចោលឡាន ចោលម៉ូតូ ចោលអីវ៉ែអីវ៉ាន់ នៅក្នុងផ្ទះ។ ម្ល៉ោះហើយ គេគ្រាន់តែប្រាប់យើងថា ទៅ៣ថ្ងៃ ឬ១អាទិត្យអ៊ីចឹង យើងទៅសិនហើយ រៀបរយទុកដាក់ឲ្យស្រួល ហើយទៅសិន។ ដូច្នេះ ដល់ពេលចេញទៅ បាត់ទៅៗ មិនឃើញប្រែប្រួលអី ឃើញតែបញ្ជូនទៅទៀត នោះលែងគិតហើយ គិតថាធ្វើម៉េចខំកសាងខ្លួន ខំដើរតាមមាគ៌ារបស់អង្គការ ដើម្បីឲ្យរស់ ប៉ុន្តែទីបំផុត ស្លាប់ទាល់តែអស់។ គ្រួសារខ្ញុំនៅសល់តែពីរនាក់ ១០នាក់ស្លាប់។

[០៩:៥៥:៤៨]

**ស៖** អ្នកស្រីបានឆ្លងកាត់ការជម្លៀសចេញពីភ្នំពេញ ជម្លៀសដោយបង្ខំ។ ហើយនៅកន្លែងទី១ ដែលអ្នកស្រីស្នាក់នៅ ហើយអ្នកស្រីបានរៀបរាប់អំពីលក្ខខណ្ឌរស់នៅទីនោះ ហើយនិងមានកន្លែងមួយទៀត ដែលគេបង្ខំឲ្យអ្នកស្រីធ្វើការជាទម្ងន់ ហើយនៅមន្ទីរឃុំឃាំង អ្នកស្រីបានពន្យល់រៀបរាប់ទាក់ទងនឹងមន្ទីរឃុំឃាំងនេះដែរ។ តាមរយៈបទពិសោធន៍របស់អ្នកស្រី អ្វីដែលអ្នកស្រីឆ្លងកាត់នេះ តើអ្នកស្រីគិតថា ការជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយនិងការបង្ខំធ្វើការដោយបង្ខំនេះ គឺជាគោលនយោបាយរបស់ខ្មែរក្រហម។ តើអ្នកស្រីយល់អ៊ីចឹងដែរឬទេ?

**ឆ៖** ចាស ខ្ញុំធ្វើការវិភាគទៅ ខ្ញុំវិនិច្ឆ័យថា នេះគឺជាគោលនយោបាយរបស់ខ្មែរក្រហមពិតប្រាកដ។ ព្រោះគេអត់មានឲ្យតម្លៃជីវិតមនុស្សទេ។ គេឲ្យតម្លៃមនុស្សថោកជាងសត្វធាតុទៅទៀត គឺស្លាប់ប៉ុន្មាន ស្លាប់ទៅ ឲ្យតែមាគ៌ា ឲ្យតែអង្គការគេមានវត្តមានទៅមុខទៀតចាស។ គេអត់បានគិតទេ បើសិនជាគិត អត់ខ្វះទេ ថ្នាំសង្កូវ ស្រូវអង្ករ ហូបចុក។ យើងឲ្យតែបានហូបឆ្អែតណ៎ះ រស់នៅជុំបងប្អូន ប្តីប្រពន្ធអី យើងចេះតែធ្វើស្រែកើតហើយ។ ដំបូង ពិបាកមែន ដំបូងវាពិបាកជាទីបំផុតហើយ ប៉ុន្តែក្រោយមក នាងខ្ញុំស្ទូងដកលឿនជាងអ្នកចាស់ទៅទៀត ក្រោយការប្រឹងប្រែងរបស់យើង យើងប្រឹងប្រែងធ្វើសព្វបែបយ៉ាង តែលឿនជាងអ្នកចាស់។ ប៉ុន្តែនេះ គេអត់ឲ្យតម្លៃ គឺគេចង់សម្លាប់មនុស្សតែម្តង ធ្វើម៉េច រង្គាលឲ្យអស់មនុស្ស ដើម្បីកើតមកថ្មីហ្នឹង វាមានគំនិតថ្មីទាំងអស់ អត់មានជាប់ស្នាមដានចាស់

នៅក្នុងខួរក្បាលតទៅទៀតចាស។

[០៩:៥៧:៥៩]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណអ្នកស្រី ខ្ញុំលែងមានសំណួរចោទទៅអ្នកស្រីទៀតហើយ។ ហើយខ្ញុំសូមអរគុណណាស់ ដែលបានមកផ្តល់សក្ខីកម្មដ៏លំបាក ហើយនិងបានផ្តល់ព័ត៌មានជាច្រើនចូលរួមចំណែកក្នុងសំណុំរឿងនេះ ហើយសូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា។

[០៩:៥៨:២៩]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ ជម្រាបសួរសាធារណជន និងជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី។

យើងខ្ញុំនឹងសួរសំណួរឡើងវិញ ខ្ញុំមិនសួរច្រើនទេ។ ខ្ញុំនឹងសួរទៅដល់ពេលសម្រាកពេលព្រឹកនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំចង់ទទួលបានការបញ្ជាក់មួយចំនួនពីលោកស្រី ដោយត្រឡប់មកនិយាយ -- តាំងពីថ្ងៃ ១៧ មេសា ៧៥ មកវិញ។ ដើម្បីឲ្យមានការបញ្ជាក់ឲ្យច្បាស់នោះ តើលោកស្រីអាចផ្តល់ឈ្មោះប្តីទី១របស់លោកស្រីបានទេ? ប្តីដែលជានាយទាហានរបស់ លន់ នល់ ហើយបន្ទាប់ត្រូវបានសម្លាប់ចោលនៅពោធិ៍សាត់នោះ តើគាត់ឈ្មោះអ្វីដែរ?

**លោកស្រី ឡាយ បូនី៖**

**ឆ៖** ចាស ប្តីនាងខ្ញុំឈ្មោះ ប្រាក់ ស៊ីណាត។ គាត់កើតនៅឆ្នាំ១៩៤៨ នៅខេត្តពោធិ៍សាត់។

**ស៖** សូមអរគុណ។ ប្រសិនបើខ្ញុំយល់មិនច្រឡំទេ កាលពីម្សិលមិញនោះ លោកស្រីឆ្លើយថា “លោក ប្រាក់ ស៊ីណាត នេះ មិនបានចូលរួមប្រយុទ្ធប្រឆាំងខ្មែរក្រហម នៅទីក្រុងភ្នំពេញទេ”។ ក្រៅពីនេះ តើលោកស្រីមានបានឃើញ ឬក៏បានស្តាប់ឮថា នៅថ្ងៃ១៧ មេសា ៧៥ ហ្នឹង មានការវាយប្រយុទ្ធ

គ្នានៅទីក្រុងភ្នំពេញដែរឬទេ?

[១០:០០:០៦]

**ផ៖** នាងខ្ញុំអត់បានដឹងទេចាស គ្រាន់តែដឹងថាខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញហើយ គ្រាប់ផ្ដោងក៏លែងធ្លាក់ ស្ងាត់ឈឹង ហើយយើងទាំងអស់គ្នាអបអរសាទរនឹងជ័យជម្នះ១៧ មេសា ហ្នឹង ដែលខ្មែរក្រហមចូល ជឿថា អូ៎! ប្រទេសកម្ពុជាយើងមានសុខសន្តិភាពហើយ នេះចប់សព្វគ្រប់អស់ហើយចាស។

**ស៖** បាទ ពិតណាស់ លោកស្រីបាននិយាយថា លោកស្រីចេញទៅតាមផ្លូវដើម្បីអបអរជ័យជម្នះ ហើយឃើញមានអ្នកលើកទង់ជ័យស។ តើលោកស្រីមានភ័យខ្លាចទេ នៅពេលដែលឃើញមានយោធាអីដើរកាត់មុខអីចឹងនោះ?

**ផ៖** ចាស នាងខ្ញុំមានការភ័យខ្លាច ព្រោះធ្លាប់ឃើញ -- ឮ ធ្លាប់ឮថា អូ៎! អត់បានទេពួកហ្នឹងកាលជំនាន់ចាប់ទាហានទៅពីមុនបែកហ្នឹង អារកនឹងធាងត្នោត សុទ្ធតែវះថ្លើមវះអី នាងខ្ញុំខ្លាច។ ឃើញតែខ្មៅៗហ្នឹង ខ្លាចបាត់ហើយចាស។

**ស៖** បាទ សូមអរគុណ។ លោកស្រីនិយាយថា មានប្រជាជនជាច្រើនចេញទៅតាមផ្លូវច្រៀងរាំអបអរសាទរជ័យជម្នះរបស់ខ្មែរក្រហម។ តាមទស្សនៈរបស់ខ្មែរក្រហម នៅពេលដែលឃើញមានប្រជាជនទទួលរាក់ទាក់បែបនេះ តើខ្មែរក្រហមធ្វើយ៉ាងម៉េចដែរ? ពួកគេអបអរសាទរជាមួយប្រជាជនដែរ ឬក៏ពួកគេមានការប្រុងប្រយ័ត្ននៅពេលដែលឃើញប្រជាជនអបអរបែបនេះ?

**ផ៖** ពួកគេមានការប្រុងប្រយ័ត្នចាស គេអត់មាននេះទេ គ្រាន់តែយើងលើកដៃស្វាគមន៍អីចឹងទៅ គេលើកមកវិញ។ ចាស គេអត់មានថា អូ៎ បាត់ប្រហែសការចងចាំរបស់គេ អត់ទេចាស គេប្រយ័ត្នប្រយែងណាស់។

[១០:០២:៣១]

**ស៖** សូមអរគុណ។ កាលពីម្សិលមិញលោកស្រីបានឆ្លើយថា លោក -- មានការផ្សាយសាររបស់ខ្មែរក្រហមតាមវិទ្យុ។ តើលោកស្រីអាចបញ្ជាក់បានទេថា នៅពេលដែលលោកស្រីនៅតាមផ្លូវ ឬក៏ពេលស្រីចូលទៅផ្ទះវិញនោះ តើខ្មែរក្រហមមានប្រើមីក្រូ ឬឧបករណ៍ផ្សាយសំឡេង ដើម្បីផ្សព្វផ្សាយសារ ឬក៏ការណែនាំរបស់ខ្មែរក្រហម ចំពោះប្រជាជននោះ?

**ផ៖** នាងខ្ញុំឮតែម្ដងហ្នឹង កាលនៅផ្ទះ។ ចាស ដល់ពេលចេញទៅតាមផ្លូវនាងខ្ញុំលែងឮអីទៀត

ហើយចាស ព្រោះអត់មានអីស្តាប់ផងទៅតាមផ្លូវចាស។ មីក្រូតាមផ្លូវអីក៏អត់ឮ គ្រាន់តែឮតែសម្រែកថា “ចេញៗ! ទៅឆាប់!”។ ឮតែប៉ុណ្ណឹង។

**សៈ** សូមអរគុណ។ ហើយលោកស្រីនិយាយថា មានទាហានម្នាក់ពីរនាក់មកផ្ទះលោកស្រី ហើយគេបញ្ជាឲ្យចេញពីផ្ទះភ្លាមៗ។ តើក្រោយពីពួកទាហាននោះមកហើយ លោកស្រីសម្រេចចាកចេញពីផ្ទះភ្លាម ឬក៏លោកស្រីត្រូវការពេលមួយចំនួនដើម្បីប្រមូលអីវ៉ាន់ចេញពីផ្ទះ ហើយឬក៏មានទាហានមកចាំពិនិត្យមើល ថាតើលោកស្រីពិតជាបានចេញពីផ្ទះឬក៏អត់?

[១០:០៣:៥៩]

**ឆៈ** នៅពេលនោះនាងខ្ញុំបានរៀបចំអីវ៉ាន់ហើយតាំងពីមុននោះ ព្រោះៗមុននឹងបែកហ្នឹងគ្រាប់ផ្លោងអីចុះឡើង អ៊ីចឹងអីវ៉ាន់រៀបហើយអស់ហើយចាស។ ហើយព្រលឹមឡើងគឺដឹងតែដាំបាយឆ្អិនហើយដើម្បីថាមិនបាច់គិតអីទេ គិតថាតែដល់ម៉ោងហូប ត្រូវតែឆ្អិនស្រាប់។ ដល់ផ្សំនឹងពេលនោះយោធាហ្នឹងក៏បានចូលមករបងផ្ទះខ្ញុំ ហើយប្រាប់ ហើយគេនិយាយធ្វើដៃខ្វែងខ្វាត់មុខមាំ ប្តីខ្ញុំក៏សម្រេចថាត្រូវតែចុះបងប្អូនខ្ញុំអីថា អត់បានទេ! កុំនៅ។ ទៅបើគេបង្ខំអ៊ីចឹងហើយ យើងត្រូវចេញ តែចេញ -- មិនចេញខ្លាចគេបាញ់ ខ្លាចគេអីអ៊ីចឹងចាស។

**សៈ** សូមអរគុណ។ ទាហានដែលមកប្រាប់ឲ្យលោកស្រីចេញនោះ តើគេ -- មានគេប្រាប់លោកស្រីឲ្យចេញ៣ថ្ងៃ ឬក៏៧ថ្ងៃ នៅពេលដែលទាហាននោះមកប្រាប់នៅថ្ងៃ១៧ មេសា ៧៥ ហ្នឹង គេប្រាប់ថា ចេញតែ៣ថ្ងៃ ឬក៏ចេញដល់ទៅ៧ថ្ងៃ?

**ឆៈ** គេប្រាប់ដំបូងថា ចេញតែ៣ថ្ងៃទេ បើយ៉ាងយូរណាស់៧ថ្ងៃ។ ហើយមិនបាច់យកអីទៅច្រើនទេ កុំឲ្យពិបាកដឹកទៅ ដឹកមក។ ហើយពេលនោះនាងខ្ញុំក៏គិតថាអ៊ីចឹងមែនហើយ ព្រោះវាមិនដែលអ្នកណាឲ្យចេញពីផ្ទះទៅនៅស្រែអត់មានឲ្យយកអីវ៉ែអីវ៉ាន់ទៅ។ នឹកស្មានមិនដល់ថា មាត់របស់អង្គការហ្នឹងវាៗលោតផ្លោះយ៉ាងហ្នឹង។ ដល់អ៊ីចឹងជឿ ជឿថា៣ថ្ងៃប្រាកដជាមកវិញ ១អាទិត្យយ៉ាងយូរចាស។ ដល់អ៊ីចឹងមនុស្សចេញព្រូសប្រាសភឹងៗគ្រប់គ្នាចាស។

[១០:០៥:៥៣]

**សៈ** លោកស្រីបានឆ្លើយថា លោកស្រីទៅស្រុកស្រែ។ អ៊ីចឹងគេមានប្រាប់ថាតើទៅកន្លែងណាឲ្យប្រាកដទេ? ឬក៏មិនមានការប្រាប់ទេ គ្រាន់តែប្រាប់ថា ត្រូវតែចេញពីក្រុងអ៊ីចឹង?

**ឆៈ** ចាស គេអត់បានប្រាប់ថាឲ្យទៅស្រុកណា ខេត្តណាទេ គ្រាន់តែថាចេញឲ្យផុត ធ្វើម៉េចឲ្យ

ផុតពីភ្នំពេញចាស។ ហើយដល់ពេលនោះយើងទៅដល់ អាពីត្រឹមផ្លូវមុនីវង្សហ្នឹង មុខសាលាច្បាប់ហ្នឹង វាណែនណាន់មែន ប៉ុន្តែដល់ទៅដល់ក្បាលថ្នល់ វាមានផ្លូវបែកទៅក្បាលថ្នល់ឆ្លងស្ពាន វាមានផ្លូវបែកទៅកៀនស្វាយ ទៅទន្លេបាសាក់អីអីចឹងទៅ វារាងទូលាយបន្តិចទៅចាស។ គឺឲ្យចេញឲ្យផុត អត់មានកំណត់ថា ទិសនេះ ទិសនោះអីអត់ទេ។ អ្នកណាចេញច្រកណាច្រកទៅ។

**ស៖** នៅពេលដែលពួកទាហានទាំងបីនាក់មកផ្ទះលោកស្រីនោះ តើគេមានប្រាប់ថា មានមធ្យោបាយធ្វើដំណើរសម្រាប់ដឹកជញ្ជូនប្រជាជនជម្លៀសចេញទេ?

[១០:០៧:០៥]

**ឆ៖** ចាស គេអត់មានប្រាប់ទេ។ គេគ្រាន់តែប្រាប់ឲ្យចេញ ចង់យើងធ្វើមធ្យោបាយ ប្រើមធ្យោបាយអីក៏បាន ស្រេចយើងម្ចាស់ការខ្លួនឯងចាស។

**ស៖** ពួកគេប្រាប់ថា ឲ្យយករបស់របរបន្តិចបន្តួច តើគេមានប្រាប់ថាឲ្យយកម្ហូបអាហារ ថ្នាំឬក៏របស់របរសំខាន់ៗចាំបាច់សម្រាប់ការចេញដំណើរ៧ថ្ងៃហ្នឹងទេ?

**ឆ៖** ចាស គេមិនបានប្រាប់ថាឲ្យយករបស់នេះ របស់នោះទេ ស្រេចតែយើង។ យើងចង់យកអីដែលយើងត្រូវប្រើរាល់ថ្ងៃ ត្រូវហូបរាល់ថ្ងៃហ្នឹងជារឿងរបស់យើងចាស។ ហើយដល់ចំពោះគ្រួសារខ្ញុំ ខ្ញុំអត់បានយកអង្ករទៅធ្ងន់ ខ្ញុំយកតែលុយចេញទៅចាស ស្ពាយលុយ ព្រោះទៅដល់ណាក៏ ឲ្យតែមានលុយគឺរស់បានហើយចាស។

[១០:០៨:១៤]

**ស៖** បាទ គឺថា ខ្មែរក្រហមមិនបាននិយាយទេ នូវ -- ហើយ ប៉ុល ពត មិនបាន -- ខ្មែរក្រហមមិនបានប្រាប់ទេថា យកលុយទៅអត់មានបានប្រយោជន៍អីទេ នៅពេលដែលមកបញ្ជាឲ្យលោកស្រីចេញនោះ?

**ឆ៖** គេអត់បានប្រាប់ផងចាស។ ដល់តែពេលចេញទៅបណ្តើរៗចេះតែឮហែៗទៅ បាន អ្ហ៎! អស់សង្ឃឹមហើយ ចប់ហើយលុយអត់ចាយ។

**ស៖** សូមអរគុណ។ លោកស្រីបាននិយាយអំពីថាលេសទម្លាក់គ្រាប់បែក។ ឥឡូវខ្ញុំចង់ត្រឡប់មកនិយាយពីចំណុចនេះ។ នៅពេលដែលខ្មែរក្រហមមកដល់ផ្ទះលោកស្រី ឬក៏នៅពេលដែលលោកស្រីឃើញខ្មែរក្រហមផ្សេងទៀតនៅតាមផ្លូវក្នុងទីក្រុងភ្នំពេញ ហើយនិងពេលក្រោយមក។ តើគេមានបានប្រាប់មូលហេតុអ្វីផ្សេងក្រៅពីថាមានមូល -- មានអាមេរិកទម្លាក់គ្រាប់បែកហ្នឹង ដើម្បីឲ្យប្រជាជន

ចេញពីទីក្រុងភ្លាមៗ ដោយមិនមានការលំបាកនោះ?

**ឆ៖** គេអត់មានប្រាប់អី ក្រៅពីថា អាមេរិកាំងទម្លាក់គ្រាប់បែក។ ហើយយើងឮតែទម្លាក់គ្រាប់បែកខ្ទេចអស់ហើយ អ៊ីចឹងត្រូវតែប្រញិបប្រញាប់ចេញឲ្យឆ្ងាយពីក្រុងចាស ដើម្បីគេរៀបចំអីឲ្យស្រួលបួល សឹមចូលត្រឡប់មកវិញ។

[១០:០៩:៤៨]

**ស៖** សូមអរគុណ។ លោកស្រីក៏បានឆ្លើយផងដែរថា ប៉ុល -- ខ្មែរក្រហមដែលមកផ្ទះលោកស្រីនោះគឺមានកាន់កាំភ្លើង ហើយលោកស្រីខ្លាច។ តើឥរិយាបទរបស់ពួកគេនោះ មានលក្ខណៈជាការគំរាមកំហែងទេចំពោះលោកស្រីនោះ?

**ឆ៖** ពេលនោះ គេអត់បានគំរាមកំហែងអីទេ ខ្ញុំនៅលើផ្ទះទេ។ ប្ដីខ្ញុំអ្នកជួប ប៉ុន្តែគ្រាន់យើងឃើញតែគេស្ពាយកាំភ្លើង ឃើញគេនិយាយឆ្ការដៃឆ្ការជើង ច្រងេងច្រងាង យើងខ្លាចគេបាត់ទៅហើយចាស។

**ស៖** កាលពីម្សិលមិញ លោកស្រីឆ្លើយថា គេបញ្ជាឲ្យចេញដាច់ខាត។ តើរបៀបដែលគេចេញបញ្ជាឲ្យចាកចេញនោះ ហើយនិងឥរិយាបទរបស់ខ្មែរក្រហមបែបនោះ តើធ្វើឲ្យលោកស្រីគិតថា លោកស្រីមានសិទ្ធិជ្រើសរើសដោយសេរីថា នៅផ្ទះក៏បាន ចេញក៏បាន ស្រេចចិត្ត តើលោកស្រីមានគិតអ៊ីចឹងទេ?

[១០:១១:០០]

**ឆ៖** ពេលនោះ ខ្ញុំអត់បានគិតដូច្នេះទេចាំ។ ខ្ញុំគិតថា ត្រូវតែចេញ ព្រោះការទម្លាក់គ្រាប់បែករបស់អាមេរិកាំងហ្នឹងមិនបានទេ ដូចគ្រាប់ផ្លោងអ៊ីចឹង ផ្លោងទៅផ្លោងមកៗ ទម្លាក់គ្រាប់ឆេះផ្ទះឯណេះឆេះផ្ទះឯណោះ។ ដល់អ៊ីចឹងត្រូវតែជឿ។ ត្រូវតែទៅ ចាស ត្រូវតែចេញអ៊ីចឹងតែម្ដង។

**ស៖** នៅតាមផ្លូវនៅពេលចេញពីទីក្រុងភ្នំពេញនោះ នៅតាមសង្កាត់ផ្សេងៗដែលលោកស្រីឆ្លងកាត់នោះ តើលោកស្រីធ្លាប់ឃើញ ឬស្ដាប់ឮថាមានអ្នកណាម្នាក់ធ្លាប់ជជែកតវ៉ាប្រឆាំងទៅនឹងបញ្ជាចាកចេញពីទីក្រុងរបស់ខ្មែរក្រហមទេ?

**ឆ៖** ខ្ញុំអត់ឃើញផ្ទាល់ទេ ប៉ុន្តែគ្រួសារខ្ញុំ បងប្អូនខ្ញុំ គេឃើញ។ គេប្រាប់ថា បើគេឲ្យទៅមុខត្រូវទៅមុខកុំងាកឲ្យសោះ បើយើងប៉ានតែដើរថយក្រោយវិញ គេសម្លាប់ចោលតែម្ដង។ ព្រោះគេឃើញផ្ទាល់ ហើយពេលនោះ ខ្ញុំស្ទូរកាំភ្លើងមែនចាស។

**ស៖** នៅក្នុងទីក្រុងភ្នំពេញ នៅពេលចាកចេញនោះ តើលោកស្រីមានឃើញផ្ទាល់ភ្នែកទាហានខ្មែរក្រហមបាញ់ឡើងលើ ឬក៏គំរាមកំហែងឲ្យប្រជាជនចេញឲ្យលឿនបំផុតទេ?

[១០:១២:៣៧]

**ឆ៖** នៅពេលនោះ ខ្ញុំៗឃើញជាក់ស្តែងចាស ជាក់ស្តែងគឺខ្លួនខ្ញុំតែម្តង គេគំរាមកំហែង។ ពេលដែលខ្ញុំចេញទៅ ខ្ញុំមានកាបូបពណ៌ត្រែអ៊ី ពណ៌ទាហានហ្នឹង ខ្ញុំស្ពាយមួយ គឺដាក់លុយ ដាក់សម្ភារៈសំខាន់ៗមាសប្រាក់អីនៅក្នុង។ ដល់អ៊ីចឹង ខ្ញុំស្ពាយជាប់នឹងខ្លួន ហើយខ្ញុំអង្គុយលើឡាន។ ខ្មែរក្រហមហាក់ដូចជាស្អប់ទាហានជាទីបំផុត។ គ្រាន់តែឃើញកាបូបពណ៌ត្រែអ៊ីហ្នឹង គាត់ចង្អុលកាំភ្លើងមកខ្ញុំ ខ្ញុំជិះនៅលើឡាន គាត់ភ្ជង់កាំភ្លើងពីដីមកខ្ញុំ គាត់ថា "បោះចោលភ្លាម បោះចោល"។ ហើយខ្ញុំញ័រអស់ហើយលោក គ្រាន់តែឮៗគាត់ស្រែកប៉ុណ្ណឹង ហើយកាំភ្លើងភ្ជង់មកអ៊ីចឹង ខ្ញុំញ័រអស់រលីង។ ខ្ញុំចាក់អីវ៉ាន់ភ្លាម ដាក់ចូលក្នុងលាក្រណាត់ក្រមាមួយវេចខ្ចប់ទៅ ហើយខ្ញុំក្រវែងកាបូបហ្នឹងចោលភ្លាមចាស។ ហើយបើយើងមិនធ្វើតាមគាត់ គាត់ដាក់ផ្ទូងមក ស្រេចបណ្តោយ។ ហ្នឹង គាត់គំរាមរញ៉េរញ៉ៃមែនទែនណា ធ្វើម៉េចឲ្យយើងខ្លាចតែម្តង។

[១០:១៣:៤១]

**ស៖** ខ្ញុំចង់ឲ្យមានការបញ្ជាក់ពាក់ព័ន្ធទៅនឹងចម្លើយលោកស្រីកាលពីម្សិលមិញ និយាយអំពីទាហាន លន់ នល់ ពាក់សម្លៀកបំពាក់។ លោកស្រីថា លោកស្រីបានឃើញទិដ្ឋភាពមួយចំនួន ហើយឃើញថាទាហាន លន់ នល់ ត្រូវបានគេចាប់ ហើយចងស្លាបសេក។ តើលោកស្រីអាចបញ្ជាក់បានទេអំពីថាអ្វីដែលលោកស្រីបានឃើញ ហើយនិងប្តីរបស់លោកស្រីបានឃើញ ហើយឬក៏បានមានគេនិយាយប្រាប់ពាក់ព័ន្ធទៅនឹងចំណុចនេះ?

**ឆ៖** ចាស នៅពេលនោះ ខ្ញុំអត់បានឃើញទេ តែបានគ្រួសារ មានគ្រួសារខ្ញុំ និងបងប្អូនខ្ញុំ គេឃើញៗថាចាប់មែន។ អ៊ីចឹងបានខ្ញុំបញ្ជាក់ហើយបញ្ជាក់ទៀតថា ទាហានខ្មែរក្រហមជាសត្រូវចំពោះមុខទាហាន លន់ នល់ អ៊ីចឹងតែម្តងចាស។ ឃើញគ្នាអត់បាន។ គ្រាន់តែឃើញ គ្រាន់តែសង្ស័យមើលទៅជើងឃើញស្នាមពាក់ស្បែកជើងក្រិន ទោះបីអ្នកឯងមិនមែនទាហានក៏ដោយ ឲ្យតែក្រិនជើងអាហ្នឹងពាក់ស្បែកជើងអាមេរិកាំងក្រិនជើងហើយ គឺទាហានហើយ គឺដឹងតែចាប់យកទៅតែម្តងចាស។ អត់ទុកទេ ឲ្យតែថាទាហាន។

[១០:១៥:០០]

**ស៖** កាលម្សិលមិញលោកស្រីបានផ្តល់ឧទាហរណ៍អំពីវរសេនីយ៍ឯកមួយ ដែលជាសមាជិករបស់គ្រួសារលោកស្រី ហើយដែលគេយករឃើញថាជាយោធា ហើយបើតាមចម្លើយរបស់លោកស្រីនោះគឺថា គាត់ត្រឡប់មកភ្នំពេញវិញដើម្បីធ្វើការ។ តើលោកស្រីដឹងទេថា មានអ្វីកើតឡើងចំពោះលោកស័ក្តិប្រាំនោះ នៅពេលដែលគាត់ត្រឡប់ចូលភ្នំពេញវិញនោះ?

**ឆ៖** នៅពេលនោះ ខ្មែរក្រហមអត់ដឹងថា បងថ្លៃខ្ញុំពាក់សក្តិប្រាំទេ។ ពេលដែលគាត់ចេញពីភ្នំពេញទៅ គាត់ទៅសំណាក់នៅព្រែកឯង។ ប៉ុន្តែគេហៅ គេប្រកាសមីក្រូតែម្តង គេប្រកាសដើររកថា អ្នកណាដែលធ្លាប់ធ្វើទាហានមានបណ្តាសក្តិ អញ្ជើញចូលមកទីក្រុងភ្នំពេញវិញ ដើម្បីធ្វើការងារបន្ត។ ហើយមនុស្សវាមានមហិច្ឆតាបន្តិចហើយចាស។ វាមិនមែនចង់ចេញពីផ្ទះទៅ ដើរវេទនាតាមផ្លូវ ទៅដេកហាលមូស ហាលខ្យល់តាមចិញ្ចើមថ្នល់ឯណា។ គ្រាន់តែឮថា គេប្រកាសអ៊ីចឹងភ្លាម គឺគាត់រៀបឥវ៉ាន់ ឲ្យប្រពន្ធរៀបអីវ៉ាន់ចូលមកទីក្រុងភ្នំពេញវិញ។ តែតាំងពីចូលមករហូតដល់ រហូតថាដល់ទៅនៅខ្សាច់កណ្តាល ទៅនៅឯណា គឺបាត់រហូត បានសន្មតថា អូ៎! យកទៅសម្លាប់ចោលអស់ហើយ ចប់ហើយ ចាញ់បោកខ្មែរក្រហមហើយចាស។

[១០:១៦:២៥]

**ស៖** សូមអរគុណ។ កាលពីម្សិលមិញក៏លោកស្រីបានឆ្លើយថា នៅពេលចាកចេញពីភ្នំពេញនៅក្នុងសង្កាត់របស់លោកស្រី ឬក៏សង្កាត់ជាប់ៗនោះ លោកស្រីឃើញមានសាកសព ហើយប្តីរបស់លោកស្រីក៏ឃើញសាកសពដែរនៅក្នុង -- នៅតាមផ្លូវ។ ខ្ញុំចង់ដឹងថាសាកសពដែលលោកស្រី ឬក៏ប្តីរបស់លោកស្រីឃើញនេះជាសាកសពដែលមានឯកសណ្ឋានជាជនស៊ីវិល ឬក៏យោធា។

**ឆ៖** ចាស សាកសពដែលខ្ញុំឃើញនៅឃុំព្រែកប្រា ហ្នឹងមានឯកសណ្ឋានជាស៊ីវិល។ ចាស ព្រោះខ្ញុំឃើញក្មេងក្នុងអង្រឹងហ្នឹង ខ្ញុំឃើញផ្ទាល់ម្តង ក្មេងដែលស្លាប់នៅក្នុងអង្រឹងផ្ទាល់ភ្នែក។ អ៊ីចឹងបានសេចក្តីថា មិនចាំបាច់យោធាទេ។ ប្រជាពលរដ្ឋដឹងរឹងទទឹងរឿងអី ក៏គេសម្លាប់ចោលដែរចាស។

**ស៖** តើលោកស្រីមានឃើញសាកសពផ្សេងទៀតទេមុនទៅដល់ឃុំព្រែកប្រានោះ ខ្ញុំចង់សំដៅដល់នៅក្នុងទីក្រុងភ្នំពេញ ពេលដែលចាកចេញហ្នឹង។ មានឃើញសាកសពទេមុនទៅដល់ព្រែកប្រាហ្នឹង?

**ឆ៖** ចាស នៅតាមផ្លូវហ្នឹង ខ្ញុំឃើញដែរ ប៉ុន្តែតិចតាច ខ្ញុំឃើញមួយពីរទេចាស។ ឃើញដេកច្រងាងស្លាប់ហ្នឹង។ ខ្ញុំដោយសារឃើញហ្នឹងហើយ ទើបខ្ញុំដឹងថា “អូ៎!អត់បានទេ ខ្មែរក្រហមត្រូវសម្លាប់

សម្លាប់ឆៅអ៊ីចឹងម្តង។ អត់មានគិតថា មុខប្រជាពលរដ្ឋត្រូវលាក់ការណ៍អីអត់ទេ”។ អ៊ីចឹងខ្ញុំត្រូវតែខ្លាច ព្រោះខ្ញុំឃើញផ្ទាល់។

[១០:១៨:២២]

**ស៖** លោកស្រីបានឃើញសាកសពខ្លះៗនៅតាមផ្លូវ តើជាសាកសពទាំងអស់នោះជាទាហាន ពាក់ឯកសណ្ឋានជាទាហាន ឬក៏ជនស៊ីវិលទេ?

**ឆ៖** ដែលតាមផ្លូវខ្ញុំឃើញហ្នឹងជាស៊ីវិលទេ ចាស។

**ស៖** កាលពីម្សិលមិញលោកស្រីបានឆ្លើយថា មានរបាំងជាច្រើននៅតាមផ្លូវ ហើយលោកស្រីថា នៅកន្លែងមួយនោះ គឺលោកស្រីមិនអាចថយ ឬក៏មិនអាចទៅមុខទេ។ តើលោកស្រីអាចបញ្ជាក់ទេថា មានប៉ុស្តិ៍យាមផ្សេងៗទៀតនៅតាមផ្លូវ ដែលមានទាហានខ្មែរក្រហមនៅយាមនោះ?

**ឆ៖** ចាស នៅតាមប៉ុស្តិ៍ហ្នឹង គេដាក់បារ៉ាស់ អត់ឲ្យយើងធ្វើដំណើរទៅមុខទៀតទេ។ គឺអត់ឲ្យផ្លងកាត់ទៅទេ គេយាមនៅទីនោះចាស។ រួចហើយ ខ្ញុំព្យាយាមរត់ ខ្ញុំព្យាយាមរត់ពីកន្លែងហ្នឹង ដើម្បីទៅជួបឪពុកម្តាយខ្ញុំនៅភូមិអញ្ចែងលើ ស្រុកខ្សាច់កណ្តាលហ្នឹងចាស។ ពិតជាឃើញមែន បារ៉ាសហ្នឹង ទាហាន យោធាហ្នឹង។

[១០:១៩:៣៩]

**ស៖** នៅកន្លែងប៉ុស្តិ៍យាមមួយចំនួននោះ តើលោកស្រីមានឃើញខ្មែរក្រហមរឹបអូសយកសម្ភារៈ របស់អ្នកជម្លៀសទេ?

**ឆ៖** ចាស អត់ឃើញមានរឹបអូសអីទេ ចាស។ អ្នកណាស្ពាយអី យកអីទៅ លើកលែងតែ -- កុំឲ្យរបស់ទាហានតែម្តង។ របស់ទាហាន គាត់អត់យក ទុកភ្លង់ហើយក្រវែងចោល។

**ស៖** លោកស្រីបាននិយាយថា មានការបែងចែករវាងប្រជាជន១៧មេសា និងប្រជាជនមូលដ្ឋាន តើចាប់ពីពេលណាដែរ ដែលលោកស្រីបានស្តាប់ឮថាគេប្រាប់ថា “ប្រជាជន១៧មេសា” នោះ គឺចាប់តាំងពីពេលនៅតាមផ្លូវដែលលោកស្រីទៅដល់ភូមិនុំង ឬក៏នៅពេលក្រោយមកទេ?

**ឆ៖** គឺចាប់តាំងពីខ្ញុំចេញដំណើរទៅដល់ភូមិស្វាយបន្ទាល ឃុំស្វាយបន្ទាល ស្រុកស្អាង ព្រោះខ្ញុំសំណាក់នៅទីនោះ២អាទិត្យ។ ខ្ញុំបានចូលទៅទាក់ទងជាមួយនឹងប្រជាជន គេហៅខ្លួនគេថា “ខ្ញុំអ្នកមូលដ្ឋាន” ហ្នឹងអ្ហែង -- នាងឯងហ្នឹងអ្នក ១៧មេសា ទើបជម្លៀសចេញមកអី? ចាស ខ្ញុំដឹងតាំងពីពេលនុំងមកចាស។

**ស៖** សូមអរគុណ។ ឥឡូវ ខ្ញុំត្រឡប់មកនិយាយអំពីការចាកចេញពីផ្សារកណ្តាល នៅពេលមេភូមិបានប្រាប់ឲ្យលោកស្រីរៀបចំអីវ៉ាន់ ដើម្បីចាកចេញទៅបាត់ដំបង។

**អ្នកបកប្រែ៖**

បាទ សូមទោស គឺមិនមែនផ្សារកណ្តាលទេ គឺខ្សាច់កណ្តាល។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** នៅពេលដែលឈ្មោះ ប៉ាត់ មេភូមិបានប្រាប់ឲ្យលោកស្រីរៀបចំអីវ៉ាន់? តើការប្រាប់ហ្នឹងគឺជាបញ្ជាតែម្តង ឬក៏លោកស្រីអាចជំទាស់ទៅនឹងការវិធានការដែលគេប្រាប់ឲ្យចេញនេះ?

**លោកស្រី ឡាយ បូនី៖**

**ឆ៖** គឺជាបញ្ជាតែម្តងចាស ហើយសមនឹងចិត្តយើងគិតថា ទៅបាត់ដំបងសម្បូរហូប មានស្រូវមានអង្ករ ព្រោះប្រទេសកម្ពុជាយើងជង្រុកស្រូវធំបំផុត គឺខេត្តបាត់ដំបង។ ដល់អ៊ីចឹងសមគេមកប្រាប់អ៊ីចឹងផង យើងអបអរសាទរហើយ គឺអត់មានគំនិតប្រឆាំងថាមិនទៅអីទេ គឺត្រូវតែរៀបអីវ៉ាន់ទៅ ដើម្បីរស់ស្រួល។

[១០:២២:៣៤]

**ស៖** នៅពេលជម្លៀសចេញពីភ្នំពេញនោះ ទាហានខ្មែរក្រហមប្រាប់ថា "ចាកចេញតែ៣ ឬ៧ថ្ងៃទេ"។ ក៏ប៉ុន្តែលោកស្រីនៅខ្សាច់កណ្តាលនោះរហូតដល់ជិតមួយឆ្នាំទៀត គេមិនឲ្យលោកស្រីត្រឡប់មកផ្ទះវិញទេ។ នៅពេលដែលមេភូមិប្រាប់ឲ្យទៅបាត់ដំបងនោះ តើលោស្រីមានការសង្ស័យទេពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលគេប្រាប់ថា ឲ្យចេញទៅនុ៎ង?

**ឆ៖** នៅពេលនោះ ខ្ញុំដូចជាអត់មានការសង្ស័យទេ ព្រោះ នៅខ្សាច់កណ្តាលហ្នឹងមេភូមិគាត់បានប្រាប់ដែរថា ឲ្យទៅៗ នៅនោះសម្បូរហូប សម្បូរអីអ៊ីចឹង ព្រោះឯណេះគ្រួសារវាកើតឡើងច្រើនកើតកូនមកច្រើនអ៊ីចឹង គេមិនអាចទទួលចិញ្ចឹមដូចថា ដីស្រែ ផលចម្ការដែលមានមិនបាច់ -- មិនអាចទ្រាំទ្រនឹងគ្រួសារថ្មីបានទៀតទេ។ អ៊ីចឹងត្រូវតែទៅ គេប្រាប់ដែរចាស គេនិយាយពីរឿងថាមានស្រូវអង្ករអីអ៊ីចឹងចាស។

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរចុងក្រោយមួយដែលជាសំណួរសុំការបំភ្លឺ។ លោកស្រីបានឆ្លើយថា "អ្នកដែលចេញពីខ្សាច់កណ្តាលទៅ ពោធិ៍សាត់ គឺត្រូវបានគេដឹកតាមមធ្យោបាយផ្សេងៗនោះគឺសុទ្ធតែជាអ្នកជម្លៀស និងអ្នក១៧មេសា"។ លោកស្រីឆ្លើយថា "ប្រហែលជាមាន ២០០នាក់"។ តើ

អ្នកទាំង២០០នុំង នៅសហករណ៍នៅពោធិ៍សាត់ ឬក៏មានអ្នកណាខ្លះទៅដល់ពោធិ៍សាត់ហើយ ធ្វើដំណើរបន្តទៅបាត់ដំបងទៀត?

[១០:២៤:១៩]

**ឆ៖** ពេលនោះ ខ្ញុំអត់បានដឹងទេ ខ្ញុំដឹងតែទៅត្រឹមសហករណ៍កោះជុំ ខ្ញុំលែងដឹងរឿងអ្នកដទៃទៀតហើយ ក្រៅពីអ្នកភូមិកោះជុំ និងគ្រួសារខ្ញុំចាស។

**ស៖** សូមអរគុណលោកស្រី។ សំណួរចុងក្រោយ នៅពេលទៅដល់សហករណ៍កោះជុំ នៅកន្លែងនោះ តើគេមានសួរចម្លើយលោកស្រីពាក់ព័ន្ធទៅនឹងខ្សែជីវិត ឬក៏អតីតកាលរបស់លោកស្រី? ហើយតើលោកស្រីត្រូវសរសេរប្រវត្តិរូបអ្វីទេ?

**ឆ៖** ចាស គេអត់បានសួរអីទេ គ្រាន់តែថា គេចែកក្រុម ចែកកងហើយ គេគ្រាន់តែសួរពីដើមនៅភ្នំពេញ រកស៊ីអី ធ្វើការអី តែប៉ុណ្ណឹងចាស។ គេអត់មានឱ្យសរសេរជាប្រវត្តិរូប ជាអីអត់ទេ ចាស។

**ស៖** ហើយដូចដែលលោកស្រីធ្លាប់ធ្វើពីមុននោះ គឺថាលោកស្រីឆ្លើយថា "ប្តីរបស់លោកស្រីហ្នឹង ជាអ្នកបើកឡានតាក់ស៊ី"។ តើអ៊ីចឹងទេ ដូចពីមុនៗដែរ?

**ឆ៖** ចាស ខ្ញុំឆ្លើយប្រាប់គេថា ប្តីខ្ញុំរត់ឡាំប្រ៊ីតា។

[១០:២៥:៥៧]

**លោក វាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

សូមអរគុណលោកស្រី ដើមបណ្តឹងរដ្ឋប្បវេណីដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ ហើយសហការីរបស់ខ្ញុំ ក៏ចង់សួរសំណួរមួយចំនួនដែរ មុនពេលឈប់សម្រាកបន្តិចទៀតនេះ។ សូមអរគុណលោកស្រី។

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** សួស្តីលោក -- សូមជម្រាបសួរអ្នកស្រី ខ្ញុំសូមអនុញ្ញាតសួរសំណួរបន្តិចបន្ថែមទៅលើសំណួររបស់សហការីខ្ញុំដែលបានសួរ។ គឺសំណួររបស់ខ្ញុំមិនមានច្រើន ដោយសារតែសំណួររបស់ខ្ញុំដែលបានសួរនេះ មានលក្ខណៈក្បោះក្បាយរួចហើយ។ សូមលោកស្រីជួយឆ្លើយបំភ្លឺបន្ថែមទៅលើអ្វីដែលលោកស្រីបានឆ្លើយកាលពីម្សិលមិញ និងថ្ងៃនេះ។ ខ្ញុំចង់ដឹងបន្ថែមថា នៅពេលដែលគេជម្លៀស

ប្រជាជនចេញពីភ្នំពេញ តើក្នុងកាលៈទេសៈនោះ មានប្រជាជនណា ឬក៏មានគ្រួសារណា ដែលអាចតវ៉ាសុំមិនចាកចេញពីទីក្រុងភ្នំពេញបានដែរឬទេ? តើមានជម្រើសនៅក្នុងការសុំមិនចាកចេញបានដែរឬទេ?

[១០:២៦:៥៩]

**លោកស្រី ឡាយ បូនី៖**

**ឆ៖** ចាស នៅពេលនោះ ខ្ញុំអត់បានដឹងទេចាស។ ព្រោះខ្ញុំអត់បានគិតទៅរឿងគេ គិតតែក្នុងគ្រួសារឯង គេឲ្យចេញ គឺចេញចាស។ ដល់អ៊ីចឹង អត់បានដឹងថា គ្រួសារណាមិនចេញ បាន ឬអត់អី។ ខ្ញុំអត់បានដឹងទេចាស។

**ស៖** សូមអរគុណ។ នៅពេលដែលមានការចាប់ខ្លួនប្រជាជន ក៏ដូចជាទាហានរបស់អតីតរបបលន់ នល់ តើការចាប់ខ្លួនមានចំពោះប្រជាជនទូទៅ ដែលជាអ្នករកស៊ីដែរឬទេ? តើការចាប់ខ្លួនមានលក្ខណៈជាទូទៅ ឬក៏មានការរើសអើងចំពោះបុគ្គលមួយចំនួន?

**ឆ៖** បើតាមខ្ញុំដឹង ចាស ឲ្យតែទាហានលន់ នល់ គឺចាប់តែទាំងអស់ ឲ្យតែវាដឹកពិតប្រាកដ។ ជួនកាលមិនច្បាស់ផង គ្រាន់តែឮគេថា ក៏ចាប់ដែរ ឲ្យតែថាឈ្មោះជាទាហាន។

**ស៖** អរគុណ។ ចុះប្រជាជនទូទៅ ដូចជាស៊ីវិល ខាងអ្នករកស៊ីអី តើមានការចាប់ខ្លាំង ដូចជាទាហានលន់ នល់ ដែរឬទេបាទ?

[១០:២៨:១០]

**ឆ៖** ខ្ញុំដឹងរឿងហ្នឹង ខ្ញុំសូមនិយាយតទៅមុខបន្តិចសិនចុះ។ ចាស ដូចជារៀងចាកប្រធានបន្តិច។ ចាស ខ្ញុំដឹងថា ជាមួយនឹងប្រជាជនទូទៅហ្នឹង ពេលដែលខ្ញុំទៅជាប់នឹងមន្ទីរខាងកសាងខ្លួន បានខ្ញុំដឹងថា មិនមែនត្រឹមតែទាហានទេ គឺប្រជាជនទូទៅ។ ឲ្យតែគេចោទថា ជាសក្តិភូមិ ជានាយទុនជាថៅកែ ជាអ្នកលក់មាសផ្សារថ្មី ផ្សារកណ្តាល មានអស់ហើយ ចាស នៅមន្ទីរឃុំឃាំងថ្កោល ដែលខ្ញុំរស់នៅប៉ុន្មានឆ្នាំហ្នឹង ស្គាល់ទាំងអស់ អ្នកនេះ មកពីនេះ នេះមកពីនោះ មុខងារជាស្អីៗ យើងដឹងទាំងអស់ ម៉ែឪគេយកទៅសម្លាប់ នៅសល់កូន ចាស។

**ស៖** សូមអរគុណ។ សំណួរមួយទៀត សូមសួរលោកស្រីថា មុនពេលដែលមានការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ តើមានការផ្សព្វផ្សាយព័ត៌មានតាមវិទ្យុ ឬក៏ព័ត៌មានដោយការនិយាយតៗគ្នាក្នុងស្ថានភាពបែបណាខ្លះ ទាក់ទិននឹងការជម្លៀសហ្នឹងដែរឬទេ? តើមានអាចមានដឹងសញ្ញាណជាមុនដែរឬទេ អំពីការជម្លៀសនេះ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងសញ្ញាណជាមុនថា នឹងរៀបចំមានការជម្លៀស មានការអី អត់ទេ ស្រាប់តែគេមកថាជម្លៀសខ្លាចអាមេរិកាំងទម្លាក់គ្រាប់បែកហ្នឹង ព្រឹបៗ រៀបចំអីវ៉ាន់ភ្លាមតែម្តងចាស។

**ស៖** បាទ សូមអរគុណ។ ទាក់ទិននឹងការដែលលោកស្រីរស់នៅក្នុងតំបន់ដែលលោកស្រីត្រូវបានគេជម្លៀសទៅដល់។ ខ្ញុំបានឮអ្នកស្រីបានបញ្ជាក់ថា មានការប្រជុំស្វ័យទិតៀន។ តើការប្រជុំស្វ័យទិតៀននេះ មានន័យដូចម្តេច? ហើយការប្រជុំនេះប្រព្រឹត្តទៅ ដោយអ្នកណាជាអ្នកដឹកនាំអង្គប្រជុំនោះ?

[១០:២៩:៥៦]

**ឆ៖** ការប្រជុំស្វ័យទិតៀននេះ គឺដឹកនាំដោយមេកង និងអនុកង។ ប្រជុំកសាងដូចថា អ្នកណាមានកំហុសអី អ្នកនោះឃើញអ្នកនោះធ្វើអីខុសៗ យើងនិយាយទៅ ហើយអ្នកដែលធ្វើខុសហ្នឹង បើគេអ្នកមូលដ្ឋានដូចគ្នា គេប៉ិនានតវ៉ាគ្នា។ តែបើចំពោះយើងអ្នកថ្មី ១៧ មេសា ហ្នឹងគឺអត់ប៉ិនានតវ៉ា ហើបមាត់អីទាំងអស់ គឺទទួលទៅតាមការណែនាំរបស់គេ ហើយនិងប្រឹងប្រែងធ្វើទៅសាឡើងវិញ ឲ្យស្រប នឹងមាគ៌ារបស់អង្គការចាស។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលប្រជាជន ឬក៏រូបអ្នកស្រីផ្ទាល់ធ្វើការងារបម្រើអង្គការនៅពេលនោះ ហើយជួបការលំបាកបញ្ហាសុខភាព ដូចជាឈឺ តើមានការអនុញ្ញាតឲ្យប្រជាជនមានការសម្រាកដែរឬទេ?

**ឆ៖** ចាស នៅពេលនោះបើសិនជាជាក់ស្តែង ថា អ្ហ៎! វាកមែន ក្អួតមែន ងើបអត់រួចមែន អាហ្នឹងសម្រាកបាន។ តែបើថាល្មមៗអាចទៅបានហើយ សុខចិត្តទៅ ព្រោះកាលណាទៅៗ ដូចថាគេសម្លឹងសម្លក់យើងអ៊ីចឹង យើងលេបបាយគេអត់រួចទេ គេថ្លែផ្កាថាឲ្យ ឈឺសតិអារម្មណ៍ មើលមកយករបបហូបបាន ហើយអត់ទៅធ្វើការ។ ហើយបើថាដេកនៅនឹងផ្ទះ មានគេទៅយកឲ្យតែម្តង ហ្នឹងបានប៉ិនានឈប់ ចាស។

**ស៖** សូមអរគុណអ្នកស្រី។ សំណួរបន្តទៀត ខ្ញុំសូមសួរលោកស្រីថា តើសហករណ៍ដែលលោកស្រីធ្វើការនោះ គេបង្កើតឡើងនុំង តើគេឲ្យប្រជាជនធ្វើការអ្វីខ្លះនៅក្នុងសហករណ៍នោះ?

[១០:៣១:៣៧]

**ឆ៖** កាលនៅក្នុងសហករណ៍ហ្នឹង ពេលវាដោយ -- ដោយពេលវេលា ដោយរដូវចាស បើរដូវរាំងស្ងួតទៅគេឲ្យយើងជីប្រឡាយ កាប់លើកទំនប់ទប់ សម្រាប់ទប់ទឹកពេលភ្លៀង គេឲ្យកងចម្ការ គេឲ្យទៅកាប់ព្រៃ វាតដីធ្វើចម្ការ។ ចាស ដល់ពេលខែស្ងួងអ៊ីចឹងទៅ គេឲ្យយើងសាប ឲ្យយើងទប់ភ្លឺ ឲ្យស្ទូង

ឲ្យច្រូតអ៊ីចឹងទៅ ទៅតាមរបររបស់កសិករ។

**ស៖** សូមអរគុណលោកស្រី។ សូមលោកស្រីជួយបញ្ជាក់បន្ថែមអំពី មន្ទីរកែប្រែ ឬក៏មន្ទីរសន្តិសុខ ដែលលោកស្រី ក៏ដូចជាស្វាមីរបស់លោកស្រី និងអ្នកដទៃទៀតដែលលោកស្រីបានដឹងឮ ថាគាត់ធ្លាប់បានទទួលនូវការឃុំឃាំងនៅក្នុងមន្ទីរកែប្រែនោះ? ដូចជាមន្ទីរកែប្រែថ្កោល មន្ទីរកែប្រែភាគ និងមន្ទីរកែប្រែដទៃទៀត។ តើពួកខ្មែរក្រហមបានប្រើទារុណកម្ម -- រូបភាពទារុណកម្មបែបណាខ្លះនៅក្នុងសម័យកាលនោះបាទ?

[១០:៣២:៣៩]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក អៀង សារី!

**លោក អាង ឧត្ដម៖**

សូមគោរពលោកប្រធាន (សូមទោស) លោក លោកស្រីចៅក្រម សហព្រះរាជអាជ្ញា សហភាគា និងអស់លោកទាំងឡាយ។

ខ្ញុំសូមជំទាស់នឹងសំណួរនេះ ដោយសារសំណួរនេះទាក់ទងទៅនឹងមន្ទីរសន្តិសុខ ដែលនៅក្នុងដីកា E124 មិនអនុញ្ញាតឲ្យសួរទេ។ សូមអរគុណ។

**លោក ច័ន្ទ តារាស្មី៖**

សូមអនុញ្ញាតបកស្រាយលោកប្រធាន។ តាមពិតគាត់ -- លោកស្រីបានឆ្លើយបញ្ជាក់តាំងពីព្រឹកមិញ រហូតដូចដល់ម្សិលមិញដែរ បានបញ្ជាក់អំពីទីតាំងមន្ទីរសន្តិសុខភាគ និងមន្ទីរទីតាំងមួយចំនួនទៀតដែលលោកស្រីបានបញ្ជាក់ថា ប្ដីរបស់អ្នកស្រី ក៏ដូចជាលោកស្រី ទទួលបានការធ្វើទារុណកម្មនៅនោះ។ អ៊ីចឹងខ្ញុំចង់ឲ្យគាត់ជួយបញ្ជាក់បន្ថែមឲ្យច្បាស់ ថាតើរូបភាពនៃការដែលគាត់ទទួលការធ្វើទុក្ខបុកម្នេញចំពោះគាត់ហ្នឹង មានរូបភាពបែបណាខ្លះ? ពីព្រោះគាត់ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលនេះ។ អ៊ីចឹងគ្រាន់តែការបញ្ជាក់បន្ថែមដើម្បីជូនអង្គសវនាការជ្រាបតែប៉ុណ្ណោះ។ ខ្ញុំមិនបានចង់និយាយអំពីអ្វីដែលមាននៅក្នុងដីកា ដូចលោកមេធាវីការពារក្ដីបានលើកឡើងអម្បាញ់មិញនេះទេ។ សូមអរគុណលោកប្រធាន។

[១០:៣៣:៤៦]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីរបស់មេធាវីជាតិការពារក្តីលោក អៀង សារី ធ្វើឡើងមានមូលដ្ឋានត្រឹមត្រូវជាក់ច្បាស់។ សេចក្តីជំទាស់មានប្រសិទ្ធភាព។ លោកតំណាងសហព្រះរាជអាជ្ញាជាតិមិនគប្បីតាំងសំណួរឲ្យហួសពីក្របខ័ណ្ឌនៃអង្គហេតុ ដែលចោទប្រកាន់នៅក្នុងវិសាលភាពសំណុំរឿង០០២/០១នោះទេ។ អង្គជំនុំជម្រះបានណែនាំរួចហើយ អំពីបច្ច័យដែលកើតឡើងដោយសារការជម្លៀសទី១ និងទី២ គឺភ្លាមៗ បន្ទាប់ពីពេលទៅដល់គោលដៅនៃការជម្លៀស ការសួរបឋម ឆ្លើយជាទូទៅបានធ្វើរួចហើយ។

ចំណែកឯបញ្ហាផលប៉ះពាល់ចំពោះខ្លួនគាត់ គឺគាត់មានសិទ្ធិ អង្គជំនុំជម្រះបានជម្រាបហើយថា សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងផលព្យសនកម្មចំពោះគាត់ គឺគាត់អាចលើកឡើងបាននៅក្នុងក្របខ័ណ្ឌវិសាលសំណុំរឿង០០២ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយយើងទុកនឹងលទ្ធភាពជូនទៅភាគី ដើម្បីធ្វើការកត់សម្គាល់។ យើងបានធ្វើបញ្ហានេះរួចហើយនៅដើមបណ្តឹងរដ្ឋប្បវេណីលើកមុន មិនគប្បីបង្កើតបញ្ហាស្មុគស្មាញបន្តបន្ទាប់ទៀតទេ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** បាទសូមបន្តសំណួរ -- ខ្ញុំមានសំណួរមួយទៀតលោកស្រីចុងក្រោយ ដោយសារពេលវេលាមានគំណត់ ដល់ម៉ោងហើយ។ អ៊ីចឹងខ្ញុំសូមសួរសំណួរលោកស្រីថា ការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញទៅតាមតំបន់នានា តាមខេត្ត លោកស្រីអាចបញ្ជាក់បន្ថែមអំពីការលំបាកដែលលោកស្រី និងក្រុមគ្រួសារ ក៏ដូចជាប្រជាជន ដែលលោកស្រីបានដឹងឮ គេប្រាប់លោកស្រីដោយផ្ទាល់ថា មានការលំបាកអ្វីខ្លះ? តើមានលក្ខណៈខុសគ្នាម៉េចជាមួយនឹងលោកស្រី ឬក៏មានលក្ខណៈដូចគ្នាទាំងស្រុងបាទ? សូមអរគុណ។

[១០:៣៥:៣៦]

**លោកស្រី ឡាយ បូនី៖**

**ឆ៖** ចាសមានការលំបាកដូចគ្នាចំពោះខ្ញុំចាស។ ព្រោះដូចខ្ញុំជម្រាបហើយថា ខ្ញុំជាអ្នកទីក្រុងភ្នំពេញ។ ខ្ញុំកើតក្នុងត្រកូលអ្នកធ្វើការ ដល់ពេលខ្ញុំមិនដែលជួបប្រទះនឹងការលំបាក ហើយជាពិសេសខ្ញុំទើបតែឆ្លងទន្លេសរសៃខ្ចី ដល់ពេលជម្លៀសចេញទៅពេលនោះ ខ្ញុំបាត់បង់អស់បងប្អូន គឺទៅតែប្អូននាក់ម៉ែកូនទៅ។ កូនតូចដល់ទៅពីរ។ ចាស ដល់អ៊ីចឹងទៅការលំបាកគឺកើតមានធ្ងន់ធ្ងរណាស់ចាស។ ហើយ

ជាពិសេសខ្ញុំឆ្លងទន្លេហើយ ខ្ញុំត្រូវជួបការលំបាកឈឺគ្រុនក្តៅរងាររស្រៀវរហូត។ ហើយខ្ញុំមើលទៅគេឯទៀត ក៏ដូចជាខ្ញុំដែរ។ ព្រោះខ្លះទៅឆ្លងទន្លេកណ្តាលផ្លូវ អ្នកខ្លះឈឺដេកលើគ្រែត្រូវរុញដាក់សេរ៉ូមតាមផ្លូវ អ្នកខ្លះត្រូវសែងស្នែង មនុស្សចាស់ដើរអត់រួច ព្រោះមិនដឹងទៅដល់ណា អង្គការ រកអង្គការអត់ឃើញចាស ចេះតែទៅ ឲ្យតែគេថា ទៅមុខ ចេះតែទៅរហូតចាស។ អ៊ីចឹងការលំបាកកើតមានទាំងអស់ចំពោះអ្នកនៅទីក្រុងចាស។ អ្នកជនបទក៏ដូចគ្នាដែរចាស។

[១០:៣៦:៤២]

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណ។ ក្នុងនាមតំណាងភាគីសហព្រះរាជអាជ្ញា សូមថ្លែងអំណរគុណចំពោះលោកស្រី ដែលបានឆ្លើយសំណួរខាងភាគីខ្ញុំ។ ហើយនិងសូមអរគុណចំពោះលោក លោកស្រីចៅក្រម។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សី អ្នកជំនាញដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៧ នាទី ដល់ម៉ោង១១:០៣ នាទី)*

[១១:០៣:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនៃនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុម

មេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមាន។ សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ខ្ញុំឈ្មោះ សុន អរុណ សូមជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមេធាវីការពារលោក នួន ជា។ ខ្ញុំមានសំណួរតិចតួច ហើយនិងបន្ទាប់មកសហការីរបស់ខ្ញុំ គាត់មានសំណួរមិនច្រើនទេ។ ប្រើពេលទាំងពីរនាក់ ប្រើពេលប្រហែលជា១ម៉ោង។

[១១:០៤:៥០]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** សំណួរទី១របស់ខ្ញុំ សូមសួរលោកស្រីដូចតទៅនេះ។ នៅក្នុងឯកសារសួរនិងឆ្លើយ នូវឯកសារលេខ D246/3 ដែលលោកស្រីបានទទួលពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីរួចហើយនោះ។ ខ្ញុំសូមសួរសំណួរទី១ ដូចតទៅនេះ។ ពេលនុ៎ងលោកស្រីបានឆ្លើយ -- ខាងសហចៅក្រមស៊ើបអង្កេតបានសួរលោកស្រីថា “តើអ្នកស្រីបានឃើញការសម្លាប់មនុស្សនៅត្រាចក្រោលឬទេ?” ហើយលោកស្រីបានឆ្លើយទៅប្រាប់វិញ ទៅប្រាប់ចៅក្រមស៊ើបអង្កេតវិញថា “ខ្ញុំបានឃើញ នៅពេលមួយទោស -- នៅពេលមួយអ្នកទោសម្នាក់ត្រូវបានគេយកមករោងបាយសហករណ៍ ហើយខ្មែរក្រហមបានប្រាប់ប្រជាជនដែលមានវត្តមាននៅទីនោះថា បុរសនោះព្យាយាមរត់គេចខ្លួន។ បន្ទាប់ពីទាហានខ្មែរក្រហមនិយាយរួច ពួកគេបានកាត់ក្បាលអ្នកទោសនោះ។ នៅពេលនោះ ខ្ញុំមិនបានឃើញ -- ឃើញពួកគេកាត់ក្បាលអ្នកទោសទេ ប៉ុន្តែខ្ញុំបានឃើញក្បាលអ្នកទោសធ្លាក់នៅលើដី”។

[១១:០៦:២៨]

ចម្លើយរបស់អ្នកស្រីនេះ ខ្ញុំនៅមិនអស់ចិត្ត ខ្ញុំចង់សួរថា ពាក្យសម្តីលោកស្រីឆ្លើយថា “ប៉ុន្តែខ្ញុំបានឃើញក្បាលអ្នកទោសធ្លាក់នៅលើដី” ពេលនុ៎ងលោកស្រីបានឃើញកាត់ក្បាល ហើយធ្លាក់ ពេលធ្លាក់នៅលើដី មានន័យថាពេលកំពុងធ្លាក់អ៊ីចឹង? ឬក៏មកដល់ដីហើយ លោកស្រីឃើញនៅលើដី?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប។

សូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិ!

**លោកស្រី ម៉ុច សុវណ្ណារី៖**

មិនជំទាស់ទៅនឹងសំណួរនេះទេ ក៏ប៉ុន្តែនាងខ្ញុំសូមលោកប្រធានបង្គាប់ទៅខាងមេធាវីការពារក្តីលោក នួន ជា ដើម្បីផ្តល់នូវលេខយោង ទំព័រយោងនៃសំណួររបស់លោក។ ចាស សូមអរគុណ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ សូមទោស ខ្ញុំមិនបានជម្រាបទៅអង្គសវនាការពីរឿងលេខយោង។ D246/3, ERN ជាខ្មែរ 00372255, អង់គ្លេស 00379163, បារាំង 00422456។

[១១:០៧:៥២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្លាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសង្កេតឃើញថា ក្នុងសំណួរដែលចោទដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសហព្រះរាជអាជ្ញានេះ។ ផ្នែកនេះមិនទាន់បាននិយាយទេ វាមានតែសំណួរពីរបីប៉ុណ្ណោះដែលបានចោទឡើងទាក់ទងនឹងបញ្ហានេះ។ មានចំណុចនេះ ដែលដើមបណ្តឹងរដ្ឋប្បវេណីនិយាយថា ប្តីគាត់ជាអតីតនាយទាហាន ហើយត្រូវបានកំណត់អត្តសញ្ញាណថាជាទាហាន ហើយដោយសារមូលហេតុនេះហើយ បានជាគេចាប់គាត់យកខ្លួន។ នៅចំណុចផ្សេងៗទៀតនោះ មិនមានបានលើកឡើងទេ ពីព្រោះថាយើងកំពុងតែធ្វើការកាត់ក្តីក្នុងសំណុំរឿង០០១/ -- អ៎! ០២/០១។ អ៊ីចឹងមានព័ត៌មានលម្អិតមួយចំនួនគួរឲ្យចាប់អារម្មណ៍ ក៏ប៉ុន្តែមិនពាក់ព័ន្ធទៅនឹងដំណាក់កាលទី១ នៃការជម្រះសេចក្តីយើងនេះនោះទេ។ ដូច្នេះ យើងត្រូវតែកម្រិតសំណួរ ហើយមិនត្រូវសួរឲ្យហួសពីវិសាលភាពនោះទេ។

[១១:០៩:១៣]

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយទៅព្រះរាជអាជ្ញា។ ចម្លើយ -- សំណួររបស់ខ្ញុំនេះនៅក្នុងឯកសារដែលមាន ដែលសួរ-ឆ្លើយ រវាងចៅក្រមស៊ើបអង្កេត និងដើមបណ្តឹងរដ្ឋប្បវេណី។ ម្ល៉ោះហើយខ្ញុំ សំណួរ-ចម្លើយនេះមានរួចទៅហើយ។ ហើយខ្ញុំគ្រាន់សួរបន្ថែម ដើម្បីបំភ្លឺឲ្យច្បាស់ ដើម្បីជូនអង្គសវនាការតែប៉ុណ្ណោះ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយមេធាវីការពារក្តីលោក នួន ជា ដែលបានសួរលោកស្រីអម្បាញ់មិញនេះ។

**លោកស្រី ឡាយ បូនី៖**

**ឆ៖** ចាស សូមអរគុណចាស។ នៅក្នុងត្រាចក្រោល គឺជាកន្លែងកសាងខ្លួនចុងក្រោយបង្អស់ដែលនាងខ្ញុំបានទៅជាប់នៅទីនោះចាស។ គឺជាទម្លាប់ ឱ្យតែពេលណាមានអ្នករត់ អ្នករត់ព្យាយាមចេញពីគុក គឺថាគេត្រូវធ្វើមីទ្ទិង គេចាប់បានមនុស្សនោះមក គឺគេធ្វើមីទ្ទិង ហើយមីទ្ទិងហ្នឹងគឺព្រលឹមឡើងយើងទៅធ្វើការ។ ថ្ងៃត្រង់ពេលបាយយើងមកមូលគ្នាហូបនៅការដ្ឋាន។ អ៊ីចឹងហូបចប់គេអត់ទាន់ឱ្យទៅកន្លែងទេ គេឱ្យចេញមកអង្គុយតម្រង់ជួរនៅមុខការដ្ឋានបាយហ្នឹង។ តាំងគេយកអ្នកទោសហ្នឹងមកបង្ហាញហើយ គេប្រាប់ថា “អ្នកដែលព្យាយាមលួចរត់អង្គការមិនទុកទេ អង្គការត្រូវតែកម្ទេចចោល”។ ហើយគេក៏លើកនិយាយពីនេះពីនោះអ៊ីចេះ អ៊ីចុះ ហើយពួកខ្ញុំចេះតែខ្សឹបខ្សៀវគ្នាថា អូយ! ពិតជាសម្លាប់ហើយ គេសម្លាប់នៅនឹងហ្នឹងហើយ ដល់អ៊ីចឹងទៅខ្ញុំវាស្លុតណាស់វាអត់ -- វាដូចថា ទៅដល់គុកហ្នឹងដំបូងហ្នឹងគេអ៊ីចឹង។ ខ្ញុំអត់ហ៊ានមើលទេ ចេះតែឈ្ងោកស្តាប់ខ្សឹបគ្នាចុះឡើង។ និយាយចុះភ្លេចខ្លួនស្រាប់តែឮអ្នកស្រែក អ្ហះ! ឃើញក្បាលធ្លាក់ដល់ដីបាត់។ ចាស ពិតជាកាប់អ៊ីចឹងមែន។ ចាស អត់មានថានិយាយក្លែងក្លាយចេះតែថាឱ្យរួចពីមាត់ទេ អត់ទេ។ គឺការសម្លាប់នៅគុកត្រាចក្រោលហ្នឹង គឺមហាវិនាសកម្ម ហើយមហាសម្លាប់។ ទោះបីមិនសម្លាប់ក៏ស្លាប់ដោយស្រួលដែរ ព្រោះដំបូលស័ង្កសីពីរម៉ែត្រអ្នកទៅធ្វើការទៅបាត់ អ្នកដែលទៅធ្វើមិនបានទន់ជ្រាយដើរអត់រួចដេកស្លាប់ដោយសារកម្តៅថ្ងៃ--

[១១:១១:៣៣]

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមកាត់អ្នកស្រីត្រង់នេះ។ ខ្ញុំមិនចង់ឮវែងឆ្ងាយ គ្រាន់ចង់សួរបញ្ជាក់អំពីរឿងអ្នកស្រីបានបញ្ជាក់ថា ខ្ញុំមិន -- នៅពេលនោះ ខ្ញុំមិនបានឃើញពួកគេកាត់ក្បាលអ្នកទោសទេ។ ប៉ុន្តែខ្ញុំបានឃើញក្បាលអ្នកទោសធ្លាក់នៅលើដី។ ខ្ញុំគ្រាន់ចង់បញ្ជាក់ថា ឃើញក្បាលធ្លាក់នៅលើដីពាក្យថា “ធ្លាក់” មួយមាត់បានន័យថា ឃើញតាំងពីកាត់រហូតដល់ដី។ បញ្ជាក់ប៉ុណ្ណឹងទេ តើគាត់ឃើញអ៊ីចឹង ឬក៏ឃើញក្បាលនៅហ្នឹងដីហើយ? អានេះដែលសំណួររបស់ខ្ញុំចង់សួរ។

[១១:១២:១៩]

**ឆ៖** ចាស ខ្ញុំគិតពិតជាឃើញអ៊ីចឹងមែនចាស។ ឃើញតាំងគេស្ទាបចុះ គេគោះក្បាលអីចុះឡើង គ្រាន់ថា ខ្ញុំមិនបានគេអារខ្វាកៗ ខ្ញុំមិនហ៊ានមើលចាស។ ដោយសារខ្ញុំមិនហ៊ានខ្ញុំខ្លាច។

**ស៖** អរគុណអ្នកស្រី។ ខ្ញុំមានសំណួរមួយបន្តទៅទៀត។ នៅទំព័រ នៅលេខ -- ឯកសារលេខដដែល ហើយទំព័រដដែល។ ត្រង់សំណួររបស់ចៅក្រមសួរថា "តើអ្នកស្រីដឹងថា សាកសពទាំងនោះត្រូវបានគេបោះចោលនៅទីណាទេ?" អ្នកស្រីបានឆ្លើយថា "ក្រោយមកទៀតទាហានខ្មែរក្រហមបីបួននាក់ដែលចូលរួមនៅក្នុងការសម្លាប់មនុស្សនោះ បានក្លាយជាអ្នកទោស ហើយពួកគេបានប្រាប់ខ្ញុំថា អ្នកទាំងនោះត្រូវបានគេយកទៅសម្លាប់នៅភាគ -- នៅខាងត្បូងគុកក្ដោល។ ពួកគេបានប្រាប់ខ្ញុំថា ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦ ខ្មែរក្រហមបានសម្លាប់អ្នកទោស ១០ម៉ឺននាក់ នៅ -- ខ្ញុំជឿថាតួលេខនេះ ត្រឹមត្រូវ"។ អ្នកស្រីបានឆ្លើយថា ខ្ញុំជឿថាលេខនេះត្រឹមត្រូវ។ យោងទៅលើរឿងអ្វីបានជាអ្នកស្រីយល់ថាក្នុងរយៈពេល១ឆ្នាំ ឬជិត១ឆ្នាំ ស្លាប់ដល់ ១០ម៉ឺននាក់?

[១១:១៤:០៥]

**ឆ៖** ចាស ត្រង់ចំណុចកន្លែងនេះ គឺថាខ្ញុំបានឆ្លើយថា ខ្ញុំពិតជាជឿជាក់មែនចាស។ ព្រោះរាល់ពេលបីថ្ងៃម្ដង គឺជាថ្ងៃធ្វើការ។ អ៊ីចឹង អត់ពីរថ្ងៃមួយថ្ងៃសម្លាប់ៗ យកទៅម្ដងពី ២០០នាក់ជាង ៣០០នាក់ ១០០នាក់ ជាង១០០នាក់។ ចាស យកទៅសម្លាប់ ហើយមិនមែនខ្ញុំថា អ្ហូ! អីច្រើនម្ល៉េះ អ្ហឺ!មិនមែនទើបនឹងសម្លាប់ត្រឹម ៧៦ហ្នឹងទេ តាំងពី៧៥មក។ អ៊ីចឹងវាអាចលោកគ្រាន់តែបែងទៅ ក្នុង១ឆ្នាំ ៣៦៥ថ្ងៃ ចែកជាបីទៅ ហើយក្នុងចែកជាបីក្នុងមួយថ្ងៃអស់ប៉ុន្មាន? អាហ្នឹងក៏តួលេខហ្នឹងក៏វាប្រហាក់ប្រហែលព្រោះទម្រាំដល់ឆ្នាំ៧៧ ពាក់កណ្ដាលឆ្នាំ៧៧ វាជិត២ឆ្នាំទៅហើយមិនមែនថាជិត ១ឆ្នាំ ឬជាង ១ឆ្នាំទេចាស។ ហើយដែលខ្ញុំជឿជាក់គឺ រាល់ថ្ងៃដែលបញ្ជាពីតំបន់នានា ពីសហករណ៍នានាឡើងមក អ៊ូអែចេចចាចចុះឡើង ប៉ុន្តែបានមកតែ២ថ្ងៃ បានមកតែ៣ថ្ងៃ ឬ១យប់ គឺយកទៅឡើងស្ងាត់អត់ហើយ។ចាស ពិតជាអ៊ីចឹង។ បានខ្ញុំជឿជាក់ថា ពីព្រោះអ្នកហ្នឹងអ្នកដែលមូលដ្ឋានហ្នឹងគាត់ជាយោធា គាត់ធ្លាប់ជាប់គុក អ៎! គាត់ធ្លាប់មើលការខុសត្រូវពេលដែលយកទៅសម្លាប់ គាត់អ្នកបណ្ដើរអ្នកទោសហ្នឹងទៅសម្លាប់ហើយ។ ចាស រួចតាំងដល់ពេលគាត់មកជាប់គុកវិញ គឺគាត់ដឹងរឿងនេះពិតប្រាកដណាស់។ ចាស ទើបគាត់ខ្សឹបប្រាប់ពួកខ្ញុំថា "អ៎ូ មានភាគណាឆ្ងាយនោះ នុ៎ង! មើល៍!" មែន! យប់ឡើងគឺថាក្លិនស្អុយអសោចហើយយើងចេះតែថា មិនដឹងនៅឯណាក្លិនស្អុយណាស់។ អើ! យើងវាមិនសូវតាមដានយកចិត្តទុកដាក់

ផង អារឿងសម្លាប់ ធ្វើម៉េចខំតែកសាងខ្លួនយើងឲ្យបានល្អ ដើម្បីជៀសផុតពីការស្លាប់ហ្នឹងចាស។

[១១:១៦:០៦]

**ស៖** អរគុណ។ ចាប់ពីឆ្នាំ១៩៧៥ រហូតដល់ ឆ្នាំ១៩៧៩ អ្នកស្រីបានទទួលភៀសខ្លួនច្រើនដំណាក់កាលណាស់ បើតាមអ្នកស្រីឆ្លើយនៅក្នុងឯកសារសួរចម្លើយរបស់ចៅក្រមស៊ើបអង្កេតមក។ ចេញពីភ្នំពេញរហូតដល់ពេលដែលទ័ពខ្មែរក្រហមឲ្យលោកស្រីបាននៅកន្លែងណានឹងនរ ហើយក្រោយមកមានផ្លាស់ប្តូរអ្វីទៀត តើលោកស្រីដែលបានឃើញ ឬបានឮសម្តីទ័ពដែលបញ្ជា ឬថ្នាក់លើបញ្ជាមកលោកស្រីឲ្យធ្វើនេះធ្វើនោះផ្ទាល់ទេ? ឬក៏ធ្វើតាម ឧបមាថា គេឲ្យទៅទាំងហ្វូងទៅនេះទៅ អ្នកស្រីឃើញគេទៅៗជាមួយ ឬក៏ឮផ្ទាល់ បញ្ជាផ្ទាល់?

**ឆ៖** ចាស អរគុណ។ ជាច្រើនដំណាក់កាលដែលនាងខ្ញុំជម្លៀសចេញពីភ្នំពេញ នេះគឺថា ភាគច្រើនគឺមិនមែនដោយសារតែចិត្តនាងខ្ញុំចង់ភៀសខ្លួន គឺបញ្ជាពីថ្នាក់លើ។ ដូចជាខ្ញុំភៀសទៅដល់ខ្សាច់កណ្តាល, ពីខ្សាច់កណ្តាលទៅកំពង់ឆ្នាំង, ពីកំពង់ឆ្នាំងទៅពោធិ៍សាត់ ហើយទីបំផុត ខ្ញុំត្រូវជាប់គុកចំនួន ៣ គឺគុកត្រាចក្រោល គុកបឹងខ្នារ និងគុក អ៎! គឺគុកច្រោល គុកបឹងខ្នារ និងគុកត្រាចក្រោល គឺបញ្ជារបស់ថ្នាក់លើ ដឹកនាំថាបញ្ជាឲ្យមេគុកហ្នឹងគឺធ្វើអ៊ីចឹងទាំងអស់ ចាស មិនមែនដោយចិត្តនាងខ្ញុំទេចាស។

[១១:១៨:០៤]

**ស៖** ខ្ញុំសូមបញ្ជាក់សំណួររបស់ខ្ញុំម្តងទៀតថា អ្នកស្រីបានឮបញ្ជាផ្ទាល់មាត់ពីអ្នកបញ្ជា ឬក៏ឮតាមយើង គ្នាយើងដែលនៅជិតៗហ្នឹងថា គេឲ្យទៅហើយ ចេះតែទៅអ៊ីចឹងទៅ ឬក៏ថាយ៉ាងម៉េច?

**ឆ៖** ឮតាមថ្នាក់លើ គឺមេកងនៅក្នុងគុកហ្នឹងដែលគេប្រាប់យើង។ គេប្រាប់យើងឲ្យរៀបធ្វើអីយើងត្រូវតែធ្វើហ្នឹង ព្រោះគេជាយោធា។ ចាស មេកងនៅក្នុងគុកហ្នឹងតែម្តងចាស។

**ស៖** អរគុណ។ លោកស្រីបានមានប្រសាសន៍ជម្រាបតុលាការថាលោកស្រីនៅក្នុងគុក។ គ្រប់ពេលដែលលោកស្រីជម្លៀសហ្នឹង លោកស្រីនៅក្នុងគុករហូត ឬក៏នៅជាផ្ទះធម្មតា ខ្ទមធម្មតា រស់ដោយសុខខ្លួនអ៊ីចឹង ធ្វើការតាមបញ្ជាថ្នាក់លើអ៊ីចឹងទៅ ឬក៏ក្នុងគុកមួយដាក់រួមទាំងអស់គ្នា?

**ឆ៖** ចាស ចាប់ពីពាក់កណ្តាលឆ្នាំ៧៦ ពេលដែលនាងខ្ញុំជម្លៀសដល់ទឹកដីពោធិ៍សាត់ គឺខ្ញុំទៅជាប់គុករហូត។ គុកនោះគឺអត់មាននៅផ្ទះផ្ទាល់ខ្លួនបានទេ គឺនៅរួម។ វ័យកណ្តាលអ៊ីចឹងនៅក្នុងគុកមួយ។ វ័យកណ្តាលប្រុសនៅក្នុងគុកមួយ មានគុកងងឹត គុកធម្មតា។ កុមារនៅផ្សេង កុមារា កុមារី នៅផ្សេង ចាស។ គឺនៅរួមទាំងរយនាក់ រាប់រយនាក់ចាស។

[១១:១៩:៤៦]

**ស៖** អរគុណ។ កាលសម័យលោកស្រីនៅក្នុងគុកហ្នឹង ខាងខ្មែរក្រហមអ្នកដាក់គុកលោកស្រី គេហៅគុកអីចឹងដែរ ឬក៏ហៅយ៉ាងម៉េច កន្លែងលោកស្រីនៅជុំគ្នាហ្នឹង?

**ឆ៖** ចាស នៅពេលនោះ គេមិនហៅគុកទេ គេហៅ មន្ទីរកសាងខ្លួន។ ទាំងបីហ្នឹង មន្ទីរកសាងខ្លួនទាំងអស់ ចាស។

**ស៖** អរគុណ។ ពេលដែលលោកស្រីបានឃើញអ្នកត្រួតត្រាមើលការខុសត្រូវលើប្រជាជននៅក្រុមរបស់លោកស្រីហ្នឹង តើក្រុម -- អ្នកបញ្ជាទាំងប៉ុន្មានហ្នឹង គេជា -- គេមានសម្លៀកបំពាក់របៀបណា? ជាទាហាន? ជាយោធា? ឬក៏ប្លែកពីយោធា?

**ឆ៖** ចាស នៅពេលនោះ មានសម្លៀសបំពាក់ប្លែកពីយោធា គេស្លៀកខោអាវខ្មៅ ស្បែកជើងកង់ឡាន ប៉ុន្តែស្ពាយកាំភ្លើង។ ព្រោះពេលបណ្ដើរទៅធ្វើការ ក៏ស្ពាយកាំភ្លើង ពេលហូបបាយក៏ស្ពាយកាំភ្លើង ពេលដេកក៏ស្ពាយកាំភ្លើងដែរចាស។

[១១:២១:១៩]

**ស៖** អរគុណ។ ពេលដែលបញ្ជាឲ្យទៅធ្វើការ ឬក៏បញ្ជាធ្វើអ្វីៗ ភាសាអ្នកបញ្ជាអ្នកទាំងនោះលោកស្រីបានស្ដាប់ច្បាស់ទេ ជាភាសាខ្មែរយើងសុទ្ធសាធ ឬរបៀបកម្ពុជាក្រោម ឬក៏របៀបប្រជា -- នៅទល់ដែនអីយ៉ាងម៉េច? ឬក៏យ៉ាងម៉េច អាហ្នឹង សូមលោកស្រីបញ្ជាក់បន្តិចមក ពីព្រោះអីលោកស្រីបានស្ដាប់ផ្ទាល់?

**ឆ៖** ចាស ពេលដែលបញ្ជាឲ្យទៅធ្វើ គឺចាសម្ដីជាភាសាខ្មែរ។ ចាស បើខ្ញុំស្ដាប់បានភាគច្រើន អ្នកពោធិ៍សាត់ សួរទៅ ចាស។

**ស៖** អរគុណណាស់។ នៅក្នុងឯកសារដដែល សំណួរខ្ញុំមួយទៀត។ អំមិញខ្ញុំបានសួរអ្នកស្រីថា អ្នកស្រីបានជម្លៀសជាហូរហែតាមដំណាក់កាលក្នុងរយៈ៣ឆ្នាំនោះ។ តើអ្នកស្រីដែលបានឃើញ ឬក៏ជួបប្រទះជនបរទេសជាយោធា ជាអ្នកបច្ចេកទេស ឬក៏ជាជនស៊ីវិលធម្មតាទេ?

**ឆ៖** ចាស នៅពេលនោះ ខ្ញុំមិនដែលជួបទេ ចាស។

**ស៖** អរគុណ។ នេះជាចម្លើយ អ៊ំ! នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ នៅក្នុងកំណត់ហេតុលេខ D246/3, ERN ជាខ្មែរ 00373256, ជាអង់គ្លេស 00379164, ជាបារាំង 00422458។ នេះជាសំណួររបស់ចៅក្រមស៊ើបអង្កេតចុងក្រោយបំផុត បើលោកស្រីចង់ដឹង មើលនៅចុងក្រោយបំផុត។

ហ្នឹង សំណួរហ្នឹងសួរៗថា "ជាដើមបណ្ដឹងរដ្ឋ-- សុំទោសៗ *(ឮមិនច្បាស់)* -- សួរថា "ជាដើមបណ្ដឹងក្នុងឋានៈអ្នកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណី តើអ្វីជាការរំពឹងទុករបស់អ្នកស្រី?" អ្នកស្រី -- ពេលនោះអ្នកស្រីបានឆ្លើយថា "ខ្ញុំបានចង់-- សុំទោស! "ខ្ញុំចង់បានយុត្តិធម៌ជនរងគ្រោះគ្មានកំហុស ដែលបានស្លាប់ក្នុងរបបខ្មែរក្រហម។ ខ្ញុំចង់ឲ្យមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទទួលខុសត្រូវ និងដាក់ទោសចំពោះបទល្មើស ដែលពួកគេបានប្រព្រឹត្ត។ ខ្ញុំចង់រកអ្នកដែលគាំទ្រនៅពីខាងក្រោយខ្នង របបខ្មែរក្រហម ទាំងជនបរទេស និងជនកម្ពុជា"។ ខ្ញុំសូមសួរអ្នកស្រីត្រង់ឃ្លាទាំងប៉ុន្មានដែលខ្ញុំបានអាននេះ ថាតើអ្នកស្រី -- ហេតុអ្វីបានជាអ្នកស្រីអំពាវនាវបែបនេះ គឺចង់ឲ្យដាក់ទោសអ្នកនៅពីក្រោយខ្នង ទាំងបរទេស និងកម្ពុជាផង? អ្នកស្រីចង់សំដៅយ៉ាងម៉េច? ចង់មានន័យថាយ៉ាងម៉េច ជនបរទេសផង និងខ្មែរផង?

**ឆ៖** ចាស មានន័យថា ការអនុវត្តបញ្ជានៅក្នុងរបបខ្មែរក្រហមនេះ មិនមែន -- គឺគេធ្វើជាប្រព័ន្ធ មិនមែនថាត្រឹមតែមេកង មេតំបន់ គណៈឃុំហ្នឹងធ្វើបានទេចាស។ អីចឹងវាមានអ្នកដែលទទួលខុសត្រូវជាន់ខ្ពស់នៅពីក្រោយខ្នង ដែលខ្ញុំចង់មានន័យថា មានបរទេសផង ព្រោះខ្ញុំឃើញជំនួយដែលមកដឹកដូចជាឡានដឹកពួកខ្ញុំពីកំពង់ឆ្នាំងមកពោធិ៍សាត់ គឺជាឡានចិន ហើយសម្លៀកបំពាក់នោះមិនមែនសម្លៀកបំពាក់បែបខ្មែរឯណា។ ខ្ញុំឃើញ ដល់តែខ្ញុំឃើញអីចឹង ខ្ញុំមានការសង្ស័យ។ អីចឹងខ្ញុំទាមទារ ធ្វើម៉េចឲ្យតុលាការកំពូលនេះ គឺថាឲ្យតុលាការនេះជួយស្វែងយល់ ហើយធ្វើម៉េចរកឲ្យឃើញ ព្រោះខ្ញុំជឿជាក់ហើយលើតុលាការកូនកាត់នេះ ថាច្បាស់ជាផ្ដល់ភាពយុត្តិធម៌ដល់ខ្មែរទាំងអស់ដែលបានស្លាប់ ដែលបានរងគ្រោះ និងដែលបានឈឺចាប់រហូតមកដល់សព្វថ្ងៃនេះ ចាស។

[១១:២៦:៥៤]

**លោក សុន អរុណ៖**

ខ្ញុំសូមអរគុណ។ ក្នុងនាមខ្ញុំជាមេធាវីរបស់ នួន ជា ដែលបាន -- អ្នកស្រីបានបំភ្លឺច្បាស់លាស់ជូនតុលាការ។ បន្ទាប់ទៅនេះសហភាគរបស់ខ្ញុំនឹងសួរបន្ថែម។ សូមអរគុណ។ សូមអរគុណលោកប្រធាន។

**លោក ហ្សាស្តើ ប៉ៅ៖**

អរុណសួស្ដីលោកប្រធាន លោក លោកស្រីចៅក្រម ភាគីទាំងអស់ សាធារណជននៅក្នុងបន្ទប់សវនាការ។ សួស្ដីលោកស្រី បូនី! សូមអរគុណដែលលោកស្រីមកទីនេះផ្ដល់សក្ខីកម្មជូនយើងខ្ញុំ។ ដូចដែលលោក សុន អរុណ បានបញ្ជាក់ គឺខ្ញុំត្រូវការរយៈពេល៣០នាទី ដើម្បីតាំងសំណួរសួរទៅកាន់

លោកស្រី។

[១១:២៧:៥១]

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** សំណួរទី១ របស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងស្ថានភាពនៅក្នុងក្រុងភ្នំពេញ គឺស្ថានភាពក្នុងក្រុងភ្នំពេញ មុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។ លោកស្រីបានឆ្លើយបញ្ជាក់អំពីរយៈកាល អំឡុងពេល រហូតមកដល់ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ លោកស្រីថាស្ថានភាពនោះ គឺវាវឹកវរណាស់ ហើយលោកស្រីក៏បានឃើញ រៀបរាប់ថា មានមនុស្សហូរចូលមកទីក្រុងភ្នំពេញនេះច្រើន។ តើលោកស្រីនេះបានឃើញមនុស្សនេះចូលមកទីក្រុងភ្នំពេញនេះយ៉ាងច្រើន គឺឃើញដោយផ្ទាល់នៅមុនឆ្នាំ១៩៧៥ ថ្ងៃ១៧ មេសា ឬក៏លោកស្រីដឹងដោយរបៀបណា?

**លោកស្រី ឡាយ បូនី៖**

**ឆ៖** ចាស សូមអរគុណ។ ខ្ញុំឃើញដោយផ្ទាល់ ព្រោះនៅពេលដែលសង្គ្រាមរួមកាន់តែតូចទីក្រុង -- កាន់តែជិតមកដល់ទីក្រុងភ្នំពេញ គឺថាឃើញតែជនភៀសខ្លួន ដឹកជញ្ជូនកូនចៅទ្រព្យសម្បត្តិចូលមករស់នៅទីក្រុងភ្នំពេញ។ ហើយពេលនោះទីក្រុងភ្នំពេញកកកុញមែន។ ឧទាហរណ៍ខ្ញុំលើកជាក់ស្តែង ដូចជាកាំបូឌីយ៉ាណា គេសង់អត់ទាន់ហើយទេ។ ម្ល៉ោះហើយកន្លែងនោះស្ងាត់អត់ទាន់មានមនុស្សនៅទេ ព្រោះនៅរកេតរកូត អត់ទាន់ស្អាតផង។ តែនៅពេលនោះ គឺថាពោរពេញទៅដោយជនភៀសខ្លួនមកសំណាក់នៅលើក្រោមពេញពាសទាំងអស់ ចាស។ ហើយទំនិញពេលនោះក៏ឡើងថ្លៃ អង្ករខ្វះខាតបានជំនួយអាមេរិកាំងមក ចែកឲ្យទាហានៗយកមកលក់ត។ អ៊ីចឹងបានខ្ញុំដឹងៗផ្ទាល់តែម្តង អត់ឮគេថាទេចាស ព្រោះខ្ញុំរស់នៅទីក្រុងភ្នំពេញកណ្តាលក្រុងហ្នឹងតែម្តង។

[១១:២៩:៥៥]

**ស៖** សូមអរគុណ។ លោកស្រីបានរៀបរាប់ផងដែរថា ប្រជាជនស្នាក់នៅជុំវិញសណ្ឋាគារកាំបូឌីយ៉ាណា។ តើលោកស្រីមានឃើញនៅកន្លែងផ្សេងទៀត ដែលមានជនភៀសខ្លួនមកតាំងទីលំនៅនៅដែរឬទេ?

**ឆ៖** ចាស ឃើញនៅគ្រប់កន្លែង។ ប៉ុន្តែគ្រាន់តែខ្ញុំលើកហេតុជាក់ស្តែងកន្លែងហ្នឹងមួយទេចាស។ នៅតាមទីកន្លែងផ្សេងៗ ផ្ទះជួលឡើងថ្លៃ បន្ទប់តូច បន្ទប់តាចអី ជ្រៀតជ្រកគ្រប់បែបយ៉ាងទាំងអស់ច្រកល្ហកឲ្យតែមានដីទំនេរចាស។

**សៈ** តាមលោកស្រីដឹង តើលោកស្រីអាចប្រាប់បានដែរឬទេ ជនភៀសខ្លួនទាំងអស់នេះគឺដេកហាលវាលនៅលើផ្លូវ ឬក៏មានទីសំណាក់អី មានដំបូលអីត្រឹមត្រូវរស់នៅ?

**ឆៈ** ចាស ដូចខ្ញុំជម្រាបអ៊ីចឹងថា ឧបមាផ្ទះយើងធំមួយ ដល់តែពេលអីវ៉ាន់ឡើងថ្លៃ ទំនិញឡើងថ្លៃក៏យើងពិបាករកចំណូលដែរ។ អ៊ីចឹងយើងជ្រៀតខ្លួនយើងទៅនៅកន្លែងខ្លះទៅ សល់បន្ទប់ខ្លះទៅ យើងវ៉ៃជាបន្ទប់នៅក្រោមផ្ទះទំនេរ វ៉ៃជាបន្ទប់ ជ្រៀកជាបន្ទប់ៗអ៊ីចឹងជួលឲ្យជនភៀសខ្លួន។ អាហ្នឹងក៏ជាការរកចំណូលមួយសម្រាប់ម្ចាស់ផ្ទះដែលរស់នៅទីក្រុងភ្នំពេញចាស។ អត់មានគេងហាលវាលទេ មានផ្ទះជួល។ ចាស រួចតាមដីទំនេរអ៊ីចឹងគេសង់ជាផ្ទះតូចៗទៅ សម្រាប់ជួលឲ្យជនភៀសខ្លួនចាស។

[១១:៣១:៤៥]

**សៈ** ដូច្នេះ ជនភៀសខ្លួនមួយចំនួននោះ គឺគាត់មានកន្លែងស្នាក់នៅនៅក្នុងផ្ទះរបស់ប្រជាជននៅក្នុងទីក្រុងភ្នំពេញ។ ក៏ប៉ុន្តែ តើលោកស្រីមានឃើញជនភៀសខ្លួនគាត់ដេកនៅតាមផ្លូវ ហើយគាត់មានបង្វេច កញ្ចោកកញ្ចប់ ហើយដេកតាមផ្លូវដែរឬទេ?

**ឆៈ** ចាស នៅពេលនោះជិតដល់ពេលបែកភ្នំពេញហ្នឹង ខ្ញុំអត់ដែលបានដើរទេ ព្រោះខ្ញុំមានផ្ទៃពោះ។ ហើយខ្ញុំមានកូនតូចទៀត។ ហើយគ្រាប់ផ្លោងធ្លាក់ជុំវិញ។ ជុំវិញម្តុំផ្ទះខ្ញុំមុខវត្តបទុម ពេទ្យឡុងង៉ែត ហ្នឹងគឺសម្បូរគ្រាប់ផ្លោងណាស់។ ដូច្នេះ ខ្ញុំអត់បានដើរចេញក្រៅផ្ទះ ដែលទៅបានឃើញសភាពបែបអស់ទាំងនោះទេចាស។

**សៈ** តាមអ្វីដែលលោកស្រីអាចជម្រាបយើងខ្ញុំ តើជនភៀសខ្លួនដែលចូលមកទីក្រុងភ្នំពេញនេះពួកគាត់ទាំងអស់នុ៎ងមានអាហារគ្រប់គ្រាន់ហូបដែរឬទេ ឬក៏អាហារហ្នឹងពិបាករកសម្រាប់ហូប?

**ឆៈ** ចាស គឺថាអាហារហ្នឹងគឺថាត្រូវតែពិបាកហើយចាស ព្រោះភ្នំពេញទទួលមនុស្សបានប៉ុន្មានហើយឥឡូវភ្នំពេញក្លាយទៅជាទទួលមនុស្សពីរទៅបីភាគទៀត។ អ៊ីចឹងទេ ការផ្គត់ផ្គង់អាហារ ណាមួយធ្វើស្រែអត់បានទៀត អ៊ីចឹងការហូបចុកហ្នឹង គឺត្រូវតែពិបាក។ ជនភៀសខ្លួនហ្នឹង មកដល់ក្រោយហ្នឹងពិបាកការស្នាក់នៅ ពិបាកហូបចុក ពិបាករកទាំងប្រាក់ជួលផ្ទះគេហ្នឹងក៏ពិបាកដែរចាស។

[១១:៣៣:៤៣]

**សៈ** លោកស្រីក៏បានលើកឡើងផងដែរពីម្សិលមិញថា គ្រួសាររបស់លោកស្រី មិនមានបញ្ហាអីជាមួយនឹងអង្ករនោះទេ ដោយសារតែទាហាននោះបានឲ្យអង្ករមកឲ្យគ្រួសារលោកស្រីហ្នឹងបានគ្រប់គ្រាន់។ ខ្ញុំចង់សូមសួរបញ្ជាក់បន្តិចត្រង់នេះ ថាតើរដ្ឋាភិបាលនៅពេលនោះឲ្យអង្ករមកលោកស្រីតែម្តង

ឬក៏ថាផ្តល់ជាថវិកា ជាលុយកាក់មកឲ្យគ្រួសារលោកស្រី ដើម្បីទិញជាអង្ករ?

**ឆ៖** ពេលនោះប្តីខ្ញុំជាទាហាន ម្ល៉ោះហើយមានរបបអង្ករចាស។ គេបើកតាមអង្គភាពរបស់គេចាស។

**ស៖** ហើយកាលពីម្សិលមិញលោកស្រីបានឆ្លើយជូនតុលាការថា គ្រួសារលោកស្រីមានបញ្ហាជាមួយនឹងបញ្ហាចំណីចំណុកផ្សេងៗទៀតក្រៅពីអង្ករនោះ។ ថាតើនិយាយអំពីស្បៀងផ្សេងៗក្រៅពីអង្ករនេះអាចរៀបរាប់ទេ ថាខ្វះខាតអ្វី?

[១១:៣៥:០២]

**ឆ៖** ក្នុងគ្រួសារខ្ញុំហ្នឹង ក៏ដូចជាម្តាយខ្ញុំអត់សូវមានការខ្វះខាតទេ ព្រោះពេលនោះ យើងទិញស្តុក យើងជម្រាបហើយថា ខ្ញុំបានជីកត្រង់សេ ជីកលេណដ្ឋាននៅក្រោមផ្ទះធំមួយ។ ម្ល៉ោះហើយមានស្តុក តាំងពីអង្ករ តាំងពីមី តាំងពីត្រីងៀត ប្រហុកអំបិល។ អ៊ីចឹងបញ្ហាស្បៀងមិនសូវជាចោទទេចំពោះគ្រួសារនាងខ្ញុំទាំងអស់ហ្នឹងចាស។

**ស៖** សំណួរដូចតទៅនេះ គឺនិយាយអំពីប្រជាជននៅទីក្រុងភ្នំពេញដែលមិនមែនជាជនភៀសខ្លួន ហើយក៏មិនមែនជាទាហាន។ ដូច្នេះ ខ្ញុំនិយាយអំពីប្រជាជនទូទៅដែលរស់នៅទីក្រុងភ្នំពេញនាពេលនោះ។ តើលោកស្រីបានឃើញដោយផ្ទាល់ភ្នែកទេ អំពីស្ថានភាពរបស់ប្រជាជនទាំងនុ៎ង? តើគាត់មានបញ្ហាស្បៀងអាហារដែរឬទេ?

**ឆ៖** ចាស ដូចខ្ញុំជម្រាបរួចហើយថា ពិតជាមាន។ ខ្ញុំអត់ឃើញផ្ទាល់នឹងភ្នែកទេ ព្រោះខ្ញុំមានផ្ទៃពោះ ហើយខ្ញុំអត់បានដើររហេតរហូតទេ ខ្ញុំនៅតែលើផ្ទះ។ ចាស មើលកូនតូចៗនៅលើផ្ទះ ខ្ញុំអត់បានដើរតែ ឮតែបងប្អូនថា ឮតែញាតិមិត្តថា ថាជនភៀសខ្លួន គ្នាលំបាកមែនទែន។ ពិបាកផ្ទះនៅ ពិបាកហូបចុក។ មិនដឹងឯណា អីណីទេ។ ចាស ខ្ញុំឮតែប៉ុណ្ណឹងចាស។

[១១:៣៦:៤៦]

**ស៖** តើលោកស្រីដឹងថាប្រជាជនធម្មតាទូទៅនៅក្នុងទីក្រុងភ្នំពេញទទួលបានសេវាថែទាំសុខភាពគ្រប់គ្រាន់ទេ? មានមន្ទីរពេទ្យគ្រប់គ្រាន់ទេ? មានវេជ្ជបណ្ឌិតគ្រប់គ្រាន់ទេ? ហើយមានថ្នាំពេទ្យគ្រប់គ្រាន់ទេ?

**ឆ៖** ចាស នៅពេលនោះ ថាមិនគ្រប់ ថាខ្វះខាត ក៏ដូចជាមិនសូវអីដែរចាស។ ព្រោះមន្ទីរពេទ្យយើងបើកគ្រប់ពេទ្យទាំងអស់ ហើយជនភៀសខ្លួន អ្នកត្រូវគ្រាប់ អ្នកត្រូវអី សែងចូលពេទ្យ មានការ

ព្យាបាលអីធម្មតាអ៊ីចឹងចាស។

**ស៖** តើវាលំបាកដែរទេក្នុងការទៅមន្ទីរពេទ្យទាំងអស់នោះ ដើម្បីទទួលបាននូវការព្យាបាលហ្នឹង?

**ឆ៖** នៅពេលហ្នឹង ខ្ញុំអត់ដឹងទេចាស ព្រោះខ្ញុំអត់ធ្លាប់ចូលពេទ្យផងចាស។ ដល់អ៊ីចឹងខ្ញុំអត់បានឃើញហេតុការណ៍អស់ទាំងនោះចំពោះអ្នកដទៃទៀត ខ្ញុំអត់ដឹងទេចាស។

**ស៖** អរគុណចំពោះចម្លើយនេះលោកស្រី។ លោកស្រីបានឆ្លើយផងដែរថា គេប្រាប់ឲ្យលោកស្រីចាកចេញពីទីក្រុងភ្នំពេញដោយសារថា អាមេរិកាំងអាចនឹងទម្លាក់គ្រប់គឺនៅក្នុងឆ្នាំ១៩៧៥។ លោកស្រីជឿទេថា អាមេរិកាំងអាចនឹងទម្លាក់គ្រប់នៅទីក្រុងភ្នំពេញទេ?

[១១:៣៨:៤៥]

**ឆ៖** នៅពេលនោះ ចាស ខ្ញុំភ័យដែរ ឮថាទម្លាក់គ្រាប់បែក ក៏ខ្ញុំឃើញគ្រាប់ផ្លោងសម្បើមដែរ ផ្លោងក្លួងៗទីលើដំបូលផ្ទះ ហ៍! របួសប៉ុន្មាននាក់? ហ៍! ដឹកទៅពេទ្យហើយ។ អ៊ីចឹងខ្ញុំជឿ។ ចាស ខ្ញុំអាចជឿ ព្រោះខ្ញុំអត់បានគិតអីទេ។ គិតថាឃើញគ្រាប់ផ្លោង ខ្ញុំខ្លាចបាត់ទៅហើយ។ អ៊ីចឹងបើគេថាទម្លាក់គ្រាប់បែក អ៊ូ! ភ័យណាស់ ទៅសិនហើយ។

**ស៖** សូមអរគុណលោកស្រី។ ហើយលោកស្រីក៏បានលើកឡើងផងដែរថា លោកស្រីត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយក្រោយពីធ្វើដំណើរអស់មួយរយៈមក គឺលោកស្រីបានទៅដល់ភូមិអញ្ចែងលើ នៅក្នុងស្រុកខ្សាច់កណ្ដាល។ បាទ សូមទោស ក្រែងលោខ្ញុំអានឈ្មោះទីតាំងមិនបានច្បាស់។ ហើយលោកស្រីបញ្ជាក់ថានៅទីនោះ គឺថាមានចំណីអាហារគ្រប់គ្រាន់។ តើលោកស្រីអាចរៀបរាប់អំពីទីកន្លែងហ្នឹង ហើយនិងចំណីអាហារនេះឲ្យបានក្បោះក្បាយរៀបជូនយើងខ្ញុំបន្តិចបានទេ?

**ឆ៖** នៅឃុំអញ្ចែងលើ ស្រុកខ្សាច់កណ្ដាលនេះ គឺថានាងខ្ញុំហូបប៉ុណ្ណឹងអាចទទួលយកបាន ព្រោះអ៊ីចេះ! គឺវាល់ល្ងាចគេហៅបើកត្រី គេមានទូកដើរពាក់មងហ្នឹង គឺល្ងាចឡើងគេហៅបើកត្រីក្នុងរបបម្នាក់បីខាំអីអ៊ីចឹង ហើយបួននាក់ទៅមួយគីឡូពីរខាំអីអ៊ីចឹងចាស។ ហើយស្រូវអង្ករយើងរកខ្លួនឯង ព្រោះយើងចេញពីភ្នំពេញទៅ យើងមានជាប់ជារបស់របរ សារុង សំពត់ ហូលផាមួង មាសប្រាក់អីអ៊ីចឹង គេឲ្យយើងដើរដូរ។ ចាស ខ្ញុំចុះទៅដូរដល់ទន្លេតូចកំពង់អំពិលអី បានជាអង្ករមកបញ្ឈរទុកនៅក្នុងផ្ទះតែម្ដងចាស។

[១១:៤០:៥៧]

ហើយនៅពេលនោះ យើងអាចដូរជាបន្លែយកមកស្ល យកមកបបរព្រោង បបរគ្រឿងហ្នឹងណា

ដល់អ៊ីចឹង គឺថាវាហូបឆ្អែតទេប៉ុណ្ណឹងចាស។ យើងកុំធៀបនៅ ការរស់នៅទីក្រុងភ្នំពេញ យើងធៀបពេលដែលយើងជម្លៀសខ្លួនទៅនៅជនបទនោះ។ យើងបានហូបប៉ុណ្ណឹងយើងគិតថា វាគ្រប់គ្រាន់សម្រាប់យើងហើយប៉ុណ្ណឹងចាស។

**ស៖** ហើយរយៈពេលបន្តិចក្រោយមក វត្តកោះជុំ ហើយលោកស្រីបាននិយាយថា "គេបានផ្តល់ឱកាសឲ្យលោកស្រីជ្រើសរើសសហករណ៍ណាមួយក៏បានតាមដែលលោកស្រីចង់ទៅវត្តអង្គជុំនុំង។ តើលោកស្រីអាចជម្រាបបន្តិចបានទេ លោកស្រីសម្រេចបានជ្រើសរើសទៅសហករណ៍ណាដែរនៅវត្តអង្គរជុំនុំង -- វត្តកោះជុំហ្នឹងបាទ? សូមកែប្រែ។

[១១:៤២:០៩]

**ឆ៖** នៅវត្តកោះជុំហ្នឹង គឺថាគេទម្លាក់ប្រជាពលរដ្ឋគ្រប់គ្នានៅទីនោះ ហើយរទេះចតនៅពេញក្នុងវត្តហ្នឹងរង់ចាំដឹក។ ហើយអាចដើរសួរគេថា រទេះនេះមកឃុំណា?ៗ ហើយបើយើងពេញចិត្តនឹងទៅយើងឡើងរទេះទៅ រៀបទៅ គេបរជូនយើងទៅហើយ។ ហើយបើយើងអត់ពេញចិត្តទៅទេ យើងអាចសុំសំណាក់នៅត្រឹមតែសហករណ៍កោះជុំហ្នឹងក៏បានដែរចាស។ គេប្រាប់អ៊ីចឹង ហើយខ្ញុំក៏បានជួបអ្នកស្គាល់គ្នាហ្នឹង ស្គាល់ខាងគ្រួសារប្តីខ្ញុំ ព្រោះប្តីខ្ញុំអ្នកពោធិ៍សាត់ ដល់រួចគេថា ហ៎! មិនបាច់ទៅណាទេនៅត្រឹមហ្នឹងហើយ ធ្វើស្រែដូចតែគ្នា ទៅឯណាក៏ដោយអីណាដែរ។ ហើយសមតែខ្ញុំ អើយើងវាមិនធ្លាប់ហាត់នឿយ ដល់ពេលហាត់នឿយអីខ្ជិលណាស់ នៅនឹងក៏នៅ អ្ហឺ! ធ្វើស្រែធ្វើចម្ការនឹងទេទៅចាស។

[១១:៤៣:១០]

**ស៖** ហើយលោកស្រីអាចប្រាប់បានទេថា នៅពេលណាទៅដល់ពេលណា ដែលលោកស្រីស្នាក់នៅកោះជុំនោះ អាចប៉ាន់ប្រមាណពេលវេលាមើល៍ តើអស់រយៈពេលប៉ុន្មានខែដែរ?

**ឆ៖** ខ្ញុំទៅនៅវត្តកោះជុំហ្នឹង ទៅនៅសហករណ៍កោះជុំហ្នឹង ប្រហាក់ប្រហែលខែភ្លៀង ក្រោយចូលឆ្នាំខ្មែរហើយ។ មើល៍ អ៊ូ! ដើម៧៦ ចាស។ ដើម៧៦ ខ្ញុំចេញទៅ ខ្ញុំទៅនៅប្រហែលជាចូលឆ្នាំខ្មែរហើយ ចប់ហើយគេដឹកខ្ញុំយកទៅដាក់មន្ទីរកសាងខ្លួនរហូតហើយហ្នឹងចាស។

**ស៖** លោកស្រីក៏បានបញ្ជាក់ថា នៅពេលដែលលោកស្រីនៅវត្តកោះជុំនោះ លោកស្រីមិនដែលធ្លាប់បានឃើញមនុស្សស្លាប់ដោយសារតែការអត់បាយ អត់ទឹកនោះទេ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស នៅពេលនោះ ខ្ញុំអត់ដែលឃើញមនុស្សណាអត់បាយអត់ទឹកទេ។ ព្រោះទើបតែទៅដល់ ទោះបីរបបក្នុងការដ្ឋានហ្នឹងវាតិចតួចក៏ដោយ ប៉ុន្តែយើងអាចមានសេសសល់ អង្ករបន្តិចបន្តួចពី

ស្រុកខ្សាច់កណ្ដាលទៅ។ អ្នកឯទៀតក៏អ៊ីចឹងដែរចាស ដូចខ្ញុំជម្រាបអ៊ីចឹងថា ដូចបាយជ្រូកយកមកធ្វើបាយមនុស្សយើងវិញ។ មានអាចដោះដូរបានជាមួយនឹងអ្នកដាំបាយជ្រូកជាមួយនឹងអីអ៊ីចឹងទៅចាស។

[១១:៤៥:០៧]

**ស៖** សូមអរគុណលោកស្រី។ ហើយបន្ទាប់មកនៅពេលលោកស្រីត្រឡប់មកទីក្រុងភ្នំពេញរស់នៅទីក្រុងភ្នំពេញនោះ លោកស្រីបានបញ្ជាក់ថាបាត់ផ្ទះសម្បែងរបស់លោកស្រី។ តើលោកស្រីអាចជម្រាបបានទេ តើលោកស្រីបាត់បង់ផ្ទះហ្នឹងដោយរបៀបណាដែរ?

**ឆ៖** ចាស ពេលដែលខ្ញុំចូលមក ប៉ុន្តែខ្ញុំមកឆ្នាំ៨០ហើយ ខ្ញុំឡើងមករស់នៅទីក្រុងភ្នំពេញ រួចពី៧៩ មក ខ្ញុំនៅខេត្តពោធិ៍សាត់ចាស។ ដល់មកដល់ឆ្នាំ៨០នេះ ខ្ញុំទៅមើលផ្ទះខ្ញុំនៅមុខពេទ្យ ឡុង ង៉េត តែម្ដង អត់ឃើញរូបរាងផ្ទះខ្ញុំទេ នៅឃើញតែផ្ទះម្ដាយធំខ្ញុំ ផ្ទះថ្ម មានបី មានបួនបន្ទប់ អាហ្នឹងនៅ ប៉ុន្តែពួកក្រសួងការបរទេសនៅ។ ទល់មុខពេទ្យ ឡុង ង៉េត តែម្ដង។ ហើយអាកន្លែងប្លុកផ្ទះខ្ញុំហ្នឹង ឃើញតែដីៗទទេ។ ចាស ឥឡូវរហូតមកដល់សព្វថ្ងៃគេសង់ផ្ទះទៀតហើយចាស។

**ស៖** តាមដែលខ្ញុំស្ដាប់បាន ផ្ទះរបស់លោកស្រីហ្នឹងត្រូវបានគេរុះរើ ហើយនៅសល់តែដីទទេហ្នឹង គឺនៅទល់មុខ ឬក៏ជិតផ្ទះលោកស្រីសព្វថ្ងៃហ្នឹង ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

ចាំៗក្បាលមីក្រូហ្វូនប្រតិបត្តិការសិនលោកស្រី។

**លោកស្រី ឡាយ បូនី៖**

**ឆ៖** ចាស ខ្ញុំ ព្រោះផ្ទះខ្ញុំកំណើតរបស់ខ្ញុំហ្នឹងនៅទល់មុខពេទ្យ ឡុង ង៉េត។ ហើយផ្ទះខ្ញុំនៅរាល់ថ្ងៃនេះ នៅសង្កាត់ទឹកថ្លា ខណ្ឌឫស្សី -- ខណ្ឌសែនសុខឯណោះនៅឆ្ងាយពីគ្នាណាស់ នោះនៅសង្កាត់លេខ៤។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** បាទ ខ្ញុំស្ដាប់បានហើយ។ លោកស្រីបានបញ្ជាក់ជូនសហចៅក្រមស៊ើបអង្កេតថា នៅពេលលោកស្រីត្រឡប់មកផ្ទះរបស់លោកស្រីវិញ គឺផ្ទះរបស់លោកស្រីត្រូវបានគេប្រើប្រាស់ជាក្រសួងការបរទេស បុគ្គលិកក្រសួងការបរទេសធ្វើការនៅក្នុងផ្ទះរបស់លោកស្រី ថាតើលោកស្រីដឹងដោយរបៀបណា?

[១១:៤៧:៤០]

**ឆ៖** ខ្ញុំដឹងដោយសួរគេ។ ចាស សួរទៅគេថា អ៎! សុទ្ធតែពួកក្រសួងការបរទេសនៅ ធ្វើការនៅក្រសួងការបរទេសនៅអស់ហើយ។ ចាស អាហ្នឹងផ្ទះម្ដាយធំ ខ្ញុំទេ។ ដីខ្ញុំអត់ទេ នៅចំហចោលទេដី។

**ស៖** លោកស្រីដឹងថា បុគ្គលិកក្រសួងការបរទេសដែលរស់នៅផ្ទះលោកស្រីហ្នឹង តើជាជនជាតិកម្ពុជា ឬក៏ជនជាតិវៀតណាម?

**ឆ៖** ចាស--

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី កុំអាលទាល់ឆ្លើយតប។

សូមអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីទទួលសិទ្ធិ!

**លោកស្រី ម៉ុច សុវណ្ណារី៖**

សូមជំទាស់ទៅនឹងមេធាវីការពារក្ដី នួន ជា ដែលសំណួរទាំងអស់នេះគឺវាមិនស្ថិតនៅក្នុងដែនយុត្តាធិការនៅក្នុងការជម្រះក្ដីនៅក្នុងដំណាក់កាលនេះទេ ពីព្រោះគាត់សួរទាក់ទងជាមួយនឹងអ្វីដែលបានកើតឡើងក្រោយឆ្នាំ១៩៨០។ ដូច្នេះ ខ្ញុំសូមជំទាស់ដោយមូលហេតុនេះ។

[១១:៤៩:០១]

**លោក ហ្សាស្តើ ប៉ោ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប ថាវាមានការពាក់ព័ន្ធ ពីព្រោះដើមបណ្ដឹងរដ្ឋប្បវេណីបានសួរទៅពីផ្ទះសម្បែងរបស់គាត់។ រយៈពេល៧៥ ហើយបន្ទាប់មកក្រោយមកសួរអំពីផ្ទះសម្បែងគាត់ នេះបើតាមសក្ខីកម្មដែលគាត់ឆ្លើយ។ មិនបញ្ហាថាតើលោក -- គាត់ទទួលបានផ្ទះសម្បែងមកវិញ ឬក៏អត់នោះទេ។ ហើយហេតុអ្វីបានជាមិនបានផ្ទះមកវិញ ឬក៏យ៉ាងណានោះទេ ក៏ប៉ុន្តែចម្លើយដែលគាត់ឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺថាគាត់មិនបានទទួលផ្ទះរបស់គាត់មកវិញទេ។ ដោយសារថារដ្ឋាភិបាលនៅពេលនោះ នៅឆ្នាំ១៩៧៩ គឺថាមិនបានប្រគល់ផ្ទះសម្បែងនេះ មកឲ្យគាត់វិញនោះទេ។ ដូច្នេះ វាអាចជាភស្តុតាងមួយបង្ហាញឲ្យឃើញថារដ្ឋាភិបាលក្នុងឆ្នាំ១៩៨០ នោះគឺជាអ្នកយកផ្ទះសម្បែងរបស់គាត់ទៅវិញទេ។ ដូច្នេះខ្ញុំយល់ឃើញថា សំណួរនេះគឺមានការពាក់ព័ន្ធលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ លោកស្រីអាចឆ្លើយតបនឹងសំណួរនេះ ប៉ុន្តែលោកស្រីបានបែងចែកច្បាស់លាស់ហើយ

ហើយសូមបញ្ជាក់ច្បាស់លាស់រវាងលំនៅដ្ឋានរបស់លោកស្រីផ្ទាល់ ហើយនិងលំនៅដ្ឋានរបស់ម្តាយធំរបស់លោកស្រី។ គ្រាន់តែបញ្ជាក់ឡើងវិញទៅបានហើយ។ ជៀសវាង លោកមេធាវីទំនងជាគាត់មានការភ័ន្តច្រឡំដោយសារតែចម្លើយរបស់លោកស្រីច្បាស់លាស់ហើយ។ ផ្ទះណាជាផ្ទះរបស់ម្តាយធំរបស់លោកស្រី ហើយផ្ទះណាដែលជាផ្ទះរបស់លោកស្រី?

**លោកស្រី ឡាយ បូនី៖**

**ឆ៖** ចាស ខ្ញុំគ្រាន់តែចង់បញ្ជាក់ម្តងទៀតថា ផ្ទះខ្ញុំដែលជាកំណើតផ្ទះម្តាយខ្ញុំ ផ្ទះខ្ញុំផ្ទាល់ខ្លួនហ្នឹង ត្រូវបានគេរុះបាត់នៅសល់តែដីទទេទេពេលដែលខ្ញុំទៅមើលហ្នឹង។ ហើយដែលនៅហ្នឹង នៅតែផ្ទះម្តាយធំខ្ញុំនៅខាងក្រោយ គឺបុគ្គលិកក្រសួងការបរទេសគេរស់នៅ។ ចាស គ្រាន់សុំបញ្ជាក់ប៉ុណ្ណឹងទេចាស។

**សួរដោយលោក ហ្វាស្តេ ប៉ោ៖**

**ស៖** ដូច្នេះ ចម្លើយរបស់លោកស្រី ឆ្លើយជូនសហចៅក្រមស៊ើបអង្កេតអំពីបញ្ហាផ្ទះសម្បែងនេះគឺមិនត្រឹមត្រូវទេ។ តើខ្ញុំយល់ដូច្នេះត្រឹមត្រូវដែរឬទេ? ឬក៏ដើម្បីបញ្ហាឲ្យវាមានការច្បាស់លាស់ មានតម្លាភាពទៅនឹងអ្វីដែលលោកស្រីឆ្លើយជូនសហចៅក្រមស៊ើបអង្កេតនោះគឺថា ឯកសារដែលខ្ញុំកំពុង នេះនិយាយនេះគឺ ឯកសារ -- ឯកសារលេខ D246/3, ERN ជាភាសាគឺ 00373255, ERN ជាភាសាអង់គ្លេស 00379164 "សំណួរគឺ តើមានអ្វីកើតឡើងចំពោះផ្ទះរបស់អ្នកស្រីនៅក្នុងទីក្រុងភ្នំពេញ? ចម្លើយ៖ ខ្ញុំបាត់បង់ផ្ទះរបស់ខ្ញុំ ខ្ញុំត្រឡប់មកឆ្នាំ១៩៨០ មកភ្នំពេញ ប៉ុន្តែនៅពេលនោះ គឺមន្ត្រីរបស់ក្រសួងការបរទេសរស់នៅផ្ទះរបស់ខ្ញុំ"។ ដូច្នេះ សំណួររបស់ខ្ញុំ គឺជាថ្មីម្តងទៀត។ បាទ ផ្នែកមួយនេះនៃចម្លើយដែលលោក ស្រីឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺថាមិនត្រឹមត្រូវទេ តើអ៊ីចឹងដែរឬទេ?

[១១:៥២:៥៦]

**ឆ៖** ចាស ខ្ញុំមកដល់ហ្នឹង ដល់ថ្ងៃក្រោយមក ខ្ញុំឃើញផ្ទះ ដីហ្នឹងគេសង់ផ្ទះនៅឡើងវិញចាស ហើយខ្ញុំអត់បានថាមកទៅតោងទាមទេ គ្រាន់ថាមកអើតមើលផ្ទះ។ ដល់មកឃើញផ្ទះ ដីទទេ ដល់ថ្ងៃក្រោយទៀតស្រាប់តែឃើញមានគេចាក់ដី ធ្វើផ្ទះអីឡើងវិញ ខ្ញុំក៏អត់ដឹងថាយ៉ាងម៉េចដែរ គ្រាន់ដឹងថាម្តុំហ្នឹង មន្ត្រីរបស់ក្រសួងការបរទេសគេនៅ សូម្បីតែផ្ទះ ឡុង ង៉ែត ដែលនៅទល់មុខខ្ញុំហ្នឹង គឺសុទ្ធតែបុគ្គលិកការបរទេសនៅទាំងអស់ នៅជិតក្រសួងគេធ្វើការអ៊ីចឹងម្តង។ ចាស របប អង្កាល់ហ្នឹងឡើងមកភ្លាម គេថា អ្នកណាធ្វើនៅក្រសួងណានៅជិតហ្នឹង។ ចាស ខ្ញុំគ្រាន់តែដឹងប៉ុណ្ណឹងទេចាស។

**ស៖** អរគុណចំពោះការពន្យល់នេះ។ ខ្ញុំគិតថាវាមានសារៈសំខាន់ ខ្ញុំនឹងសួរម្តងទៀត។ ថាតើត្រឹមត្រូវដែរឬទេ ដែលថាចម្លើយរបស់លោកស្រី ថាមន្ត្រីក្រសួងការបរទេសនៅពេលនោះ គឺកំពុងតែរស់នៅផ្ទះរបស់លោកស្រី តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំៗជម្រាបហើយថា ផ្ទះខ្ញុំហ្នឹងគេរុះបាត់ហើយ ពេលដែលខ្ញុំមកនៅតែដីទទេទេ ប៉ុន្តែខ្ញុំឃើញផ្ទះអ៊ំខ្ញុំទេដែលនៅជាប់គ្នាហ្នឹង គឺគេប្រាប់ថាសុទ្ធតែបុគ្គលិកក្រសួងការបរទេសរស់នៅទាំងអស់ នៅម្តុំហ្នឹង។ ចាស ខ្ញុំគ្រាន់តែបញ្ជាក់ ជម្រាបប៉ុណ្ណឹងចាស ព្រោះដីខ្ញុំ គេរុះផ្ទះបាត់ហើយ។

[១១:៥៤:៥១]

**ស៖** បាទ សូមអរគុណចំពោះការបំភ្លឺនេះ។ ដើម្បីឲ្យខ្ញុំយល់កាន់តែច្បាស់នោះ គឺថាលោកស្រីបានចុះហត្ថលេខាទៅលើកំណត់ហេតុស្តាប់ចម្លើយ ដែលលោកឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយលោកស្រីបានអះអាងអំពីភាពត្រឹមត្រូវ ថាចម្លើយនោះគឺត្រឹមត្រូវ ជូនអង្គជំនុំជម្រះនៅក្នុងថ្ងៃនេះ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំពិតជាបានអះអាងអ៊ីចឹងមែន ចាស ថាចម្លើយនេះគឺខ្ញុំឆ្លើយដោយផ្ទាល់មាត់ខ្លួនខ្ញុំ។

**លោក ហ្វាស្តេី ប៉ោ៖**

សូមអរគុណលោកស្រី ខ្ញុំអស់សំណួរហើយ។ សូមអរគុណ ដែលបានមកឆ្លើយបំភ្លឺជូនតុលាការយើងខ្ញុំ ក៏ដូចជាក្រុមការពារមេធាវីការពារក្តីក្រុម នួន ជា សូមអរគុណច្រើន ដែលលោកស្រីបានជួយឆ្លើយបំភ្លឺ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី លោក អៀងសារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមានសំណួរ។ សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមគោរពតុលាការ សូមគោរពអង្គសវនាការសាជាថ្មី។

សួស្តីអ្នកស្រី ឡាយ បូនី! ខ្ញុំបាទ អាង ឧត្តម ហើយសហភាតារបស់ខ្ញុំគឺ ម៉ៃខល កាណាវាស គឺគាត់ទៅអង្គុយក្រោយហើយ។ យើងខ្ញុំជាសហមេធាវីការពារក្តីលោក អៀង សារី ពេលនេះអត់មានសំណួរសួរលោកទេ -- សួរលោកស្រីទេ។ ប៉ុន្តែយ៉ាងណាក្តីតាងនាមលោក អៀង សារី យើងខ្ញុំសូម

អរគុណលោកស្រីដែលបានឡើងមកផ្តល់សក្ខីកម្មជូនតុលាការក្នុងការស្វែងរកការពិត ហើយសូមលោកស្រីបានសុខសប្បាយពេលត្រឡប់ទៅផ្ទះវិញ។

សូមអរគុណលោកប្រធាន។

[១១:៥៦:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើខ្លួនមានសំណួរ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះទាំងអស់ និងអង្គសវនាការទាំងមូល។ ក្នុងនាមកលោក ខៀវ សំផន យើងខ្ញុំគ្មានសំណួរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយជាចុងក្រោយនេះ ដូចអង្គជំនុំជម្រះបានជម្រាបជូនលោកស្រី ហើយថា លោកស្រីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី គឺលោកស្រីមានសិទ្ធិ អាចថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលកើតមានចំពោះលោកស្រី នៅក្នុងអំឡុងកម្ពុជាប្រជាធិប-តេយ្យ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

**លោកស្រី ឡាយ បូនី៖**

ចាស នាងខ្ញុំសូមអរគុណចាស។ ក្នុងនាមនាងខ្ញុំជាដើមបណ្តឹងរដ្ឋប្បវេណី នាងខ្ញុំមានការសប្បាយរីករាយហើយ។ នេះជាឱកាសមួយដ៏ល្អបំផុត ដែលរយៈពេលជាង៣០ឆ្នាំហើយ ដែលនាងខ្ញុំបានដក់ទុកនូវការឈឺចាប់នៅក្នុងខួក្បាល នៅក្នុងបេះដូង នៅក្នុងខ្លួនខ្ញុំ។ ហើយដោយសារមានតុលាការហ្នឹង ទើបនាងខ្ញុំបានឡើងមកសម្តែងនូវការឈឺចាប់អស់ទាំងនេះចាស។ ចាប់តាំងពីថ្ងៃ១៧ មេសា ឆ្នាំ៧៥ គឺថា ខ្ញុំចាប់ផ្តើមមានទុក្ខរហូត គឺថាទុក្ខនោះទុក្ខធំ ដែលខ្ញុំមិនដែលជួបប្រទះសោះ គឺថាត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញ ចោលផ្ទះសម្បែង ព្រាត់ប្រាសគ្រួសារ ម៉ែឪ បងប្អូន ទាំងកូន ទាំងសសៃខ្ចីទើបតែឆ្លងទន្លេហើយ២០ថ្ងៃ ដែលនាងខ្ញុំមិនដែលជួបប្រទះ ដែលឪពុកម្តាយ ចិញ្ចឹមមកបានល្អ ស្រាប់តែត្រូវ

របបខ្មែរក្រហមនេះ មកបំផ្លាញសេចក្ដីសុខនេះចាស។ វេទនាណាស់ ចេញទៅតាមផ្លូវទាំងឈឺ ទាំងជាជាមួយកូន ជាមួយប្ដី ទីបំផុតទៅស្លាប់កូន ស្លាប់ម្ដងមួយៗ រហូតពេលដែលខ្ញុំជម្លៀសចេញពីភ្នំពេញគឺថា ទុក្ខសោកនេះ ខ្ញុំបានកប់ទុកយូរហើយ នៅពេលនេះខ្ញុំបានមកសម្ដែងនាងខ្ញុំមានសេចក្ដីជ្រះថ្លា និងអរព្រះគុណដល់តុលាការនេះណាស់ចាស។

[១១:៥៩:២៦]

ហើយជាពិសេស ពេលដែលនាងខ្ញុំជម្លៀសគឺថាជម្លៀសនោះ ជម្លៀសហួសហេតុចាស ពីភ្នំពេញមកខ្សាច់កណ្ដាល ពីខ្សាច់កណ្ដាលទៅកំពង់ឆ្នាំង ពីកំពង់ឆ្នាំងទៅពោធិសាត់។ ទីបំផុតទៅរស់នៅសហករណ៍កោះជុំ ធៀបអត់ជាងសត្វធាតុទៅទៀតណ៎ា រហូតដល់សុំគេដូរបាយជ្រូកយកមកហូប។ ទីបំផុត អង្គការសម្រេចចិត្តមិនដឹងជាកាត់ទោសខ្ញុំយ៉ាងម៉េច សម្រេចចិត្តយកខ្ញុំទាំងគ្រួសារ យកទៅដាក់គុក ហើយគុកនោះគឺមហាវិនាសកម្ម ដោយសារមិនមែនត្រឹមតែខ្ញុំទេ សូម្បីតែប្រជាពលរដ្ឋទាំងអស់ ដែលមិនមានទោសពៃរ៍អ្វីសោះនេះ! យកទៅសួរចម្លើយវ៉ៃដកក្រចក ជ្រមុជទឹក ចងកញ្ជួរ ដែលគ្នាអត់មានទោសអីសោះ ហើយថែមទាំងប្រាប់ថា ឲ្យសារភាពឲ្យត្រឹមមក អ្នកឯងធ្វើខុសអីខ្លះ? ហើយចុះបើគ្នាអត់ខុសអីផង ឲ្យសារភាពថាម៉េច បើសារភាពបន្ធូរបន្ថយ បើមិនសារភាពរឹតតែធ្ងន់។ ពេលទៅសួរចម្លើយនៅគុកថ្កោល ត្រឡប់មកវិញគឺថាវារ។ មានស្ត្រីម្នាក់នោះ ប្រាប់ខ្ញុំថា អូនហើយអូន បើបងស្លាប់ទៅល្អជាងនៅរស់ឲ្យគេសួរចម្លើយវ៉ៃ ដកក្រចកបែកឈាមហូររហាម។ អ៊ីចឹងបានថា គឺថាមហាវិនាសកម្មនេះ ដល់តែធ្វើស្រែ ពេលទៅធ្វើការក៏វ៉ៃ ពេលហូបវាយក៏វ៉ៃ ពេលដេកក៏វ៉ៃ។ ហើយមូលហេតុអីបានវ៉ៃ? គេមិនឲ្យយើងហូបបន្លែ ព្រោះគេថា ហូបទៅឈឺបាត់បង់ពលកម្ម ប៉ុន្តែយើងហូបអត់ឆ្អែតព្យាយាមបេះបន្លែមកលាយ ដើម្បីសម្រន់នៅក្រពះ។

[១២:០១:១២]

ហើយដូចការសម្លាប់អ៊ីចឹង ទើសអីក៏សម្លាប់ដែរ។ ងាកទៅមើលនៅក្នុងគុកហ្នឹងពេលដែលខ្ញុំមិនទាន់ចេញទៅសមរភូមិមុខគឺថា ងាកទៅឃើញបែកក្បាល ឃើញបែកភ្នែក ឃើញរយះ នេះហើយច្រវាក់មួយណាក៏ជាប់ច្រវាក់ដែរ ពេលដែលចេញមកធ្វើការលើកច្រវាក់ចងនៅចង្កេះចាស ហើយជាន់ដូចថាខែៗច្រូតអ៊ីចឹង បែនស្រូវអ៊ីចឹងទៅ ជាន់ស្រូវបណ្ដើរ ឲ្យតែប៊ានថា ខ្មេះពីរបីគ្រាប់យកមកញាត់មាត់ ភូស! បែកឈាមរហាម។ អ៊ីចឹងបានថា ខ្ញុំនេះគឺថា វាធ្ងន់ធ្ងរបំផុត គឺថាបើត្រឹមតែអ្នកសហករណ៍វានៅគ្រាន់បើទេ តែជាប់គុកក្រោយមកកសាងខ្លួនបាន។ សម្លាប់ឆ្អែតឆ្អន់ប្រហែល១០ម៉ឺននាក់ហើយ ធ្វើ

ស្រែបានផលល្អ ដីមានជីវជាតិហើយ ប្រគល់ឲ្យអ្នកសហករណ៍ ចាស ប្រគល់ដីឲ្យអ្នកសហករណ៍ទើបបណ្ដើរពួកនាងខ្ញុំហ្នឹង រាប់រយនាក់ហ្នឹងត្រឡប់ទៅធ្វើស្រែនៅបឹងគល់ទៀត។ បឹងគល់ ស្ថិតនៅឃុំបឹងខ្នារ ស្រុក២៣ ដដែលចាស។ ធ្វើស្រែស្ទូងស្រូវបាន ១០០ហិកតា។ ហើយពេលស្ទូងនោះគឺថា ដកសំណាបយប់ យប់ឡើងដកសំណាបដល់ម៉ោងដប់ពីរ។ ដល់ម៉ោងដប់ពីរអី ដល់ម៉ោងដប់មួយ។ ម៉ោងដប់មួយឲ្យចូលកន្លែង, ចូលកន្លែងទម្រាំបានសម្រាកម៉ោងដប់ដប់ពីរៗ។ ម៉ោងបី ត្រូវផ្ដុំកញ្ចែច្រេចឲ្យងើប គឺត្រូវតែងើបមកអង្គុយសំកុកតម្រង់ជួរឲ្យមូលខាំ។ ចាស រដូវនោះជារដូវរងា មានឯណាមានបារទូលសំណាបហ្នឹងហើយ រុំគ្របខ្លួន ចាស។ អ៊ីចឹងមូលខាំរហូតដល់ពេលឃើញអញ្ចាញដៃ មើលទៅភ្លឺស្រាងៗទើបបណ្ដើរឲ្យចេញទៅស្ទូងៗ--

[១២:០២:៥១]

**ប្រធានអង្គជំនុំ៖**

ឈប់ៗ លោកឈប់ៗ លឿនពេក ឲ្យយឺត អ៊ីចឹងបកប្រែអត់ទាន់ទេណា ដើម្បីឲ្យជាប្រយោជន៍សម្រាប់ដំណើរការសវនាការ ហើយនិងភាគីពាក់ព័ន្ធ ព្រោះភាគីដែលចូលរួមនៅក្នុងកិច្ចដំណើរការនេះទាំងចៅក្រមអង្គជំនុំជម្រះ ទាំងអ្នកដែលស្ដាប់នោះគឺ មានជនជាតិបរទេស ដែលយើងត្រូវប្រើប្រាស់ភាសាបារាំង និងភាសាអង់គ្លេសមួយទៀតដែរណ៎ះ ! បន្ធូរៗឲ្យយឺតជាងមុនបន្តិចបាទ។

សូមអញ្ជើញបន្ត បាទ!

កុំអាលឈប់ៗ !

**លោកស្រី ឡាយ បូនី៖**

ចាស នាងខ្ញុំមានការរន្ធត់ពេក ចាសសូមទោស។ ដោយសារ -- ដល់តែពេលភ្លឺស្រាងៗឡើងទើបគេបណ្ដើរយើងចេញទៅធ្វើការ ចាស ហើយហូបចុកខ្វះខាត មួយកំប៉ុងហូបបួនប្រាំនាក់។ ដល់អ៊ីចឹងទៅតើសួរថាតកម្លាំងធ្វើការមានឯណា? អត់មានកម្លាំងធ្វើការទេ ប៉ុន្តែទៅទាំងចិត្ត ទៅទាំងខ្លាចស្លាប់ចាស។ ហើយពេលទៅធ្វើការហ្នឹង ត្រូវទូលសំណាបទៅខ្លួនឯង ហើយបើប៉ានថា ធ្វើជ្រុះធ្វើអី គឺខ្សែតីវ៉ៃដូចគោអ៊ីចឹង ចាសនាងខ្ញុំក៏ធ្លាប់ត្រូវដែរចាស វ៉ៃខ្សែតី ព្រោះពេលគេវ៉ៃហ្នឹង គេមិនមែនគិតថា វ៉ៃអ្នកនេះមួយ អ្នកនោះមួយ គឺគេវាត់យកៗតែម្ដង។ ប៉ះអ្នកណា ត្រូវអ្នកហ្នឹងចាស។

[១២:០៤:៣៤]

ទៅស្ទូងអ៊ីចឹងដែរ ពេលចុះស្ទូង។ យើងស្ទូងទៅមានផែនការរបស់គេ ស្ទូងទៅត្រូវមួយហិកតា

ហ្នឹងស្ទូងប៉ុន្មាននាក់? ត្រូវប៉ុន្មានម៉ោងឲ្យហើយ? ចាស គឺមានកម្រិតផែនការទាំងអស់ ធ្វើការធ្ងន់ មានកម្រិត មានផែនការ តែហូបតិច។ សួរថាយើងទាំងអស់គ្នាទទួលយកបានឬអត់? មិនមែនត្រឹមតែហូបតិចទេ សម្លាប់ស្រួលទៀតចាស។ ក្រោយមក នាងខ្ញុំស្ទូងបាន១០០ហិកតាហើយ ពួកនាងខ្ញុំ -- ប៉ុន្តែខ្ញុំសូមលើកកន្លែងនេះបន្តិចទៀតចាស។ ពេលដែលបណ្តើរទៅនោះ ពីគុកថ្កោលទៅកន្លែងមន្ទីរកសាងខ្លួនបឹងគល់ហ្នឹង គឺថាបាត់មនុស្សច្រើនទៀត ចាស យើងចេះតែដើរទៅតាមថ្នល់រទេះភ្លើង ដល់ទៅដល់ណោះ អ៊ូ! បាត់អ្នកនេះ បាត់អ្នកនោះ។ ពេលនោះអាហ្នឹង ទៅដល់ហ្នឹងពួកនិរតីម្តង អាហ្នឹងបូព៌ាចប់ទៀតហើយ ទៅខាងហ្នឹងពួកនិរតីទទួលម្តងចាស សម្លាប់ហ្នឹងពាយចាស។ ដល់ទៅបឹងខ្នារហ្នឹង នាងខ្ញុំទៅស្ទូងបាន ពួកនាងខ្ញុំស្ទូងបាន១០០ហិកតា។ ១០០ហិកតាហើយ ក៏ប្រគល់ដីហ្នឹងទៅឲ្យអ្នកសហករណ៍ចាស យើងធ្វើបានផលល្អហើយ។ អ៊ីចឹងគេឲ្យដីហ្នឹងទៅឲ្យអ្នកសហករណ៍ គេក៏បណ្តើរពួកខ្ញុំយកទៅគុកបឹងគល់ទៀត។

[១២:០៥:៥១]

ពេលនោះទៅដល់គុកបឹងគល់បានដឹងថា ចំជាពិបាកហើយ ជាកន្លែងចុងក្រោយបង្អស់ ដែលពិបាកជាងគុកថ្កោល ដែលពិបាកគុកបឹងខ្នារទៅទៀតចាស។ អ្នកដែលខុស គឺដាក់ខ្នោះជើង។ ដាក់ខ្នោះជើងហ្នឹងគឺថា អាខ្នោះជើងហ្នឹង ដេកតម្រៀបគ្នាទៅរុញខ្នោះចាស។ ហើយហូបចុក ឲ្យតែហូបស្រួលមិនស្រួលដូចថា មានការធ្វេសប្រហែសអី នាយអាយអ៊ីចឹង គឺវ៉ៃអ៊ីចឹងតែម្តង វ៉ៃបែកឈាមអស់ហើយ។ ចាស ហើយអ្នកដែលជាប់នៅក្នុងបន្ទប់ អ្នកជាប់គុកងងឹត គឺមិនបាច់សម្លាប់ទេ គឺស្លាប់ដោយខ្លួនឯងរដូវប្រាំង ព្រោះក្តៅណាស់ ខែចែត្រ ចាស ដំបូលពីរម៉ែត្រ ហើយគ្មានកម្លាំងទប់ទល់នឹងធាតុក្តៅ ធាតុត្រជាក់អីទេ។ ចាសត្រូវដេកស្លាប់តែម្តង។ ហើយបើយើងទៅធ្វើការ យើងមកអត់រួចទេ គឺមិនបាច់មកដឹងតែស្លាប់នៅហ្នឹងហើយ។ ដឹងតែស្លាប់នៅ ជាដំបូក ជាគល់ឈើ គឺមិន -- គ្មានអ្នកណាគ្រាអ្នកណាមកបានទេចាស ព្រោះម្នាក់ៗយោងតែខ្លួនអត់រួចផង។ ហើយនៅពេល នៅទីនោះ នាងខ្ញុំលើកពីខ្លួននាងខ្ញុំចុះ វាឃ្លានពេក ដូចជាខ្លួង នាងខ្ញុំហូបតែឆៅទេចាស មិនដែលបានស្ងោរឆ្អិននឹងគេទេ ព្រោះបើមានភ្លើងគឺគេវ៉ៃ ហើយឃ្លានណាស់! គឺថាអាការអត់ឃ្លាននេះហើយ ដែលធ្វើឲ្យមនុស្សភ្លេចអស់ហើយសីលធម៌ ភ្លេចអស់ហើយសុជីវធម៌ ចាស ធ្វើអីក៏ដោយឲ្យតែរស់សិន។

នៅគុកបឹង -- នៅគុកត្រាចក្រោលហ្នឹង ក៏ដូចគ្នាចាស។ ព្រលឹមឡើងបណ្តើរទៅធ្វើការកាំភ្លើងច្រូងច្រាងយួរកណ្តាប់ទៅធ្វើការ ថ្ងៃត្រង់មកហូបបាយនៅការដ្ឋានវិញ។ ថ្ងៃហូបបាយហើយ ចេញទៅ

ធ្វើការទៀត ធ្វើការហើយត្រឡប់មកការដ្ឋានវិញហូបបាយទៀត។ យប់ទៅដកសំណាប គឺថាដឹងយ៉ាងម៉េច ខ្ញុំឆ្ងល់របបហ្នឹង ក៏អាក្រក់ម្ល៉េះ! ឱ្យគ្នាធ្វើការយប់ជ្រៅហើយ មិនឱ្យគ្នាសម្រាកឱ្យបាន ថាឥឡូវបើភ្លឺបានទៅស្ទូង អាហ្នឹងឱ្យនៅដល់ភ្លឺទៅ ហេតុអីបានជាផ្ដុំកញ្ចែឱ្យគ្នាមកអង្គុយតម្រង់ជួរ ឱ្យមូសខាំហាលរងា ហាលសន្សើម ហើយសួរថាសុខភាពហ្នឹងវាទៅជាយ៉ាងណាចាស។

[១២:០៨:១៤]

ជាប់យូរក្រោយមកទៀត ចុងក្រោយគេក៏បានជម្លៀសពួកខ្ញុំ នៅក្នុងគុកដដែលហ្នឹង ប៉ុន្តែចុះទៅសហករណ៍ ទៅជួយអ្នកសហករណ៍ ព្រោះពេលនោះទឹកជន់ ទឹកជំនន់ហ្នឹង គេជម្លៀសខ្ញុំឱ្យទៅជួយទប់ទឹកនៅសហករណ៍។ គ្រាន់តែដើរទៅដល់សហករណ៍ អ្នកសហករណ៍ស្រែកថា អឺ! ទុកដាក់អីវ៉ាន់ឱ្យស្រួលបួលវើយ ពួកមន្ទីរកសាងខ្លួនមក ពួកហ្នឹងសុទ្ធតែចោរ។ នៅពេលនោះ ពួកខ្ញុំឈឺចាប់ណាស់ ការឈឺចាប់ហ្នឹង មិនដឹងជាថ្លែងប្រាប់នរណាទេចាស។ ពេលទៅធ្វើការ គេឱ្យយើងនៅក្នុងការដ្ឋានបាយ គេឱ្យយើងសម្រាកក្នុងហ្នឹងពេលយប់ តែព្រលឹមឡើងត្រូវរៀបអីវ៉ាន់ទើរលើដំបូល ទើរលើគេន៎ៃ ហៅដូចពិដានការដ្ឋានបាយហ្នឹង។ អីវ៉ាន់ទើរលើហ្នឹង ដើម្បីថ្ងៃឡើងប្រជាពលរដ្ឋសហករណ៍ហ្នឹង គេហូបបាយក្នុងការដ្ឋានហ្នឹង។ អ៊ីចឹងទេ យើងទើរអីវ៉ាន់ ទើរហើយយើងចេញទៅធ្វើការ។ ធ្វើការនោះគឺថា ទៅជីកដីដើម្បីលើកទំនប់ទប់ទឹកទន្លេ ទប់ទឹកទន្លេសាបចាស។ ហើយអ្នកសហករណ៍ធ្វើការ មានអ្នកសហករណ៍ មានអ្នកមន្ទីរកសាង។ អ្នកសហករណ៍ធ្វើការដីគោក ចាស គេមកធ្វើថ្ងៃបន្តិចបានគេធ្វើ ធ្វើហើយគេមានពេលសម្រាកហូបបាយ។ ដល់តែយើងធ្វើក្នុងទឹក គឺចុចដីទៅក្នុងទឹក ហើយជ្រមុជផើបយកដីហ្នឹងយកដាក់លើទំនប់ដើម្បីទប់ទឹក។ ដល់តែពេលអ្នកសហករណ៍ ម៉ោងបីឡើងគេទូលដំឡូង គេចំហុយដំឡូងឈើ ដំឡូងមីហ្នឹងយកទៅឱ្យហូប ចំណែកយើងអ្នកមន្ទីរកសាងខ្លួនហ្នឹង អត់ទេ ធ្វើរហូតៗ ដល់ពេលយប់ ដល់ពេលចប់ គឺត្រឡប់មកការដ្ឋានបាយគេវិញ បានគេចែកបាយនៅពេលនោះ។ ពេលនោះហើយដែលគេវ៉ៃ មកដល់ព្រលប់ ការដ្ឋានតូចមនុស្សត្រូវស្នាក់នៅវាប់រយនាក់ អ្នកទោស អ៊ីចឹងទេអីវ៉ៃអីវ៉ាន់ទើរនៅលើដំបូលហ្នឹងត្រូវយកទៅវាបាត់ អារបស់អញៗ របស់អញនៅឯណា? ម្ល៉ោះហើយចេចចាចគេថា យើងហ្នឹងអត់សណ្ដាប់ធ្នាប់ គេវ៉ៃយើងនឹងខ្សែតី វាត់ខ្សែរខ្វាច់ចាស។

[១២:១០:៣០]

អ៊ីចឹង បានខ្ញុំគ្រាន់តែចង់ជម្រាបថា ពេលធ្វើការក៏វ៉ៃ ពេលហូបក៏វ៉ៃ ពេលដេកក៏វ៉ៃ គឺថាវ៉ៃទាំងអស់ វ៉ៃរហូតចាស។ រហូតដល់មានពេលមួយនោះ គេឱ្យខ្ញុំ ពួកខ្ញុំហ្នឹងទៅទប់ទឹកទន្លេសាប។ ចាស ជីក

ទប់អីអ៊ីចឹងទៅ ពួកខ្ញុំបន់អស់ហើយ បន់ម៉្ងៃៗឲ្យធ្លាយទំនប់ហ្នឹងទៅលោកអើយ ព្រោះវេទនាម្ល៉េះ។ ដល់តែពេលខ្យល់មកខ្លាំងគេឲ្យ -- គេអត់ឲ្យយើងនៅខាងក្នុងទំនប់ គេឲ្យយើងទៅនៅខាងក្រៅទំនប់ ទៅនៅខាងក្រៅហ្នឹង ព្រោះទឹកទន្លេសាប កាលណាខ្យល់ខ្លាំងគឺរលក ដល់រលកបោកមកឲ្យត្រូវខ្នងយើង។ យើងទៅទប់ឲ្យរលកត្រូវខ្នងយើងវាអត់ធ្លាយទំនប់ហ្នឹងទេ បោកមកចំខ្នងយើងរលកទៅវិញហើយ។ អ៊ីចឹងទេ ពួកខ្ញុំបន់អស់ហើយ ចុះនៅត្រាំ លោកគិតមើលត្រាំតាំងពីព្រឹកដល់ល្ងាច តើវាពិបាកប៉ុនណា វារងារផង វាអត់ឃ្លានផង វានឿយហត់ផងចាស។ ម្ល៉ោះហើយ បន់អស់ហើយ ជីបអូចៗ អូយ! ធ្លាយមកលោក ធ្លាយឲ្យស្រឡះទៅ! មានអី ពេលមួយនោះធ្លាយមែន។ ដល់ធ្លាយទំនប់ អ្នកដែលនៅមុខទឹកហ្នឹងគឺត្រូវស្លាប់ចាស គឺស្លាប់តែម្តង អត់មានសេសសល់ទេចាស។

ហើយលើករឿងមួយទៀត នៅហ្នឹងដែរចាស ពេលដាំដំឡូងកាលណាទឹកចូលមក គេប្រញិបប្រញាប់គាស់ណាស់ ទោះដំឡូងតូចដំឡូងធំក៏ដោយ គេគាស់ហើយ។ ដល់តែយើងនេះ ជាអ្នកទោសនេះវាឃ្លាន។ អ៊ីចឹងក៏បានទៅកាយៗរោងគេចាស់ៗហ្នឹង ខ្វះទៅម៉ោងសម្រាកហ្នឹង ទំនេរទៅរើសដំឡូងហ្នឹង គេចោទយើងថា យើងលួចដំឡូងគេចាស។ នាងខ្ញុំធ្លាប់ជាប់ម្តងដែរ គេយកមកមន្ទីរវិញ ដាក់ខ្នោះជើងទៅចាស។ ក្រោយមកបាន នេះទៅបានមានអ្នកនេះទៅជួយទៅ បានចុះមកទន្លេហ្នឹងដដែលវិញទៀតចាស។ នៅ -- ហើយពេលដេកអ៊ីចឹងដែរ ពេលដេកអត់មានកន្លែងដេកស្រួលបួលទេចាស នាងខ្ញុំសម្រាកអ៊ីចឹងទៅ ចេះតែសម្រាកឲ្យបានទៅ ហើយដល់ពេលទឹកវាចេះតែឡើងមក ជន្លេនពួន ពំនូកប៉ុនៗនេះពួនលើជើង។ មែនទែនទៅ លែងខ្លាចហើយជន្លេន ក៏អត់ខ្លាច ឈ្លើងក៏អត់ខ្លាច ស្អីក៏អត់ខ្លាចដែរ ក្រៅតែជីវិតរស់មួយចាស។

[១២:១២:៣៩]

អ៊ីចឹងបានថា ជីវិតនេះគឺថាវាអាក្រក់បំផុត មិនដឹងថាអ្នកដឹកនាំហ្នឹងគេជាមនុស្សសតិសម្បជញ្ញៈគេហ្នឹងជាមនុស្សដែរឬអត់? ដែលគេយកមនុស្សដូចគ្នាទៅធ្វើបាបរបៀបនេះចាស។ ចុងបញ្ចប់ហ្នឹងគឺថា ខ្ញុំណ៎ា គេយៀកណាមចូលខែ០១ បែក គេសប្បាយរីករាយរាំវង់ ឡកកញ្ចេង ប៉ុន្តែជីវិតនាងខ្ញុំ បែករហូតដល់ខែ៥ គឺដោយសារពួក ប៉ុល ពត ហ្នឹង ពួកអាវខ្មៅហ្នឹង កៀរនាងខ្ញុំចុះទៅតទៅទៀត មិនដឹងគេកៀរទៅណា ហើយពួកខ្ញុំអត់ប៊ានរត់ទេ ចេះតែនឹកឃើញថា ខំរស់មកដល់ថ្ងៃនេះ គេស្លាប់ហើយ ម៉ែ -- ញាតិមិត្តអីអ៊ីចឹង អ្នកមកមន្ទីរខ្ញុំមានបួននាក់ ស្លាប់អស់បីនាក់ នៅសល់តែខ្ញុំម្នាក់។ អ៊ីចឹង អត់រត់ទេ ពិបាកស្រណុកអី ខំប្រឹងតទៅទៀតចាស។ រហូតដល់ខែ៥ ទើបខ្ញុំបានបែក។ បែកបានស្គាល់នេះ ខ្ញុំឡើង

មកឃុំត្រពាំងជងចាស តំបន់២៣ ហ្នឹង ខ្ញុំក៏ឡើងមកនៅទីនោះទៅចាស។

[១២:១៣:៣៧]

ហើយជាចុងបញ្ចប់នេះ គឺថាខ្ញុំសូម -- ជាបំណងរបស់ខ្ញុំចាស ចុងក្រោយហ្នឹង គឺថា ក្រោយពីការរៀបរាប់អំពើទារុណកម្មដ៏មហាវិនាសកម្មដ៏អាក្រក់ ដ៏ដូចសត្វធាតុ លើសពីសត្វធាតុទៅទៀតនេះចាស ខ្ញុំសូមបញ្ចប់ចុះ ហើយខ្ញុំសំណូមពរចាស ជាសំណូមពរ ដូចរបស់ខ្ញុំអ៊ីចឹងគឺថា ខ្ញុំបានជម្រាបហើយនៅក្នុងនេះចាស ថាត្រូវធ្វើអី ត្រូវរកមុខអ្នកណាខ្លះ ព្រោះបើថា ខ្មែរដូចគ្នា ហេតុអីក៏ចិត្តខ្មៅម្ល៉េះ? ក្រែងលោតែមានអ្នកបរទេសបន្ថែមលើហ្នឹងទៀត បានជាវាអត់ស្គាល់ឈាមខ្មែរដូចគ្នាចាស។ ចាស អ៊ីចឹងបានថា ខ្ញុំចេះតែចង់ដឹង ឲ្យតុលាការរែកមុខធ្វើម៉េចរកឲ្យឃើញទៅ ហើយសំណាងគឺថា ខ្ញុំសូមឲ្យសាងសង់ស្តូបមួយ ព្រោះដោយសារថា មន្ទីរកសាងខ្លួននៅគុកថ្កោលហ្នឹង ថាវាអត់មានក្នុងការស៊ើបអង្កេតទេ ប៉ុន្តែនេះជាសំណូមពររបស់ខ្ញុំ ទោះបីធ្វើបានក៏ដោយ មិនបានក៏ដោយ ក៏ជាគំនិតរបស់ខ្ញុំផ្ទាល់ចាស ខ្ញុំសូមឲ្យតុលាការជួយផ្តល់ ជួយជាគំនិត ឲ្យបានសង់ស្តូកមួយដើម្បីគោរពវិញ្ញាណក្ខន្ធ អ្នកដែលបានស្លាប់នៅគុកថ្កោលនេះ ព្រោះកន្លែងនេះ ថ្កោលនេះ ខ្ញុំដឹងច្បាស់ជាងគេថា ស្លាប់ច្រើនហ្នឹង។ ចាស ដើម្បីឲ្យវិញ្ញាណក្ខន្ធអ្នកដែលស្លាប់ទៅ ស្លាប់បិទភ្នែកជិត ស្លាប់ដោយអស់ចិត្ត។ ចាស សូមអស់ជាយោបល់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី ឡាយ បូនី ដែលបានអញ្ជើញមកផ្តល់សក្ខីកម្ម ហើយឥឡូវនេះ ការស្តាប់សក្ខីកម្មរបស់លោកស្រី រហូតដល់ពេលនេះបានចប់ហើយ។ ហើយវត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ។ លោកស្រីអាចវិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។

[១២:១៥:៥៤]

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ វិលត្រឡប់ទៅកាន់ទីលំនៅដ្ឋានរបស់គាត់ ឬក៏ទីកន្លែងដែលជាគោលដៅដែលគាត់មានបំណងទៅបានហើយ។ ហើយលោកស្រី ឡាយ បូនី អាចនឹងចាកចេញពីបន្ទប់សវនាការ ត្រឡប់ទៅបានហើយ។

ហើយទន្ទឹមនេះដែរ ក៏អង្គជំនុំជម្រះសូមជម្រាបជូនថា ដោយសារពេលវេលាសមស្របនៅក្នុង

ការសម្រាកពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការត្រឹមនេះ ហើយសវនាការនឹងបន្តធ្វើនៅរសៀលនេះ ចាប់ផ្តើមពីម៉ោងមួយសាមសិបនាទី។ ហើយសវនាការនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើការសវនាការស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម TCW-362 ដែលនឹងចាប់ផ្តើមសួរដោយតំណាងសហព្រះរាជអាជ្ញាមុនភាគីដទៃទៀត។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនភាគីដែលពាក់ព័ន្ធនឹងរឿងក្តីនេះដែរ ថាអង្គជំនុំជម្រះនឹងផ្តល់ឱកាសចំពោះភាគីណាដែលមានបំណងចង់ធ្វើការកត់សម្គាល់លើសេចក្តីថ្លែងការណ៍រៀបរាប់អំពីទុក្ខសោកវេទនា អំពីព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡាយ បូនី ដែលបានធ្វើអម្បាញ់មិញនេះ មុនពេលដំណើរការស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម TCW-362។

សូមអញ្ជើញលោកមេធាវី!

[១២:១៧:១៨]

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំ លោក នួន ជា ចង់តាមដាន -- ស្នើសុំតាមដាននីតិវិធីសវនាការរសៀលនេះ នៅបន្ទប់ខាងក្រោម។ ដោយសារតែលោកមានការឈឺចង្កេះ ហើយនិងមិនអាចផ្តង់អារម្មណ៍បាន ផ្តោតអារម្មណ៍។ ដូច្នេះហើយយើងខ្ញុំនឹងដាក់ជូនលិខិតបោះបង់សិទ្ធិនេះ ជូនលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់លោក នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយមូលហេតុមានបញ្ហាសុខភាព មិនអាចអង្គុយយូរ តាមដានក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះបាន។ ហើយមេធាវីបានសន្យាថា នឹងប្រគល់មកអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ របស់ជនជាប់ចោទ នួន ជា។

[១២:១៨:០៩]

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។ ដោយលោក នួន ជា បានលះបង់សិទ្ធិមានវត្តមាន

ដោយផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី នួន ជា ប្រគល់មកអង្គជំនុំជម្រះភ្លាម នូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់របស់ជនជាប់ចោទ នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដាន និងចូលរួមក្នុងកិច្ចដំណើរការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយដែលស្ថិតក្រោមសាលសវនាការនេះ សម្រាប់រយៈនៃកិច្ចដំណើរការសវនាការនៅរសៀលថ្ងៃនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះ ទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំរួចជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់សាល -- បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយសាមសិបនាទី រសៀលនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១៩ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:០១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅល្ងាចនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-362 ដែលនឹងចាប់ផ្តើមសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាមុននឹងភាគីដទៃទៀត។ ប៉ុន្តែមុននឹងកោះអញ្ជើញសាក្សីរូបនេះចូលមកកាន់បន្ទប់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅភាគី ដែលពាក់ព័ន្ធនឹងរឿងក្តី ប្រសិនបើមានបំណងធ្វើការកត់សម្គាល់លើសេចក្តីថ្លែងការណ៍រៀបរាប់អំពីទុក្ខសោកវេទនាព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ដែលបានធ្វើកាលពីព្រឹកមិញនេះ។

សូមអញ្ជើញ!

[១៣:៣៣:១៧]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន! លោក លោកស្រីចៅក្រម ហើយខ្ញុំអត់មានការកត់សម្គាល់ជាក់លាក់សម្រាប់សាក្សី អ៎! ដើមបណ្ដឹងរដ្ឋប្បវេណីណាមួយទេ។ ប៉ុន្តែខ្ញុំមានសំណួរពាក់ព័ន្ធតែមួយទេ សម្រាប់អង្គជំនុំជម្រះក្នុងការពិចារណា និងសម្រេច។

នៅក្នុងដំណើរការដើមបណ្ដឹងរដ្ឋប្បវេណីថ្លែងទុក្ខសោក ដើមបណ្ដឹងរដ្ឋប្បវេណីបានថ្លែងពីអង្គហេតុមួយចំនួនដែលវាហួស វាផុតពីទំហំនៃរឿងក្ដី០០២/១ លើ ០១។ ខ្ញុំចង់សួរថា តើអង្គហេតុដែលដើមបណ្ដឹងរដ្ឋប្បវេណីបញ្ចេញក្រៅពីទំហំនៃរឿងក្ដីនេះ តើនឹងត្រូវប្រើជាភស្តុតាងនៅក្នុងរឿងក្ដីនេះទេ? ឬក៏តើនឹងត្រូវប្រើជាភស្តុតាងសម្រាប់រឿងក្ដីក្រោយៗទៀតដែរឬទេ? ក្នុងខណៈដែលភស្តុតាង ឬសម្ដីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នោះមិនត្រូវបានសួរដេញដោលដោយភាគីនោះឡើយ។ សូមអរគុណ។

[១៣:៣៤:៣២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៣៤:៥១]

**ប្រធានអង្គជំនុំ៖**

ភាគីដទៃទៀតមានមតិយោបល់អ្វីដែរទេ លើបញ្ហាដែលលើកឡើងដោយមេធាវីជាតិការពារក្ដីលោក អៀង សារី ដែលបានលើកឡើងអម្បាញ់មិញនេះ?

សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំគិតថាយើងបានពិភាក្សាៗគ្នាពីម្សិលមិញ ហើយអង្គជំនុំជម្រះផ្ដល់ឲ្យលទ្ធភាពក្នុង -- ទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីថ្លែងទៅលើសំណុំរឿង០០២។ ហើយយើងក៏កំពុងរៀបចំឯកសារពាក់ព័ន្ធទៅនឹងប្រធានបទនេះ។ ខ្ញុំគិតថា ភាគីទាំងអស់បានប្រើប្រាស់នូវលទ្ធភាពក្នុងការសួរដើមបណ្ដឹងរដ្ឋប្បវេណីនេះនៅលើសំណុំរឿង០០២ អស់ហើយ។ ជាពិសេសគឺមេធាវី នួន ជា ក៏បានសួរពាក់ព័ន្ធទៅនឹងករណីសំណុំរឿង០០២ អស់ហើយ។

ដូច្នេះភាគីអាចសាកសួរគាត់ ហើយអាចផ្ទៀងផ្ទាត់ទៅនឹងតថភាពនូវអ្វីដែលគាត់បានសួរ --

ដែលគាត់បានឆ្លើយ។ ដូច្នេះខ្ញុំគិតថា មិនមានការលំបាកអ្វីនោះទេ។

[១៣:៣៦:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៣៧:១៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់។ ហើយសូមជម្រាបអីចេះ ដោយសារបញ្ហានេះយើងបានដោះស្រាយគ្នា ហើយដោយសារមានបញ្ហានេះបានកើតឡើងកាលពីប៉ុន្មានថ្ងៃមុន លើការអង្គហេតុដែលត្រូវសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីថ្លែងការណ៍រៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់គាត់ ដែលយើងបានសម្រេចមួយរួចហើយ។ ហើយបញ្ហាដទៃទៀត ភាពជាក់ច្បាស់លើបញ្ហានេះ អង្គជំនុំជម្រះនឹងពិនិត្យពិចារណាសម្រេច នៅពេលដែលអង្គជំនុំជម្រះបានទទួលនូវពាក្យស្នើសុំជាលាយលក្ខណ៍អក្សររបស់ក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះបានបង្គាប់ឲ្យគាត់ធ្វើនូវពាក្យសុំជាក់លាក់លើបញ្ហានេះ ដើម្បីអង្គជំនុំជម្រះពិនិត្យពិចារណា សម្រេចលើបញ្ហានេះឲ្យបានជាក់ច្បាស់។ នេះយើងបានឯកភាពគ្នា និងបានកំណត់របៀបក្នុងការដេញដោលរួចហើយ។

[១៣:៣៨:១៤]

ហើយបញ្ហាមួយទៀតថា ភស្តុតាងកម្រិតណាដែលអង្គជំនុំជម្រះនឹងពិចារណាសម្រេចនោះ។ បញ្ហានេះអង្គជំនុំជម្រះសូមជម្រាបថា នៅក្នុងកិច្ចដំណើរការពិភាក្សាដេញដោល អង្គជំនុំជម្រះបានកំណត់នូវអង្គហេតុច្បាស់លាស់ហើយ គឺអង្គហេតុសំណុំរឿង ០០២/០១។ ហេតុដូច្នេះអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់ធ្វើនេះ គឺអង្គជំនុំជម្រះនឹងពិចារណានៅក្នុងក្របខ័ណ្ឌវិសាលភាពនៃអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់នេះ តាមឆន្ទានុសិទ្ធិដែលមាន។ ហើយអង្គជំនុំជម្រះជឿជាក់ថាខ្លួនមានសមត្ថភាពនៅក្នុងការពិនិត្យពិចារណារាល់ភស្តុតាងទាំងឡាយ ដែលពាក់ព័ន្ធនឹងអង្គហេតុដែលបានកំណត់ធ្វើសវនាការពិភាក្សាដេញដោលក្នុងក្របខ័ណ្ឌសំណុំរឿង០០២/០១។ ដោយឡែកសំណុំរឿងផ្សេងទៀត ០០២/០២ ដែលយើងនឹងពិនិត្យពិចារណានៅពេលក្រោយ។ ហើយរឿងនេះគឺអង្គជំនុំជម្រះផ្តល់លទ្ធភាពជូនភាគីនៅក្នុងការពិភាក្សាដេញដោលរាល់បញ្ហាដែលពាក់ព័ន្ធ។ វាមិនដូចគ្នាទេ ប៉ុន្តែអាចស្រដៀងគ្នាទៅនឹងអ្វីដែលយើងបានកំណត់ធ្វើនៅក្នុងសំណុំរឿង០០២/០១ ដែរ។

បាទ ជាបន្តអង្គជំនុំជម្រះសូមមន្ត្រីរដ្ឋបាលតុលាការ កោះអញ្ជើញសាក្សីដែលមានរហស្សនាម TCW-362 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៣:៤០:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនថា អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សូមលះបង់សិទ្ធិមានវត្តមានក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោលចំពោះសាក្សីចំនួន ១០រូប និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦រូប។ ក្នុងចំណោមសាក្សីចំនួន ១០រូប ក៏មានឈ្មោះសាក្សីដែលមានរហស្សនាម TCW-362 ម្នាក់ដែរ។ ហើយយោងតាមរបាយការណ៍របស់លោកគ្រូពេទ្យនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលទទួលព្យាបាលលោក អៀង សារី ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ បានបញ្ជាក់ថា លោក អៀង សារី បច្ចុប្បន្ននេះកំពុងតែសម្រាកទទួលការព្យាបាលនៅផ្នែកទូទៅនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ ហើយពេលនេះ លោក អៀង សារី សូមលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដោយមានដែនកំណត់ ដោយគាត់មានបញ្ហាសុខភាពត្រូវសម្រាកទទួលការព្យបាលនៅមន្ទីរពេទ្យ តែរូបកាយ និងស្មារតីសមស្រប។

[១៣:៤២:០៣]

អង្គជំនុំជម្រះសម្រេច ធ្វើការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-362 ដោយមិនមានវត្តមានលោក អៀង សារី។ ដោយអនុវត្តតាមវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។ ហើយទន្ទឹមនឹងនេះ អង្គជំនុំជម្រះក៏សូមជម្រាបជូនផងដែរថា សាក្សីរូបនេះ នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មគឺមានអមដោយមេធាវីប្រឹក្សាឈ្មោះ លឹម ប៊ុនហេង។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ជម្រាបសួរលោកសាក្សី? ហើយតើលោកឈ្មោះអីដែរ សាក្សី?

**លោក គង់ គីម៖**

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំបានឈ្មោះ គង់ គីម បច្ចុប្បន្នរស់នៅភូមិព្រៃតាំងផ្លង់ ឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ មានប្រពន្ធ មានកូនប្អូន គឺស្រីបីនាក់។

[១៣:៤៣:០២]

**ស៖** បាទ អរគុណលោក គង់ គីម។ តើក្រៅពីឈ្មោះ គង់ គីម តើលោកប្រើឈ្មោះអ្វីផ្សេងដែរ ឬទេ?

**ឆ៖** បាទ ពីមុនមកខ្ញុំឈ្មោះ កើ បាទ។

**ស៖** បាទ អរគុណ។ ហើយលោកប្រកបមុខរបបរកស៊ីធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំបាទ ខ្លួនខ្ញុំផ្ទាល់ប្រធានក្រុមប្រឹក្សាឃុំ។

**ស៖** បាទ អរគុណ។ ហើយលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានទេថា ឪពុកបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំបានឈ្មោះ ជូ ឡុង ស្លាប់។

**ស៖** ចុះម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអីដែរ?

**ឆ៖** ម្ដាយខ្ញុំបាទឈ្មោះ ឡេង គា ស្លាប់។

[១៣:៤៤:០៩]

**ស៖** បាទ អរគុណ។ ហើយចុះប្រពន្ធរបស់លោកឈ្មោះអី?

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ តេង មុត។

**ស៖** អរគុណ។ លោក គង់ គីម តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គលដែលត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្ដី០០២ នេះទេ ហើយក៏មិនជាប់ញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីនាក់ គឺលោក នួន ជា, លោក អៀង សារី, លោក ខៀវ សំផន ដែរ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ ពិតប្រាកដមែន។

**ស៖** លោក គង់ គីម តើលោកបានធ្វើសម្បថហើយឬនៅមុននឹងចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ?

**ឆ៖** ខ្ញុំបាទបានធ្វើសម្បថរួចហើយ។

**ស៖** លោកធ្វើសម្បថនៅកន្លែងណា? ហើយនៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំបាទបានចូលមកដល់ក្នុងនេះ គឺថាធ្វើសម្បថមុននេះបន្តិច។

**ស៖** នៅមុខអ្នកតាដំបងដែកខាងកើតអគារនេះមែនដែរឬទេ?

[១៣:៤៥:៤៥]

**ឆ៖** បាទ នៅមុខអ្នកតាដំបងដែកហ្នឹងមែន។

**ស៖** បាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

ហើយឥឡូវនេះ អង្គជំនុំជម្រះប្រាប់អំពីសិទ្ធិ និងករណីយកិច្ចទៅលោក ក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ លោក គង់ គឹម ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏សុំឱ្យលោកធ្វើអំណះអំណាង ឬអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនឆ្លើយ -- មិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាង ឬសេចក្តីអត្ថាធិប្បាយនោះនាំឱ្យលោកនឹងត្រូវទទួលរងនូវការចោទប្រកាន់។ ករណីយកិច្ចលោកក្នុងនាមជាសាក្សីត្រូវផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការចំពោះមុខអង្គជំនុំជម្រះនេះ ត្រូវឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែក្នុងករណីឆ្លើយតបនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯងដូចយើងជម្រាបអំពីសិទ្ធិរបស់លោកដូចខាងលើអម្បាញ់មិញនេះ។ លោកជាសាក្សីត្រូវតែឆ្លើយការណ៍ដែលណាដែលពិត ដែលខ្លួនលោកបានដឹង បានឮ បានឃើញ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះនឹងសួរលោក។

[១៣:៤៧:១០]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក គង់ គឹម តើលោកដែលធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ពីប៉ុន្មាន រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ?

**លោក គង់ គីម៖**

**ឆ៖** បាទ ខ្ញុំបាទបានឆ្លើយជាមួយខាងស៊ើបអង្កេតបានមួយដងនៅផ្ទះបាទ។

**ស៖** តើលោកចងចាំទេថា ធ្វើហ្នឹងនៅពេលណាដែរ? ថ្ងៃខែឆ្នាំ?

**ឆ៖** ខ្ញុំបាទមិនបានចងចាំពិតប្រាកដទេ ឆ្នាំខែបាទ។

**ស៖** នៅមុនពេលចូលមកមុខអង្គជំនុំជម្រះនាពេលនេះ តើលោក គង់ គីម បានពិនិត្យមើល ឬ អាននូវកំណត់ហេតុស្តាប់ចម្លើយរបស់លោក ដែលបានធ្វើការពីលើកមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យស៊ើបអង្កេត ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

[១៣:៤៨:២៧]

**ឆ៖** ខ្ញុំបាទបានអាននូវកំណត់ហេតុសួរ-ឆ្លើយ អំពីអង្គចៅក្រមស៊ើបអង្កេត។

**ស៖** តាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ ថាតើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្តាប់ចម្លើយដែលបាន -- ដែលលោកបានអានដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ ឬក៏វាស៊ីសង្វាក់គ្នាស្របទៅនឹងចម្លើយ ដែលលោកបានធ្វើសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននោះដែរឬទេ?

**ឆ៖** បាទ នៅលើកំណត់ហេតុនោះពិតជាត្រឹមត្រូវ ពេលដែលខ្ញុំបានឆ្លើយជាមួយចៅក្រម។

**ស៖** បាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

ហើយអង្គជំនុំជម្រះសូមជម្រាបតំណាងសហព្រះរាជអាជ្ញាថា នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀត។ សូមអញ្ជើញ!

**លោក វើង ហ៊ត់៖**

សូមគោរពលោកប្រធាន! សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ! សួស្តីមិត្តភក្តិទាំងអស់ ដែលបានចូលរួមនៅក្នុងអង្គសវនាការនេះ។

ជម្រាបសួរលោក គង់ គីម។ ខ្ញុំជាក្រុមការងារមកពីការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំមានសំណួរចង់ដឹង ដើម្បីឱ្យលោកឆ្លើយ។

មុននឹងខ្ញុំសួរសំណួរ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីផ្តល់កំណត់ហេតុ ចម្លើយ

របស់សាក្សី ដែលគាត់បានឆ្លើយនៅថៅក្រុមស៊ើបអង្កេត ជូនគាត់។ ក្នុងគោលដៅនេះ ខ្ញុំចង់សម្រួលកិច្ចការសំណួរនេះ ឱ្យបានលឿន ហើយចង្អុលបង្ហាញទៅដល់សាក្សី ដើម្បីឱ្យគាត់មានលទ្ធភាពពិនិត្យផង បាទ។

**ប្រធានអង្គជំនុំ៖**

លោកបង្ហាញអត្តសញ្ញាណឯកសារ ជាក់ច្បាស់បានដែរឬទេ?

**លោក វ៉េង ហ៊ាត់៖**

អរគុណលោកប្រធាន។ ខ្ញុំសូមបង្ហាញឯកសារ D166/76។

**ប្រធានអង្គជំនុំ៖**

ម្តងទៀតមើល៍ D166/ ប៉ុន្មាន ចិតសិបប៉ុន្មាន?

**លោក វ៉េង ហ៊ាត់៖**

D166/76។

សូមទោសលោកប្រធាន ច្រឡំ 74 ទេ បាទ។

[១៣:៥២:០៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** លោក គង់ គីម ឥឡូវនេះ លោកមិនទាន់ចាំបាច់ក្នុងការពិនិត្យមើលកំណត់ហេតុនេះទេ។ ខ្ញុំចាប់ផ្តើមសួរលោកសំណួរខ្លះៗ សួរថា តើលោកចូលនៅក្នុងកងទ័ពនៅក្នុងឆ្នាំណាដែរបាទ?

**លោក គង់ គីម៖**

**ឆ៖** ខ្ញុំបាទចូលនៅ -- ចូលកងទ័ពនៅឆ្នាំ១៩៧៤។

**ស៖** ពេលនោះលោកមានអាយុប៉ុន្មានដែរ?

**ឆ៖** អាយុខ្ញុំបាទ មានអាយុ១៥ឆ្នាំ។

**ស៖** សូមលោកជួយរៀបរាប់ តើរចនាសម្ព័ន្ធយោធា ដែលលោកចូលនោះ ទាក់ទងជាមួយនឹង

ភូមិភាគឧត្តរ កងពល៣១០ រួមទាំងតួនាទីរបស់លោកមុនឆ្នាំ -- មុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ផង បាទ។

[១៣:៥៣:៥៣]

**ឆ៖** បាទ ខ្ញុំបាទបានចូលកងទ័ពនៅឆ្នាំ១៩៧៤ នៅក្នុងទ័ពតំបន់ ខេត្តកំពង់ធំ។ ក្រោយមកបានបញ្ជូនមកនៅទ័ពភូមិភាគឧត្តរ។ បាទនៅក្នុងឆ្នាំ១៩៧៤ ដើមឆ្នាំ១៩៧៥ បានបញ្ជូនមកនៅព្រែកក្ដាមហ្នឹងបាទ បញ្ជូនមកវ៉ៃនៅទីក្រុងភ្នំពេញ។

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរលោក ទាក់ទងនឹងមុនថ្ងៃទី១៧ មេសា ឆ្នាំ៧៥។ តើលោកចូលកងទ័ពនេះ លោកធ្លាប់បានចូលរួមប្រជុំផ្នែកកងទ័ពដែរឬទេ?

**ឆ៖** បាទ ពេលដែលធ្វើកងទ័ព បានចូលរួមប្រជុំកម្រិតតែត្រឹមអនុសេនាតូច អនុសេនាធំ ហើយនិងក្រុមបាទ។ អត់ដែលបានប្រជុំរហូតដល់វរសេនាធំកងពល ព្រោះខ្ញុំនៅក្នុងពេលនោះ គឺជាយុវជនហើយ ជាកុមារនៅក្មេងផង។

**ស៖** អ្នកណាដឹកនាំការប្រជុំនៅពេលនោះ ដែលលោកបានឃើញនោះ?

**ឆ៖** នៅពេលប្រជុំ ខ្ញុំបាទ គឺចូលរួមនៅមេក្រុម មានឈ្មោះ ប៉ុន ជាកងអនុសេនាតូច។ ហើយមានមេក្រុម ឈ្មោះ ឡាំ បាទ។

[១៣:៥៦:០៤]

**ស៖** តើកម្មវត្ថុនៃការប្រជុំហ្នឹង គេនិយាយពីអ្វីដែរបាទ?

**ឆ៖** បាទ ពេលដែលប្រជុំ គឺប្រជុំអំពីផែនការដែលយើងវាយសម្រុកចូលទីក្រុងភ្នំពេញ។ អ៊ីចឹងរបៀបគឺនិយាយពីផ្នែកយោធា និងក្បួនយុទ្ធសាស្ត្រ ដែលយើងត្រូវចូលមកដាក់ត្រៀម។ បាទ មានប៉ុណ្ណឹង។

**ស៖** តើពេលនោះ លោកទទួលបញ្ជាផ្ទាល់ឲ្យធ្វើអ្វីដែរ?

**ឆ៖** ពេលនោះ គឺខ្ញុំទទួលបញ្ជា គឺចូលខ្សែត្រៀមមុខ។ សំខាន់គឺពេលនោះ គឺដើម្បីប្រយុទ្ធ វាយចូលក្នុងទីក្រុងភ្នំពេញ។ បាទ ទៅតាមសមរភូមិព្រែកព្នៅ អន្លង់ក្ងាន ភូមិធំ ត្រពាំងព្រាយ មុខព្រួញឆ្ពោះមកទីក្រុងភ្នំពេញ។

**ស៖** បាទ ឥឡូវនេះ លោកចាប់ផ្ដើមកាន់ក្រដាស ដែលខ្ញុំឲ្យលោកអម្បាញ់មិញ ហើយខ្ញុំដាក់សញ្ញាដើម្បីសម្គាល់ថា ឆ.៣។ ដើម្បីឲ្យភាគីផ្សេងទៀត គាត់អាចមានលទ្ធភាពក្នុងការមើល ខ្ញុំសូមអាន

ERN ជាភាសាខ្មែរ 00270163, ភាសាអង់គ្លេស 00278681, ភាសាបារាំង 00486096។ នៅក្នុងខ្លឹមសារទាំងនេះ ខ្ញុំសូមអាន លោកបានប្រាប់ទៅអ្នកស៊ើបអង្កេតថា “ក្នុងពេលជាមួយគ្នានោះ ខ្ញុំទទួលបញ្ជាថា ឱ្យតែទាហានស្លៀកពាក់ទាហាន គឺត្រូវបាញ់សម្លាប់ចោលតែម្តង”។ ខ្ញុំចង់សួរថា តើបញ្ជានេះលោកទទួលពីខាងណាដែរបាទ?

[១៣:៥៨:៥៤]

**ឆ៖** បាទ បញ្ជានេះ គឺខ្ញុំបាទទទួលពីអនុសេនាតូចខ្ញុំផ្ទាល់ ឈ្មោះ ប៊ុន។ ដោយឡែក គឺថាអនុសេនាតូចនេះ គេបានទទួលផែនការពីវរសេនាតូច -- អ៎ វរសេនាធំ ព្រោះខ្ញុំបាទជាយុវជន មិនបានឡើងទៅប្រជុំដល់ថ្នាក់ធំទេ គ្រាន់តែក្រោមការដឹកនាំរបស់អនុសេនាតូច គឺស្តាប់បញ្ជាត្រឹមអនុសេនាតូច។

**ស៖** ខ្ញុំចង់ដឹងថា តើគេបញ្ជារបៀបអ៊ីចឹង ឬមួយក៏ខុសប្លែកពីនេះ សូមលោកជួយបញ្ជាក់បន្ថែម? ហើយសូមបន្ថែម ហើយការបញ្ជានេះ តាមរយៈអង្គប្រជុំ ឬមួយក៏ តាមរយៈមធ្យោបាយអ្វីដែរបាទ?

**ឆ៖** កាលណោះគឺជាបទបញ្ជា គឺទៅតាមអង្គប្រជុំផង ហើយនិងបញ្ជាជាក់ស្តែងទៅតាមសមរភូមិដែលយើងចុះត្រៀម។ គឺថាបញ្ជា គឺកំណត់ថា បើមានទាហាន ឬក៏មានប្រជាជននៅខាងជួរមុខហ្នឹង គឺយើងត្រូវតែបាញ់តែម្តង។

**ស៖** លោកបានមានប្រសាសន៍អំមិញថា ឱ្យតែជួបប្រជាជននៅខាងមុខ ជួរមុខទាហានរបស់លោក ឬមួយក៏ទាហានខ្មែរក្រហមនៅពីមុខហ្នឹង គឺបាញ់ៗតែម្តង តើចង់និយាយអ៊ីចឹងមែនទេលោក?

**ឆ៖** បាទ ពេលដែលនិយាយហ្នឹង និយាយរឿងបាញ់ពិតប្រាកដមែន ប៉ុន្តែទ័ពខាងក្រៅហ្នឹង គេហៅថាទ័ពខ្មែរក្រហម ហើយទ័ពខាងក្នុងហ្នឹង គេហៅថាទ័ពខាង លន់ នល់ បាទ។ អ៊ីចឹងខ្ញុំបាទនៅទ័ពខាងក្រៅ មិនមែនទ័ពខាងក្នុងទេ។

[១៤:០១:២៣]

**ស៖** តើលទ្ធផលបន្ទាប់ពីកិច្ចប្រជុំនេះ លោកអនុវត្តចំពោះមុខប្រជាជនធម្មតាដែលនៅខ្សែ នៅមុខខ្សែត្រៀមរបស់លោក ហើយនិងចំពោះមុខទាហាន លន់ នល់ នោះ តើលោកបានបាញ់ៗ ដូចៗកិច្ចប្រជុំហ្នឹងដែរទេបាទ?

**ឆ៖** បាទ ពេលដែលខ្ញុំបាទ បានទទួលបញ្ជា គឺថាចូលក្នុងសមរភូមិខ្សែត្រៀម គឺថាមិនដែល

បានជួបប្រជាជនសុទ្ធទេ។ បើជួបៗជាមួយតែទាហាននិងទាហាន។ អ៊ីចឹងប្រជាពលរដ្ឋ គឺអត់ដែលមាននៅក្នុងសមរភូមិទេ។

**ស៖** ខ្ញុំសូម ឬក៏សូមឲ្យលោកផ្តល់ព័ត៌មានបន្ថែមទៀត។ ខ្ញុំពិនិត្យឃើញថា ក្រុមរបស់លោកបានបាញ់សម្លាប់ប្រជាជនស៊ីវិល និងបាញ់សម្លាប់ទាហាន លន់ នល់។ ខ្ញុំចង់ដឹងថា មុនពេលជនរងគ្រោះស្លាប់នោះ តើពួកគាត់មានលើកទង់សចុះចាញ់ដែរឬទេ? ហើយនៅក្នុងចម្លើយនេះ គឺលោកអាចពិនិត្យមើលនៅក្នុង ឆ.១៧ ដែលខ្ញុំរៀបចំជូនលោកហ្នឹង អ៎! ឆ.៧។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ អំមិញនេះ តំណាងសហព្រះរាជអាជ្ញាជាតិបានលើកថាជាសម្តីរបស់សាក្សីនិយាយថា “កងទ័ពរបស់គាត់បាញ់សម្លាប់ប្រជាពលរដ្ឋ។ ទោះបីជាលើកទង់ជ័យ-សក៏ដោយ”។ ហើយកន្លងមក យើងអត់ដែលបានឮសាក្សីនេះផ្តល់សក្ខីកម្មបែបនេះទេ។ ដូច្នេះហើយបានជាខ្ញុំជំទាស់នោះបាទ។

[១៤:០៣:៣២]

**លោក វ៉េង ហ៊ត់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតឆ្លើយតបទៅគាត់បន្តិច។ នៅក្នុងសំណួរ គឺក្រុមការងាររបស់ចៅក្រមស៊ើបអង្កេត គាត់បានសួរទៅសាក្សីថា “ពេលវាយក្រុងភ្នំពេញនោះ តើលោក ឬក្រុមរបស់លោកមានបាញ់ចំទាហានស៊ីវិលខ្លះដែរទេ?” ពេលនោះ សាក្សីគាត់បានឆ្លើយថា “ពេលបាញ់ប្រាកដជាត្រូវស្លាប់ហើយ ប៉ុន្តែខ្ញុំមិនដែលបានចាប់យកមកបាញ់សម្លាប់នោះទេ”។ អ៊ីចឹងពេលបាញ់ស្លាប់នេះ ខ្ញុំចង់សួរថាក្រុមលោកហ្នឹងបាញ់សម្លាប់ស៊ីវិលហ្នឹង ពេលនុ៎ងពួកគេហ្នឹងលើកទង់ជ័យ-ស ឬក៏អត់? ហើយបើសិនជាគាត់ឆ្លើយថា លើក មិនលើក អាហ្នឹងរឿងរបស់គាត់។ សូមអរគុណលោកប្រធាន។

[១៤:០៤:២៥]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា សំអាងឲ្យបានត្រឹមត្រូវនៅមូលដ្ឋាននៃដែលលោកបង្អែកដើម្បីតាំងសំណួរ។ អំមិញនេះ គឺលោកបានដាក់ទាំងសំណួរទី៧ សំណួរទី៣ អ៊ី ហើយបើយើងមើលនៅ

ក្នុងឯកសារ D166/74 ហ្នឹង ដូចមិនមានលេខរៀងដូចដែលលោកបានលើកឡើងអ៊ីចឹងទេ។ អ៊ីចឹងទេលោកគប្បីកំណត់នូវផ្អែកលើមូលដ្ឋាននៃសំណួរដែលសួរនៅក្នុងឯកសារនេះ ដោយកំណត់លេខ ERN លេខ ERN នេះឲ្យបានច្បាស់លាស់ទាំងបីភាសា ដើម្បីជាមូលដ្ឋានក្នុងការផ្អែក ក្នុងការតាំងសំណួរដោយសារលោកតាំងសំណួរមិនមានបង្អែកហ្នឹងហើយ ទើបវាមានការកត់សម្គាល់ពីមេធាវីជាតិការពារក្តីលោក ខៀវ សំផន។

**លោក វ៉េង ហ៊ត់៖**

អរគុណណាស់លោកប្រធានដែលបានជួយរំឭក។ ក្រុមការងារខាងមេធាវី ខ្ញុំសូមជម្រាបប្រាប់លោកថា នៅ ឆ.៧ នេះជាការកំណត់របស់ខ្ញុំ ជាមួយដើមបណ្តឹងដែលងាយស្រួលគាត់ពិនិត្យទេ។ ហើយ ERN ជាភាសាខ្មែរ 00270164, ភាសាអង់គ្លេស 00278682, ភាសាបារាំង 00486097។ បាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

លោករៀបចំសំណួរអម្បាញ់មិញចុងក្រោយដែលសួរហ្នឹងម្តងទៀត ដើម្បីឲ្យច្បាស់លាស់ ហើយផ្អែកលើមូលដ្ឋានអ្វីដែលលោកតាំងសំណួរដូច្នេះ? ផ្អែកលើខ្លឹមសារនៃចម្លើយដែលសាក្សីឆ្លើយនៅក្នុងកំណត់ហេតុនេះ ឬយ៉ាងម៉េច ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់ ពីព្រោះសួរទៅ ដូចជារឿងថ្មីចែស យកមកសួរហ្នឹង ដោយសារលោកសួររួច បានមកបង្ហាញសំណួរ-ចម្លើយលេខ៧ លេខប៉ុន្មានដែលលោកបង្កើតដោយខ្លួនឯង ប៉ុន្តែភាគីពាក់ព័ន្ធទៃទៀតអត់ដឹងទេ។

[១៤:០៦:៣៨]

**លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធាន។

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** ខ្ញុំសូមសួរទៅសាក្សីម្តងទៀត។ លោកប្រាប់ថា “ពេលបាញ់ប្រាកដជាមានត្រូវស្លាប់ហើយ ត្រូវស្លាប់ខ្លះហើយ”។ ខ្ញុំចង់ដឹងថា នៅពេលដែលបាញ់ត្រូវស្លាប់ខ្លះនោះ មុនពេលដែលពួក គាត់ស្លាប់នោះ គាត់បាញ់តដៃជាមួយលោក ឬមួយក៏គាត់លើកទង់ជ័យ-ស បាទ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដែលជាអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្តេី ប៉ោះ**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា វានឹងមានលក្ខណៈច្បាស់លាស់ជាងនេះ ប្រសិនបើសហព្រះរាជអាជ្ញាជាតិ អាននូវសំណួរទាំងឡាយដែលមាននៅមុនចម្លើយដែលគាត់ចង់ដកស្រង់នោះ។ សំណួរដែលគាត់សួរនោះគឺថា "តើក្នុងពេលរំដោះទីក្រុងភ្នំពេញនោះ ថាតើកងទ័ពរបស់លោកមានសម្លាប់ជនជាតិស៊ីវិលដែរឬទេ?" បានឆ្លើយថា "មានសម្លាប់ខ្លះ។ ហើយពេលដែលឃើញប្រជាជននោះគឺថា យើងបាន បាញ់សម្លាប់ចោលខ្លះ"។ ដូច្នេះហើយសូមឱ្យខាងសហព្រះរាជអាជ្ញាជាតិនោះ គួរតែអានសំណួរនោះ ឱ្យបានច្បាស់លាស់ទៅ ថាតើមានការសម្លាប់ទាហាន ឬក៏ប្រជាជនដែរឬទេ? ហើយសាក្សី បានឆ្លើយថាមានឃើញប្រជាជនស៊ីវិលទេ។ ដូច្នេះ សូមឱ្យបញ្ជាក់ឱ្យច្បាស់ត្រង់ចំណុចនេះ។

[១៤:០៨:៣១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់ ហើយពេលវេលាតំណាងសហព្រះរាជអាជ្ញា ដូចមានពេលវេលាតិចទេ ប៉ុន្តែការ អ៎! របៀបក្នុងការតាំងសំណួរតែមួយ ឃើញថា មិនភាព មិនមានច្បាស់លាស់ បង្កើតឡើងនូវការជំទាស់តវ៉ាជាច្រើន ហើយការកត់សម្គាល់របស់យើង គឺដូច្នេះ ឃើញថាមិនច្បាស់លាស់ទេ សូមលោករៀបចំសំណួរឱ្យបានច្បាស់លាស់ បញ្ហាទី១។ បញ្ហាមួយទៀតហ្នឹង ការសួរហ្នឹងដូចជាអាចមានការប៉ះពាល់ទៅលើសាក្សី ពីព្រោះសំណួរអំមិញហ្នឹង វាផ្ទុយ ឬក៏វាខុសពីខ្លឹមសារនៃសំណួរ-ចម្លើយដែលបានសួរនៅក្នុងកំណត់ហេតុ។ សួរអំមិញនេះ គឺសួរទៅសាក្សីផ្ទាល់តែម្តង ថាតើសាក្សីហ្នឹងបានបាញ់សម្លាប់ប្រជារាស្ត្រ អឺៗ ជាជនស៊ីវិលដែលឬទេ? អានេះជាសំណួរដាក់បន្ទុកលើសាក្សីហើយ។

**លោក វ៉េង ហ៊ាត់៖**

ខ្ញុំសូមរៀបសំណួរមួយសាទៀត។ ហើយចំពោះ ERN ខ្ញុំបានជម្រាបជូនគ្រប់មិត្តភក្តិជាភាគីទាំងអស់ហើយ។ អ៊ីចឹង ខ្ញុំគ្រាន់តែបង្កើតសំណួរថ្មីទេ។

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** នៅក្នុងសំណួរដដែលនេះ លោកបានប្រាប់អ្នកស៊ើបអង្កេតថា "ពេលបាញ់ប្រាកដជាមានត្រូវស្លាប់ខ្លះហើយ" ហើយខ្ញុំចង់សួរថាតើការបាញ់នេះ គឺត្រូវស្លាប់ទាហានហ្នឹងគឺ មុនពេលដែលបាញ់ស្លាប់ហ្នឹងពួកគេហ្នឹង បាញ់តដៃជាមួយក្រុមលោក ឬមួយក៏ក្រុមទាហាន លន់ នល់ ហ្នឹង លើកទង់ជ័យ-ស? នេះជាគំនិតរបស់ខ្ញុំចង់សួរគាត់បាទ។

[១៤:១០:៣៥]

**ស៖** សួស្តីសាក្សី លោកអាចយល់សំណួរខ្ញុំហ្នឹងបានទេ? ខ្ញុំអាចសួរលោកមួយសាទៀតបាទ។

**លោក គង់ គឹម៖**

**ឆ៖** នៅក្នុងចំណុចដែលបានសួរខ្ញុំបាទនៅក្នុងចំណុចនេះគឺថា ផែនការគឺការទទួលបទបញ្ជាកន្លងទៅដែលរូបខ្ញុំធ្វើទ័ព គឺថាពិតប្រាកដមែន។ ប៉ុន្តែអាការស្លាប់ប្រជាជននេះជាថ្ងៃចុងក្រោយដែលយើងវ៉ៃបែកទីក្រុងភ្នំពេញ ដូច្នេះ ដល់ការចូលដល់ទីក្រុងភ្នំពេញ គឺទាហានខាងក្នុង និងទាហានខាងក្រៅមានកើតពើបប្រយុទ្ធគ្នាបាទ។ ពេលប្រយុទ្ធច្រឡូកជាមួយប្រជាពលរដ្ឋ អ៊ីចឹងកាលដែលបែកទីក្រុងភ្នំពេញគឺថាផ្ទុះអាវុធនៅតាមពួក តាមក្រុមក្រុងភ្នំពេញក៏មានផ្ទុះដែរ។ អ៊ីចឹងមិនកំណត់ថា លើកហើយដាក់អាវុធទាំងអស់ទេ។ បាទ នៅផ្ទុះតាមកន្លែងៗនៅក្នុងក្រុងភ្នំពេញ អ៊ីចឹងបណ្តាលឲ្យគ្រាប់វាប៉ះពាល់ទៅដល់ប្រជាពលរដ្ឋ។

[១៤:១១:៣៨]

**ស៖** អរគុណលោក។ ខ្ញុំបន្តសំណួរទៅទៀត នៅក្នុងឯកសារ ERN ជាភាសាខ្មែរ 00270165, ភាសាអង់គ្លេស 00278683, ភាសាបារាំង 00886097។ នៅក្នុងសំណួរដែលខ្ញុំដាក់ជូនសាក្សី គឺ ឆ.១១។ ខ្ញុំសូម -- ក្នុងនោះលោកបានបញ្ជាក់ថា "នៅពេលដែលលោកវាយចូលទីក្រុងភ្នំពេញ --" ខ្ញុំសូមអានទាំងមូលតែម្តង "ខ្ញុំបានឃើញសាកសពអណ្តែតទឹក ខ្ញុំបានឃើញសាកសពទាហានលន់ នល់មួយៗ និងសាកសពប្រជាជនជាច្រើនស្លាប់ហូរហៃតាមផ្លូវ ខ្លះមានប្រឡាក់ឈាម ខ្លះនៅលើថ្នល់ ឡានពួកខ្ញុំកិនពីលើក៏មាន ចាប់ពីគីឡូម៉ែត្រលេខ៦ រហូតទៅដល់ស្ពានជ្រោយចង្វា"។ ខ្ញុំមានសំណួរទៅលោកថា តើហេតុអ្វីលោកឃើញសាកសពនោះ លោកមិនជួយជញ្ជូនសាកសពចេញបានហើយ -- តើមនុស្សច្រើនពេក ឬយ៉ាងម៉េចបានលោកយកឡានទៅកិនសាកសពទាំងនោះបាទ?

[១៤:១៣:២៦]

**ឆ៖** បាទ នៅពេលនុ៎ងគឺចុងក្រោយ គឺវាយចូលភ្នំពេញគឺថាបានវាយសម្រុកមានជ័យជម្នះ។ ដូច្នេះឡានដែលបើកបរនោះ មិនមែនបើកបរសម្រាប់តែជាន់ទេ បើកបរដឹកជញ្ជូនកងទ័ពដើម្បីចូលមកកាន់មុខព្រួញដែលគេប្រគល់ឲ្យ។ ដូច្នេះពេលដែលមានជ័យជម្នះហ្នឹងឃើញថា វាមានការច្របូកច្របល់ណាស់។ ទី១ ប្រជាពលរដ្ឋគឺថាគាត់នៅកុះករ ហើយមានការដើរហូរហែផង។ ហើយកងទ័ពក៏មិនទាន់ស្គាល់ភូមិសាស្ត្រ អ៊ីចឹងមានការគ្រប់គ្រងជាកង ជាក្រុមដើម្បីចូល មកឈរជើងតាមគោលដៅដែល

មានបទបញ្ជាទៅតាមកង តាមក្រុម។

[១៤:១៤:១៥]

**ស៖** ខ្ញុំចង់ដឹងថា ហេតុអីបានលោកមិនវាងសាកសពនុំងទៅ ចាំបាច់កិនសាកសពធ្វើអីបាទ?

**ឆ៖** បាទ ពេលនុំងដូចខ្ញុំបានឆ្លើយថា មានការច្របូកច្របល់ច្រើន ហើយសាកសពដែលស្លាប់នៅតាមថ្នល់ហ្នឹង គឺថាវានៅរកូតចន្លោះៗហ្នឹង ហើយខ្ញុំបានពុំបានជាអ្នកបើកទេ ខ្ញុំគ្រាន់ជាអ្នកជិះឡានដែលអាហ្នឹងឃើញថា អ្នកបើកឡើងគឺថាគេចដែរ តែគេចវាអត់ផុត។ បាទ ព្រោះវាមានស្លាប់នៅលើថ្នល់ច្រើន អ៊ីចឹងទៅគេចអត់ផុត។

**ស៖** អរគុណលោក។ ខ្ញុំបន្តសំណួរទៅមុខ នៅពេលដែលលោកនាំកម្លាំងកងទ័ពរបស់លោកចូលមកដល់ក្រុងភ្នំពេញហ្នឹង ទទួលបានជ័យជម្នះ តើលោកមានឡើងឋានៈអីដែរទេបាទ?

**ឆ៖** បាទ ពេលដែលវាយចូលនៅក្រុងភ្នំពេញ ខ្ញុំបាទគឺថាមិនទាន់មានឋានៈអីទេ គឺថាជាយុវជនសុទ្ធបាទ។ គឺថាមិនទាន់មានតួនាទីអ្វីទេ។

**ស៖** ខ្ញុំសូមអាននូវលេខ ERN 00270164, ERN ជាភាសាបារាំង 00278682, ERN ជាភាសាបារាំង 00486097។ លោកបានប្រាប់ថា "ពេលដែលចូលមកដល់ទីក្រុងដំបូងលោកឡើងឆែកឆេរផ្ទះប្រជាជន និងដេញប្រជាជនចេញ"។ ខ្ញុំដឹងថា តើការឡើងឆែកឆេរផ្ទះប្រជាជន និងដេញប្រជាជនចេញនេះ លោកទទួលបញ្ជាពីអ្នកណាដែរបាទ?

[១៤:១៦:៣៧]

**ឆ៖** បាទ មុនដំបូងចូលដល់ទីក្រុងភ្នំពេញ គឺថាទៅតាមកង ទៅតាមក្រុមគឺឈរនៅតាមគោលដៅដែលគេកំណត់។ អ៊ីចឹងជាជំហានមុនដំបូង គឺថាមិនទាន់បានបែងចែកកម្លាំងឲ្យដើរឆែកតាមផ្ទះទេ ដោយយើងគ្រប់គ្រងកម្លាំង។ ឃើញថានៅក្នុងទីក្រុងភ្នំពេញនេះ ទាហានក៏មាន ទាហានខាង លន់ នល់ក៏មាន ហើយប្រជាជននៅច្របូកច្របល់ អ៊ីចឹងកងកម្លាំងខាងក្រៅនេះ ជំហានមុខដំបូងគឺចូលទៅគ្រប់គ្រងកម្លាំងតាមដុំៗ។ បាទ ក្រោយមកគឺថាមានការ -- មានបទបញ្ជាពីអនុសេនាតូចៗទទួលផែនការពីអនុសេនាធំថា "ជម្លៀស"។ អ៊ីចឹងការជម្លៀសនេះ មានកងគេពិសេសទៅទៀតដែលជម្លៀសប្រជាពលរដ្ឋចេញ។ ប៉ុន្តែដល់ពេលក្រោយមកឃើញថា ប្រជាពលរដ្ឋគាត់នៅសេសសល់ទៅតាមផ្ទះថ្មដែលនៅជាន់លើៗអ៊ីចឹងទៅ ដូច្នេះគេចែកឡូត៍ ដើម្បីឲ្យកងទ័ពដែលនៅប្រចាំឡូត៍ហ្នឹង គឺថាបោសសម្អាតហើយនិងឡើងទៅតាមផ្ទះ ទៅតាមមុខសញ្ញាដែលគេប្រគល់ឲ្យ។

**ស៖** អរគុណលោក។ តើលោកមានបញ្ហាអ្វីទេនៅពេលដែលប្រជាជនដែលមិនព្រមចុះចេញពីផ្ទះ? តើគេមានវិធានការយ៉ាងម៉េចដែរបញ្ហាពីថ្នាក់លើ?

**ឆ៖** បាទ ពេលដែលមានផែនការជម្លៀសប្រជាពលរដ្ឋចំនួនច្រើនអស់ហើយ នៅតែចំនួនប្រជាពលរដ្ឋដែលតិចតួច ហើយនិងទាហានដែលនៅសេសសល់។ អ៊ីចឹងកន្លងទៅគឺថា ការទទួលបទបញ្ជាឡើងបោសសម្អាតនេះជូនទៅវាទៅចំប៉ះទាហាន។ បាទ ប៉ះទាហាន ហើយក៏មានការបាញ់គ្នានៅលើផ្ទះស្លាប់ទាហានខាងក្រៅក៏មាន។ ហើយបើចំប្រជាពលរដ្ឋគឺនាំគាត់ឲ្យចុះ ហើយបញ្ជូនទៅតាមថ្នាក់លើដែលមានអនុសេនាធំ អនុសេនាតូច រហូតតែដល់កងពល ដែលកងពលខ្ញុំបាទនេះឈរជើងនៅសណ្ឋាគារខាងជើងវត្តភ្នំនេះ គឺឈ្មោះ អឿន។

[១៤:១៨:៥៨]

**ស៖** អរគុណលោក។ ខ្ញុំសូមអានឯកសារដដែលនេះ នៅក្នុង ERN ជាភាសាអង់គ្លេស 00270165 អ៎! ភាសាខ្មែរ, ភាសាអង់គ្លេស 00278683, ភាសាបារាំង 00486097។ ចំណែកសំណួរដែលខ្ញុំធ្វើឲ្យលោកងាយស្រួលនោះគឺ ឆ.១២។ នៅលើ ឆ.១២នេះ អ្នកស៊ើបអង្កេតបានសួរលោកថា "តើប្រាកដទេថាមានបញ្ជាឲ្យប្រជាជនចេញ ហើយបើមិនចេញត្រូវសម្លាប់ចោលដែរទេ?" លោកបានឆ្លើយថា "បាទ មានបញ្ជានេះមែន គឺបញ្ជាតាមរយៈ តាយឹម ដូចរាល់ដង"។ តើខ្ញុំនិយាយនេះលោករក្សាទុក ឬក៏លោកយល់យ៉ាងម៉េចដែរបាទ?

**ឆ៖** បាទ ឈ្មោះ យឹម ហ្នឹង មិនមែនឈ្មោះយឹម ឈ្មោះ យីម គឺគាត់ជាវរសេនាតូចបាទ។ ក្រោយពីប្រជាពលរដ្ឋចេញ ភាគច្រើនដែលបានចេញអស់ហើយ គឺថាមានបទបញ្ជា គឺថាឲ្យតែនៅមួយពីរដែលនៅក្នុងបង្កប់ហ្នឹង គឺកំណត់ថា ទៅជាខ្មាំងបាទ។ អ៊ីចឹងរៀបចំជាឡូទៅតាមអនុសេនាធំ អនុសេនាតូចបាទ តាមក្រុមដែលឲ្យទទួលឡូៗនេះ គឺថាការពារមិនឲ្យមានជនណា ដែលក្រៅពីកងទ័ពដែលខាងក្រៅទេ។ អ៊ីចឹងបើមានជនដែលខាងក្រៅទ័ព គឺសុទ្ធតែគេចោទទៅជាខ្មាំងទៅវិញ បាទ ហ្នឹងជាបទបញ្ជាកន្លងទៅ ប៉ុន្តែដែលជាក់ស្តែង ខ្ញុំបាទពុំដែលបានចាប់បាន ឬយកបាញ់ចោល គឺអត់មានបាទ។ ហ្នឹងកន្លងទៅ ដែលពេលដែលបទបញ្ជា ដាក់ឲ្យយើងខ្ញុំ។

[១៤:២១:១២]

**ស៖** អរគុណ។ ដោយសារបញ្ហាប្រថុចញ៉ុច នៃការជម្លៀសនេះ តើលោកប្រាប់ទៅប្រជាជនថាម៉េចដែរ នៅពេលដែលលោកឲ្យប្រជាជនចេញពីផ្ទះនោះបាទ?

**ឆ៖** បាទ ជំហានមុនដំបូងដែលមានផែនការទទួលបទបញ្ជាពីថ្នាក់លើហ្នឹង កងខ្ញុំបាទគឺអត់មានភារកិច្ចខាងជម្លៀសប្រជាពលរដ្ឋទេ។ អ៊ីចឹងគេចែកទៅ មានកងពិសេសគេអ្នកជម្លៀស រីឯកងខ្ញុំនេះ ជាអ្នកឈរនៅគោលដៅ ហើយការពារកម្លាំងបាទ ពុំបានចូលរួមក្នុងការជម្លៀសប្រជាជនមុនដំបូងទេ។ លុះត្រាតែជម្លៀសអស់ហើយ នៅតិចតួចបានមានតួនាទីបោសសម្អាត ទៅតាមឡូមុខព្រួញដែលគេប្រគល់ឲ្យ។

**ស៖** អរគុណ លោក គីម។ ខ្ញុំសួរបន្តទៅទៀត។ នៅពេលដែលលោកនិយាយអម្បាញ់មិញស្តីពីការនៅចុងក្រោយនេះ តើនៅតាមមន្ទីរពេទ្យ មានអ្នកជំងឺដែលរស់នៅជាចុងក្រោយដែរទេបាទ?

**ឆ៖** បាទ ចំពោះសំណួរនេះ ខ្ញុំបាទ ពេលដែលចូលដល់ទីក្រុងភ្នំពេញគឺ ខ្ញុំទទួលបទបញ្ជាឈរជើងតាមគោលដៅ ហើយមិនបានចូលដល់មន្ទីរពេទ្យពិនិត្យមើលអ្នករបួស គឺថានិយាយរួមចំពោះខ្លួនខ្ញុំបាទ អត់ដឹង។ គឺថា ទទួលបទបញ្ជាតែឈរជើងកន្លែងណា គឺនៅកន្លែងហ្នឹងគឺថា ព្រោះវាមាននាទីគេបាទ។ កាលណាយើងដើរឆ្វេចឆ្វាច វាច្រឡំចូលនាទីគេ គឺមានប៉ះពាល់ គឺថាមានការបាញ់គ្នា។ អ៊ីចឹងគឺថាកំណត់នៅទីណា គឺនៅទីនុំងបាទ។

[១៤:២៣:៣៥]

**ស៖** ខ្ញុំសូមសួរលោកតែមួយសំណួរទៀតទេលោកបាទ។ ទាក់ទងជាមួយនឹងការជម្លៀសនេះ តើលោកធ្លាប់បានជួបក្រុមក្មេងៗ ដែលនៅរង់ចាំម៉ែ ពុក ដែលបែកគ្នានោះ ហើយមិនព្រមចេញណា តើលោកធ្លាប់ជួបពីបញ្ហានេះដែរទេបាទ?

**ឆ៖** បាទ ពេលដែលផែនការជម្លៀសប្រជាពលរដ្ឋចេញពីទីក្រុងភ្នំពេញគឺថា យើងខ្ញុំបាទបានឃើញផ្ទាល់តែប្រជាពលរដ្ឋ ដែលពេលចេញគឺថា មានការណែនតាន់តាប់តាមផ្លូវអ៊ីចឹងជាបន្តបន្ទាប់ហូរហែអ៊ីចឹងទៅ។ តែត្រង់ថា ឲ្យមានកុមារ ក្មេងអីនៅដាច់ជាក្រុមពីរបីនាក់អី អត់មាន។ អត់ដែលឃើញ។

**លោក វ៉េង ហ៊ត់៖**

អរគុណ លោក គង់ គីម ដែលលោកបានខិតខំប្រឹងប្រែង មកជួយបំភ្លឺដើម្បីយុត្តិធម៌ នៅសាលាក្តីនេះ។

សូមអរគុណលោកប្រធាន និងក្រុមប្រឹក្សា។ ខ្ញុំអស់សំណួរហើយ តទៅនេះ ខ្ញុំសូមឲ្យក្រុមការងារសហព្រះរាជអាជ្ញាអន្តរជាតិបន្តសំណួរ។

[១៤:២៥:៤៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមគោរពលោក លោកស្រីចៅក្រម មេធាវី ភាគីទាំងអស់!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សួស្តីលោក គង់ គីម សូមថ្លែងអំណរគុណលោក ដែលលោកបានមកជួយស្វែងរកការពិតដល់តុលាការ ហើយនិងឆ្លើយតបទៅនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាជាតិ។ ខ្ញុំនឹងបន្តសួរត្រង់ចំណុចមួយចំនួនដែលលោកបានឆ្លើយ និងពិភាក្សារួចមកហើយ។ ប្រសិនបើខ្ញុំអាចចាប់ផ្ដើមសួរលោកបាននោះ គឺថាខ្ញុំនឹងសួរអំពីបញ្ជាៗនានា ដែលបានចេញទៅឲ្យក្រុមកងពលរបស់លោកនោះ គឺមានការចេញបញ្ជាទៅកងពលរបស់លោក។ លោកក៏បានរៀបរាប់អំពីបញ្ជាទាំងអស់នោះមួយចំនួនផងដែរ។ ខ្ញុំចង់សួរថា តើគេបញ្ជូនបញ្ជានេះ ដោយរបៀបណាដែរ? នៅក្នុងចម្លើយលើ D166/74 ខ្មែរ ERN គឺ 00270164, បារាំង 00486096, អង់គ្លេស 00278682។ នៅត្រង់នោះ គឺមានសួរសំណួរថា “តើមេរបស់លោកមានប្រាប់លោកអំពីរបៀបចាត់ការប្រជាជនដែរឬទេ?” គឺលោកឆ្លើយថា “អ្នកដែលនៅក្នុងតំបន់នោះ គឺថាត្រូវតែបាញ់ចោលតែម្តង នៅពេលដែលយើងជួបពួកគេ។ បញ្ជាទាំងអស់នេះ គឺចេញមកពី អឿន ទៅ សុង និងប្រធានវរសេនាតូច ឈ្មោះ យឹម រហូតមកដល់ខ្ញុំ”។

[១៤:២៧:៤៣]

ខ្ញុំចង់សុំសួរលោកថា លោកបាននិយាយអំពីឈ្មោះ អឿន នេះ តើលោកអាចបញ្ជាក់បានដែរឬទេ តើបញ្ជានោះ ចេញមកពីមេបញ្ជាការ ហើយឲ្យតាម -- ហើយបញ្ជាតាមដំណាក់កាលពី អឿន រហូតមកដល់លោក ឬក៏យ៉ាងម៉េច?

**លោក គង់ គីម៖**

**ឆ៖** បាទ ពេលដែលទទួលបទបញ្ជានេះ ខ្ញុំបាទពុំដែលបានបទបញ្ជាពីថ្នាក់ធំៗទេ។ គ្រាន់តែស្គាល់ថា អឿន នេះ ជាមេកងពលបាទ។ ហើយ សុង នេះ ជាវរសេនាធំ។ យឹម នេះ ជាវរសេនាតូច។ រ៉េន នេះ ជាអនុសេនាធំ បាទ ហើយបន្តបន្ទាប់ ខ្ញុំជាយុវជនទេ ប៉ុន្តែគ្រាន់តែទទួលបទបញ្ជាតាមថ្នាក់តៗមក ប៉ុន្តែពេលដែលខ្ញុំចូលរួមបានប្រជុំ បានតែត្រឹមអនុសេនាធំទេ មិនដែលបានចូលទៅប្រជុំក្នុងវរសេនាតូច វរសេនាធំ កងពលទេ។ បើអនុសេនាធំ គឺបណ្ដាយុវជនបានចូលរួមជាជួរ គឺប្រជុំស្តាប់នូវបទបញ្ជា។

**ស៖** សូមអរគុណ។ នៅក្នុងចម្លើយរបស់លោក លោកនិយាយថា "បញ្ជានេះ ចេញមកពីប្រធានកងពលឈ្មោះ អឿន"។ តើលោកដឹងថាបញ្ជានោះ ចេញមកពី អឿន គឺលោកដឹងដោយរបៀបណា? នរណាគេប្រាប់លោកដែរ?

[១៤:២៩:៣៣]

**ឆ៖** បាទ ពេលដែលដឹងនោះ តាមផែនការដែលអនុសេនាធំយកផែនការមកដាក់ហើយ គឺគេនឹងប្រាប់ថា បញ្ជានេះ ជាបញ្ជាកងពលរបស់ អឿន។ អ៊ីចឹង ឲ្យបណ្ដាយុវជននៅក្នុងអនុសេនាធំ ក្រោមអនុសេនាតូច និងក្រុមហ្នឹង គឺទទួលការអនុវត្តតាមបទបញ្ជារបស់កងពល។

**ស៖** សូមអរគុណ។ តើភារកិច្ចកងទ័ពរបស់លោក តើជាធម្មតានោះ គឺលោកទទួលបញ្ជាមកពីតែប្រធានកងពលតែប៉ុណ្ណោះ? តើអ៊ីចឹងដែរឬទេ គឺទម្លាប់គឺទទួលបញ្ជាមកតែពីប្រធានកងពលទេជាទូទៅ ឬក៏វាជាករណីពិសេសនៅក្នុងពេលសមរភូមិដែលទទួលបញ្ជាពីកងពល?

**ឆ៖** បាទ នៅពេលដែលយើងប្រយុទ្ធ គឺថាមិនដែលបានជួបមុខប្រធានកងពល ប្រធានវរសេនាធំ ហើយវរសេនាតូចក៏យើងមិនដែលបានស្គាល់មុខ គឺយើងទទួលបញ្ជាពីត្រឹមតែអនុសេនាតូចអនុសេនា -- ក្រុមដែលយើងនៅជាមួយផ្ទាល់។ អ៊ីចឹងគ្រាន់តែស្គាល់ឈ្មោះ ប៉ុន្តែរូបរាងកាយ ហើយនិងមុខមាត់ យើងអត់ដែលស្គាល់ទេ។ គ្រាន់តែទទួលបញ្ជាបន្ត ប៉ុន្តែអនុវត្តជាក់ស្តែងគឺបញ្ជានៅតាមក្រុម និងអនុសេនាតូចហ្នឹង។

[១៤:៣១:១៩]

**ស៖** សូមអរគុណ។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ? សូមលោកកែខ្ញុំ ប្រសិនបើខ្ញុំនិយាយខុស។ ប្រតិបត្តិការយោធាទាំងអស់នៅក្នុងកងពលរបស់លោក គឺដឹកនាំដោយ អឿន តាអឿន។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ កងពលខ្ញុំគឺឈ្មោះ អឿន មែន។

**ស៖** សូមអរគុណ។ តើលោកដឹងដែរឬទេ តើ តាអឿន នេះរាយការណ៍ទៅណាវិញដែរ?

**ឆ៖** បាទ ខ្ញុំបាទ ដូចខ្ញុំជម្រាបហើយថា ខ្ញុំមិនអាចដឹងចាប់ពីវរសេនាតូចឡើងទៅ គឺថាមិនបានទាំងស្គាល់មុខស្គាល់ឈ្មោះផង គឺរួមរស់បានត្រឹមតែអនុសេនាធំ អនុសេនាតូច ហើយនិងក្រុម។ ត្រឹមវរសេនាតូចឡើងលើ គឺមិនដែលបានស្គាល់បាទ។

**ស៖** សូមអរគុណ។ យើងខ្ញុំប្រហែលជាសួរអំពីបញ្ហាអឿននេះ នាពេលក្រោយបន្តិចទៀតនេះ។ ប្រសិនបើយើងមើលចម្លើយរបស់លោកដដែល គឺខ្មែរ 00270164 រហូតដល់ចំណុចចុងក្រោយនៃទំព័រដដែល, បារាំងគឺ 00486097, អង់គ្លេសគឺ 00278682។ លោកបានរៀបរាប់ថា ក្រុមរបស់លោក កងរបស់លោកនៅប៉ែកខាងជើងក្រុង ឈរជើងនៅប៉ែកខាងជើងក្រុង ហើយលោកនិយាយថា លោកត្រូវធ្វើការឆែកឆេរ ហើយដេញប្រជាជនចេញ ហើយគ្មានវិន័យថាមិនឲ្យបាញ់ប្រជាជនឡើយ ហើយប្រសិនអ្នកណាបានបាញ់ហើយនោះ ខ្ញុំមិនដែលឃើញទោសអ្វីដែរ។ ខ្ញុំ -- អ្នកខ្លះមានសីលធម៌មិនបាញ់ ហើយអ្នកគ្មានសីលធម៌ក៏បាញ់។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ តើលោកដឹងដោយរបៀបណាដែរ? ដឹងតាមណាដែរ ដែលថាទាហានខ្លះនោះមានបាញ់អ្នកប្រជាជន?

[១៤:៣៤:០៥]

**ឆ៖** បាទ ពេលដែលទទួលទៅតាមមុខសញ្ញា គឺថាគ្មានបទបញ្ជា ឬគ្មានវិន័យអំពីការមិនឲ្យបាញ់ទេ គឺថាមិនបានផ្សព្វផ្សាយមិនឲ្យបាញ់ ឲ្យបាញ់ក៏មិនគ្មានបទបញ្ជា។ ដូច្នេះដាក់ស្ដែងទៅតាមក្រុមប្រតិបត្តិការដែលមានការប្រតិបត្តិការទៅ ឡើងទៅលើផ្ទះទៅ ជួនកាលវាប៉ះទៅលើទាហាន។ បាទ សេសសល់ទាហានហ្នឹងវាអាចបាញ់ទាហានខាងក្រៅ អ៊ីចឹងវាអាចមានពើបប្រយុទ្ធគ្នាជាដុំ ជាបុគ្គលៗខ្លះដែលក្រោយពីការស្ងប់ស្ងាត់ជម្លៀសទៅហើយ វានៅមានផ្ទុះ នៅមានបណ្ដាលឲ្យស្លាប់ ខ្លះទៅក៏គប់គ្រាប់បែក។ ដូច្នេះ អ្នកខ្លះឡើងទៅពើប ជួនកាលវាមានទាហានផង វាមានប្រជាពលរដ្ឋនៅនុំងផង។ ដូច្នេះគឺថាកាលដែលពេលប្រយុទ្ធគ្នា គឺមានការប៉ះពាល់អ៊ីចឹង។ តែឲ្យថា ការចាប់បានហើយឲ្យបាញ់ គឺអត់មានទេបាទ។

**ស៖** បាទ ចូលទៅក្នុងចម្លើយរបស់លោកដដែលនេះ នៅខាងក្រោមនេះគឺសួរដូចតទៅ លោកបានឆ្លើយដូចខាងក្រោម៖ "ក្នុងពេលដេញប្រជាជនចេញ គឺមានការពិបាកណាស់ដោយសារតែទាហានលន់ នល់ ដែលនៅសេសសល់ខ្លះគឺបានបោកគ្រាប់បែក ហើយសម្លាប់ទាហានខ្មែរក្រហម។ ប្រជាជនខ្លះនៅជាន់លើមិនព្រមចេញ ដូច្នេះយើងទទួលបានបញ្ជាឲ្យកាត់ផ្ដាច់ទឹកផ្ដាច់ភ្លើងចំនួនកន្លះខែហើយទើបពួកខ្ញុំចាប់បានប្រជាជន ហើយចុះមករួចក៏បញ្ជូនទៅឲ្យមេៗ"។ ខ្ញុំសូមសួរលោកថា រយៈពេលប៉ុន្មានដែរ ក្រោយ ១៧មេសា ៧៥ ដែលថាលោកបានទទួលឲ្យ -- បញ្ជាឲ្យផ្ដាច់ទឹកផ្ដាច់ភ្លើងនុំង?

[១៤:៣៦:៣០]

**ឆ៖** បាទ ក្រោយដែលពេលយើងរំដោះភ្នំពេញ ដោយឃើញថាការផលវិបាកការជម្លៀស

ប្រជាពលរដ្ឋឲ្យ -- មិនទាន់អស់ដែលគាត់អាចរស់នៅលើផ្ទះដោយសារគាត់មានទឹក មានអង្ករ មានបាយហូប។ ដូច្នេះ ខ្ញុំបាទគ្រាន់តែទទួលផែនការតាមរយៈថ្នាក់អនុសេនាតូចមួយក្រុម។ តែផែនការនេះជាផែនការកងពល ហើយគេនឹង -- ផែនការហ្នឹងគេផ្តាច់ទឹកផ្តាច់រង្គករហ្នឹង ដើម្បីកុំឲ្យមានប្រើប្រាស់។ អ៊ីចឹងទោះបីជាកងទ័ពដែលនៅទីក្រុងភ្នំពេញហ្នឹង ដែលចូលមកគឺប្រើតែទឹកអាងដែលនៅតម្កល់មានដែលទឹកថ្មី គឺអត់មានចេញចូល។ នេះ ជាផែនការរបស់ថ្នាក់លើ ហើយខ្ញុំជាក់ស្តែងខ្ញុំឃើញអ៊ីចឹងមែន ប៉ុន្តែខ្ញុំមិនអ្នកបញ្ជាទេ រឿងទឹករឿងអីនេះ។

[១៤:៣៧:៣៣]

**ស៖** បាទ សូមអរគុណ។ បាទ ដើម្បីបង្ហាញផ្នែកនេះបន្ថែមតទៅទៀតនោះ ខ្ញុំចង់សួរទៅលោកទៅនឹងកំណត់ហេតុស្តាប់ចម្លើយ។ លោកនៅចាំទេ លោកត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងខែកក្កដា ឆ្នាំ២០០២ ហ្នឹងគឺថាបានទៅសម្ភាសលោក លោកនៅចាំទេ?

**ឆ៖** បាទ ខ្ញុំបាទនៅចាំ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន លោក លោកស្រីចៅក្រម។ នៅក្នុងសំណុំរឿងនេះ គឺថាយើងមានប្រតិចារឹកឯកសារលេខ 19.96 ជាភាសាខ្មែរមានរហូតទៅដល់ ៥០ទំព័រឯណោះ។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបញ្ជូនឯកសារនេះទៅសាក្សី ហើយសូមសួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៤:៣៩:០៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក គង់ គីម ខ្ញុំគិតថាលោកធ្លាប់ឃើញឯកសារនេះពីមុន គឺថាប្រតិចារឹកដែលគេ

សរសេរចេញមកពីការសម្ភាសដោយថតខ្សែអាត់ជាមួយនឹងរូបលោក។ ខ្ញុំសូមសួរទៅលោកថា តើលោកធ្លាប់ឃើញឯកសារនេះពីមុនមកទេ?

**លោក គង់ គីម៖**

**ឆ៖** បាទ ឯកសារដែលខ្ញុំកាន់នឹងដៃហ្នឹងគឺពុំដែលឃើញ អត់ដែលឃើញ។

**ប្រធានអង្គជំនុំ៖**

ដកចេញវិញទៅ មន្ត្រីរដ្ឋបាលតុលាការដកឯកសារពីសាក្សីវិញ!

[១៤:៤០:០៤]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** បាទ លោក គង់ គីម ខ្ញុំសូមបញ្ជាក់ឡើងវិញថា លោកនៅចាំថាគេធ្លាប់បានសម្ភាសលោក ដូច្នេះខ្ញុំមិនមានជាការភ្ញាក់ផ្អើលអីទេ ដែលលោកឆ្លើយថាលោកមិនធ្លាប់បានឃើញនោះ។ នៅក្នុងឯកសារនេះលោកបាននិយាយប្រធានបទដូចគ្នា ទៅនឹងអ្វីដែលខ្ញុំកំពុងតែសួរលោក។ ដូច្នេះខ្ញុំគ្រាន់តែសុំសួរលោកពីរបីសំណួរទេ ថាតើវាស៊ីសង្វាក់គ្នាទៅនឹងឯកសារដែលខ្ញុំសួរលោកនេះទេ។ នេះគឺជាផ្នែកមួយពាក់ព័ន្ធទៅនឹងបញ្ហារបស់ខ្មែរក្រហមបាទ មិនមែនបញ្ហារបស់ខាងផ្នែកទាហានសាធារណរដ្ឋនោះទេ។ យោងទៅតាមប្រតិចារឹកនេះ លោកឆ្លើយដូចតទៅ "ទាហាននៅក្នុងក្រុមរបស់ខ្ញុំ" -- ខ្ញុំនឹងផ្តល់លេខ ERN តាមក្រោយ។ ERN ជាភាសាខ្មែរ 00054834, ជាភាសាបារាំង 00403350, អង់គ្លេស 00633874។ បាទ នេះគឺជាផ្នែកដែលខ្ញុំចង់សួរ -- "ទាហាននៅក្នុងកងរបស់ខ្ញុំទើបតែមកចេញពីព្រៃយើង -- បាទ យើងពាក់ឯកសណ្ឋាន *ប៉ូលីដេស្ទ័រ* មួករបស់ពួកខាងយើងខ្ញុំ គឺថាដេរថ្នេរខុសពីក្រុមដទៃ។ នៅពេលដែលយើងឃើញឯកសណ្ឋានរបស់ទាហាន លន់ នល់ នៅថ្មីៗក៏យកមកពាក់។ នៅពេលទាហានយើងខ្ញុំមកគេកំណត់អត្តសញ្ញាណខុស ដូច្នេះគេបានបាញ់សម្លាប់ទាហាននៅកងរបស់ខ្ញុំជាច្រើន ដោយសារតែមានការច្របូកច្របល់ច្រឡំឯកសណ្ឋាននេះ"។ ដូច្នេះ ខ្ញុំសូមសួរទៅលោក តើលោកនៅចាំទេ លោកនៅចាំស្ថានការណ៍ដែលថាទាហាននៅកងរបស់លោក ឬទាហានរបស់ខ្មែរក្រហមដែលពាក់ឯកសណ្ឋានទាហាន លន់ នល់ នោះគឺត្រូវបានសម្លាប់នៅក្រោយពេលការដួលរលំទីក្រុងភ្នំពេញនោះ?

[១៤:៤២:៥៧]

**លោក គង់ គីម៖**

**ឆ៖** បាទ ពេលដែលយើងចូលដល់ទីក្រុងភ្នំពេញ គឺថាមានការច្របូកច្របល់។ ដោយឡែកគឺ

ប្រជាពលរដ្ឋគឺច្របូកច្របល់ ហើយទាហាន និងទាហាននេះក៏មានការច្របូកច្របល់។ ដូច្នេះការប្រយុទ្ធដែរយើងចូលទៅតាមមុខសញ្ញាមកវាមុនដំបូងពង្រាយ ដោយយើងគ្រប់គ្រងមិនទាន់បាន។ អ៊ីចឹងដោយឡែកគឺថាជាចរិតរបស់មនុស្ស ទាហានខាងក្រៅនេះអ្នកដែលមិនគោរពទៅតាមបទបញ្ជាខ្លះ គឺថាពេលដែលឃើញខោអាវទាហានមក យកខោអាវហ្នឹងមកស្លៀកពាក់។ អ៊ីចឹងទាហានដែលគេកាន់ចរិតពីនុំងមក ដែលៗគេស្លៀកខោអាវ ឯកសណ្ឋានគេនៅព្រៃស្រេចហ្នឹង ដល់តែពេលឃើញហ្នឹងវាអាចច្រឡំគ្នាបាទ។ ហើយមានការប្រយុទ្ធគ្នា។ អ៊ីចឹងមិនត្រឹមតែប្រយុទ្ធគ្នាស្លាប់ទេ សូម្បីទាហានដែលមកពីព្រៃខ្លះភ្លើតភ្លើនទៅដល់បើកម៉ូតូ បើកឡានអីបុកស្លាប់អីក៏មានដែរ។ អ៊ីចឹងគឺថាមានការច្របូកច្របល់ណាស់ពេលដែលបែកភ្នំពេញនេះ។

[១៤:៤៤:០២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះសម្រាកនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ប្រសិនបើអនុញ្ញាត ខ្ញុំសូមការណែនាំពីអង្គជំនុំជម្រះ ដោយសារតែពេលវេលា យើងចាប់ផ្ដើមយឺតបន្តិចហើយចំពោះសាក្សីរូបនេះ គឺនៅម៉ោងប្រហែលជាមួយកន្លះជាងឯណោះ។ ដូច្នេះហើយយើងទទួលបានមួយម៉ោងកន្លះសម្រាប់ខាងសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយខ្ញុំដឹងថា អង្គជំនុំជម្រះក៏បើកសវនាការនៅថ្ងៃស្អែកផងដែរ។ ដូច្នេះ ខ្ញុំសូមសួរថាតើយើងខ្ញុំនេះ ខាងតំណាងសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី នឹងអាចសួរបន្តនៅពេលដល់ថ្ងៃព្រឹកស្អែកទៀត ឬក៏យ៉ាងម៉េចលោកប្រធាន? ឬក៏លោកប្រធានចង់ឲ្យយើងខ្ញុំបញ្ចប់មុនជាងនេះ?

[១៥:០៤:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០៥:៤៧]

**ប្រធានអង្គជំនុំ៖**

ចុះខាងក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីត្រូវ ប្រហែលជាទំនងត្រូវការពេលវេលាប៉ុន្មានដែរ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំរយៈពេល១ម៉ោង ត្រូវការរយៈពេល១ម៉ោង។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា! អង្គជំនុំជម្រះយល់ព្រមអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញាអាចបំពេញកិច្ចការរបស់ខ្លួននៅរសៀលនេះ ហើយស្អែកអង្គជំនុំជម្រះនឹងផ្ដល់ម៉ោងដោយឡែកជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីរយៈពេល១ម៉ោង។

[១៥:០៦:៤៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះការសម្របសម្រួលនេះ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក គង់ គីម លោកបានជ្រាបហើយ គឺយើងខ្ញុំនៅសល់១ម៉ោងទៀត។ ដូច្នេះខ្ញុំព្យាយាម

សួរឲ្យបានគ្រប់ជ្រុងជ្រោយទៅលើចំណុចទាំងឡាយ។ មុនពេលឈប់សម្រាក យើងបានជជែកគ្នាអំពីករណីប្រជាជនត្រូវបានគេបង្ខំឲ្យចាកចេញពីផ្ទះសម្បែង ហើយនិងការកាត់ផ្ដាច់ទឹកផងដែរ ទឹកប្រើប្រាស់។ នៅក្នុងកិច្ចសម្ភាសន៍ដដែលនោះ កិច្ចសម្ភាសន៍ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា មានចំណុចមួយ ផ្នែកមួយនោះគឺពាក់ព័ន្ធទៅនឹងហេតុការណ៍ទាំងនេះ ខ្មែរ ERN គឺលេខ 0054836, បារាំង 00402351, អង់គ្លេស 00633875។ ខ្ញុំនឹងអានផ្នែកទាំងឡាយដែលពាក់ព័ន្ធនៅក្នុងឯកសារនេះជូនលោកស្ដាប់។ “តើលោកនិងអ្នកណាមួយរាយការណ៍អំពីហេតុការណ៍នេះទៅថ្នាក់លើដែរឬទេ? ចម្លើយ៖ បាទ ខ្ញុំរាយការណ៍ អ្នកផ្សេងក៏រាយការណ៍ផងដែរ។ យើងពិភាក្សាជជែកគ្នានៅក្នុងក្រុម នៅពេលដែលយើងធ្វើរបាយការណ៍ឡើងទៅលើបែបនេះ”។ បន្ទាប់មកនៅខាងក្រោមបន្តិចគឺមានសំណួរថា “តើកម្រិតលោករាយការណ៍ទៅ ត្រឹមកម្រិតណា? លោកឆ្លើយថា លោករាយការណ៍ទៅកងវរសេនាតូចដែលនៅពីលើខាងយើងខ្ញុំ”។ តើត្រឹមត្រូវដែរឬទេ លោក គង់ គីម គឺលោកបញ្ជូនរបាយការណ៍ឡើងទៅលើអំពីស្ថានភាព ឬក៏នៅពេលជម្លៀសប្រជាជននោះ គឺថាលោកក៏បានរាយការណ៍ទៅថ្នាក់លើផងដែរ? តើអ៊ីចឹងដែរឬទេ?

[១៥:០៨:៥៧]

**ប្រធានអង្គជំនុំ៖**

លោកសាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមគោរពតុលាការ អង្គសវនាការ។ ខ្ញុំមិនឡើងមកជំទាស់ទេ ប៉ុន្តែឡើងមកធ្វើសំណូមពរ មុនសម្រាកនេះ អង្គជំនុំជម្រះបានបង្គាប់ឲ្យដកឯកសារពីដៃសាក្សីហើយ ប៉ុន្តែមិនទាន់បានដកឯកសារពីកុំព្យូទ័រ។ អាស្រ័យហេតុនេះ សូមមេត្តាបង្គាប់ឲ្យដកឯកសារពីកុំព្យូទ័រដែរ ដូចបទបញ្ជាមុនៗ សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំគិតថា ឯកសារនេះមិនបានបញ្ចាំងឲ្យសាក្សីមើលនោះទេ ហើយយើងខ្ញុំដឹង ប្រសិនបើបញ្ចាំងឲ្យសាក្សីមើលនោះ គឺថាខ្ញុំនឹងសូមឲ្យដកចេញភ្លាមតែម្ដង គឺមិនឲ្យមើលទេ។

**ប្រធានអង្គជំនុំ៖**

បាទ កុំឲ្យមានបញ្ហាស្មុគស្មាញ។ ដកចេញ។

[១៥:១០:០០]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** យើងត្រឡប់មកវិញលោក គង់ គីម។ ខ្ញុំសូមសួរអំពីបញ្ហារាយការណ៍។ តើត្រឹមត្រូវដែរឬទេ គឺលោកនោះ ក៏ត្រូវធ្វើការរាយការណ៍ឡើងទៅមេបញ្ជាការកងវរសេនាតូចផងដែរ។ តើអ៊ីចឹងដែរឬទេ? បាទ កុំអាលទាន់ឆ្លើយ លោកមានការជំទាស់ហើយ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីការពារក្ដីលោក នួន ជា?

[១៥:១០:២២]

**លោក ហ្សាស្ដើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ ដើម្បីយុត្តិធម៌ចំពោះសាក្សី សហព្រះរាជអាជ្ញាគួរអានកថាខណ្ឌនៅខាងលើសំណួរនេះផងដែរ។ ដោយសារតែសាក្សីមិនរាយការណ៍អំពីបញ្ហាជម្លៀសប្រជាជននោះទេ។ គឺការដែលគាត់រាយការណ៍នោះ គឺថាគាត់រាយការណ៍ទៅលើស្ថានភាពផ្សេងតែប៉ុណ្ណោះ។ ដើម្បីឲ្យយើងយល់លម្អិតទៅលើចំណុចហ្នឹង គួរតែអានចំណុចខាងលើហ្នឹង ឲ្យសាក្សីបានស្ដាប់ផង។ ដូច្នេះសហព្រះរាជអាជ្ញាគួរតែអានផ្នែកខាងលើឲ្យសាក្សីបានស្ដាប់ មុននឹងសំណួរដែលគាត់បានសួរ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ជាទីគោរព! ខ្ញុំសូមឆ្លើយតបដូចតទៅ៖ នៅក្នុងការលើកឡើងរបស់ខ្ញុំ ការជំទាស់បែបនេះ គួរតែច្រានចោល។ គឺមេធាវីការពារក្ដី ក៏អាចមានសិទ្ធិធ្វើការសួរអំពីបរិបទនេះផងដែរ។ នេះគឺជាឯកសារមាន ៥១ទំព័រ វាវែងណាស់។ ដូច្នេះហើយ ខ្ញុំសូមឲ្យសាក្សីបញ្ជាក់បំភ្លឺតែប៉ុណ្ណោះ។ សាក្សីគឺគាត់មានលទ្ធភាពផ្ដល់ជារូបភាព និងពន្យល់ឲ្យយើងពេញលេញនៅលើចំណុចនេះ ពាក់ព័ន្ធទៅនឹងឯកសារ ៥១ទំព័រនេះ។ ដូច្នេះហើយ យើងខ្ញុំសូមស្នើថា ឲ្យលោកប្រធានច្រានចោលនៃការជំទាស់នេះ។

[១៥:១១:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់គ្មានប្រសិទ្ធភាព។ សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយសហ

មេធាវី -- តំណាងសហព្រះរាជអាជ្ញាដែលសួរលោកចុងក្រោយអម្បាញ់មិញនេះ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក គង់ គីម តើលោកចង់ឲ្យខ្ញុំសួរសំណួរឡើងវិញដែរឬទេ?

**លោក គង់ គីម៖**

**ឆ៖** បាទ ឲ្យសួរថែមបន្តិច អំមិញអត់សូវច្បាស់ទេ។

**ស៖** សំណួររបស់ខ្ញុំនោះ គឺគ្រាន់តែចង់សួរថា លោកនេះ ក៏បានធ្វើរបាយការណ៍ រាយការណ៍ជូនទៅមេបញ្ជាការកងវរសេនាតូចអំពីការជម្លៀសប្រជាជនផងដែរ។ តើលោកបានធ្វើរបាយការណ៍ទៅកងវរសេនាតូចដែរឬទេ?

**ឆ៖** បាទ នៅពេលនោះ ដោយខ្ញុំជាយុវជន គឺមិនបានរាយការណ៍ទៅដល់វរសេនាតូចទេ។ គឺថាការរួមរស់បានតែត្រឹមក្រុម អនុសេនាតូច និងអនុសេនាធំ។ រីឯវរសេនាតូច គាត់នៅដាច់ដោយឡែកៗ អ៊ីចឹងមិនអាចស្គាល់គ្នាទេ។ កាលណោះ គឺថាការចងក្រង ការនៅជាមួយ បានត្រឹមតែអនុសេនាតូច និងអនុសេនាធំ។ អ៊ីចឹង របាយការណ៍បានត្រឹមតែថ្នាក់អនុសេនាធំ។ បាទ មានប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ តើក្រុមរបស់លោកនេះ ជូនដំណឹងរាយការណ៍ទៅអនុសេនាធំអំពីការជម្លៀសប្រជាជនដែរឬទេ?

**ឆ៖** បាទ ពេលដែលកម្លាំងធំដែលបានជម្លៀសប្រជាជនជាច្រើនអស់ទៅហើយ គឺបើនៅក្នុងគោលដៅរបស់ខ្ញុំពិនិត្យឃើញថា ប្រជាជននៅសល់ ហើយនាំប្រជាពលរដ្ឋនេះ ចេញពីផ្ទះ បញ្ជូនទៅត្រឹមអនុសេនាធំហ្នឹង បាទ។

[១៥:១៣:៤៨]

**ស៖** សូមអរគុណ។ នៅពេលនេះ បើសិនជាយើងមើលអំពីតួនាទីរបស់លោក និងនៅក្នុងចម្លើយរបស់សហចៅក្រមស៊ើបអង្កេត គឺគេបានសួរលោកឲ្យលោករៀបរាប់អំពីប្រវត្តិរបស់លោកមុនឆ្នាំ១៩៧៥។ លោកបាននិយាយថា “លោកគឺជាកងទ័ពនៅក្នុងពល៣១០ នៅភាគខាងជើង។ លោកនៅក្នុងក្រុម ក្រុមនីមួយៗ គឺមាន១២នាក់”។ ដូច្នេះ តើលោកនេះ នៅពេលដែលជម្លៀសទីក្រុងភ្នំពេញលោកជាប្រធាន “ក” -- ក្រុម “ក” ដដែល ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ពេលដែលវាយចូលដល់ -- មុនពេលចូលដល់ភ្នំពេញ ខ្ញុំបាទមិនទាន់មានតួនាទីជាប្រធាន “ក” នៅឡើយទេ។ ក្រោយមកគឺថាបែក វាយបែកភ្នំពេញ ដោយការរៀបចំនៅទីក្រុងភ្នំពេញ

ឈរជើងនៅតាមគោលដៅ ពេលនោះ ខ្ញុំបានទទួលតួនាទីជាប្រធាន “ក”។

[១៥:១៥:១១]

**សៈ** ប្រសិនបើយើងមើលៗ ការងាររបស់ក្រុមរបស់លោក ជាពិសេសក្នុងពេលដែលជម្លៀសប្រជាជននោះ យោងតាមចម្លើយដែលលោកបានឆ្លើយបញ្ជាក់ប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ERN ដែលពាក់ព័ន្ធជាភាសាខ្មែរគឺ 00054839, បារាំងគឺ 00402355, អង់គ្លេសគឺ 00633879។ សំណួរគេសួរលោកដូចតទៅ៖ “តើលោកប្រាប់ប្រជាជនយ៉ាងម៉េច នៅពេលដែលលោកជួបឃើញប្រជាជននៅក្នុងផ្ទះ តើប្រាប់ពួកគេយ៉ាងម៉េច?” លោកឆ្លើយដូចតទៅ៖ “យើងប្រាប់ថាមេបញ្ជាការឲ្យប្រជាជនចាកចេញ ប្រសិនបើតវ៉ានឹងបាញ់សម្លាប់ចោល។ យើងប្រើអំណាចបាញ់សម្លាប់ពួកគេចោល។ ពួកមេបញ្ជាការបញ្ជូនយើងមកឲ្យធ្វើការជម្លៀសប្រជាជន។ ប្រសិនបើមិនចេញពីផ្ទះ ក្រោយពីយើងដែលហៅចេញនោះទេ គឺយើងនឹងបាញ់សម្លាប់ចោល។ ហើយប្រសិនបើតវ៉ានៅពេលដែលធ្វើដំណើរមកនោះ គឺថាយើងនឹងបាញ់ចោលផងដែរ។ យើងមិនពាក់ព័ន្ធទៅនឹងនាំពួកគេទៅណានោះទេ គ្រាន់តែហៅពួកគេឲ្យចាកចេញពីផ្ទះ”។ តើនេះគឺជាសេចក្តីសង្ខេបនូវចម្លើយរបស់លោក ដែលលោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងពេលដែលលោកធ្វើការងារជម្លៀសប្រជាជននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ហើយប្រសិនជាប្រជាជនមិនចេញទេ យើងនឹងមានការបាញ់សម្លាប់ចោល។ តើអ៊ីចឹងដែរឬទេ? ការសង្ខេបហ្នឹងត្រឹមត្រូវដែរឬទេ?

[១៥:១៧:១២]

**ឆៈ** បាទ ពេលដែលជម្លៀសប្រជាពលរដ្ឋជាច្រើននុ៎ង ខ្ញុំមិនទាន់បានទទួលបទបញ្ជាឲ្យកម្ទេចចោលទេ។ ក្រោយមកដែលប្រជាពលរដ្ឋជាច្រើនទៅអស់ហើយ ហើយនៅក្រោយនេះ មានប្រជាពលរដ្ឋនៅខ្លះ ដោយគាត់នៅជាន់លើ ហើយមានទាហាន។ ដូចខ្ញុំបានបញ្ជាក់ថា មានទាហាន។ ដែលពេលក្រុមប្រតិបត្តិការទៅតាមផ្លូវនេះ ហើយឡើងទៅតាមផ្ទះថ្មមានទាហានបាញ់ទ័ពខាងក្រៅស្លាប់ ដោយពេលឡើងជម្លៀសហ្នឹង។ ដូច្នេះក្រោយមកមានផែនការតឹងតែងថា បើសិនជាមានមនុស្ស ប្រជាជនក៏ដោយអីក៏ដោយឲ្យតែឡើងទៅគឺថាបើឃើញ ដោយគេចាត់ទុកថាអ្នកទាំងនេះគឺជាខ្មាំង គឺអ្នកចចេស ដោយមិនតាមការឃោសនាឲ្យចេញ។ អ៊ីចឹង ខ្ញុំបានដឹងច្បាស់ដែរថា ពេលគេជម្លៀសហ្នឹង មានកងគេដើរប្រកាស ដើរផ្សព្វផ្សាយអ៊ីចឹង ឲ្យប្រជាពលរដ្ឋចុះពីលើផ្ទះ ចាកចេញទីលំនៅហ្នឹងឲ្យចុះមកបង្ហាញ ហើយគេនឹងជម្លៀសចេញ។ ក្រោយដែលគេប្រកាសហើយ គឺអាហ្នឹងជាបទបញ្ជាក្រោយដែលថា អ្នក

ដែលរឹងទទឹងហ្នឹងគឺបទបញ្ជាទៅតាមគោលដៅដែលឈរជើងហ្នឹង គឺជាបទបញ្ជាថា ប្រជាជនក្តី ឬក៏ទ័ពក្តី គឺត្រូវតែមានការបាញ់ ព្រោះវាមានការប៉ះពាល់បាញទ័ពខាងក្រៅហ្នឹងស្លាប់។ អីចឹងបានមានបទបញ្ជាហ្នឹង។

[១៥:១៨:៣៨]

**សៈ** សូមអរគុណ។ នៅក្នុងចំណុចដដែលនេះ ប្រសិនបើយើងលេខខ្មែរ ERN មើលខ្មែរ ERN 0054840 (ស៊ីក), បារាំងគឺមានលេខ 00403350, អង់គ្លេសគឺ 633874, សំណួរនោះសួរថា "តើមានអ្វីកើតឡើងចំពោះខ្មោចដែលបានសម្លាប់ចោលនោះ?" លោកបានឆ្លើយថា "នៅពេលដែលយើងទៅដល់ក្រុង ប្រសិនបើយើងចង់បាញ់ប្រជាជន គឺអាចបាញ់បានតែម្តង គឺប្រជាជន គឺនៅក្នុងក្រុម។ យើងអាចបាញ់ប្រជាជនបាន លើកលែងតែកងទ័ពរបស់យើងមិនអាចបាញ់បាននោះទេ។ ដូច្នេះយើងអាចបាញ់ប្រជាជនបាន។ យើងមិនទទួលទោសនោះទេ ដោយសារតែប្រជាជនទាំងអស់នោះ គឺជាខ្មាំង។ នៅពេលនោះ ត្រាក់ទ័របានអូសខ្មោចទម្លាក់ចូលទន្លេពីគីឡូម៉ែត្រ៦ ទៅ គឺថាយើងឃើញមានខ្មោចនៅតាមផ្លូវ"។ នៅពេលដែលយើងមើលចំណុចដែលបានសរសេរដូច្នេះ លោក គីម តើត្រឹមត្រូវដែរឬទេ ដែលថា ទាហានខ្មែរក្រហមនោះ បើសិនជាចង់បាញ់ប្រជាជនសម្លាប់ចោលនោះ ពួកគេអាចបាញ់បានតែម្តងហើយគ្មានទទួលទោសពៃរ៍អ្វីទេ នៅពេលដែលបាញ់ប្រជាជន តើដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ សំណួរនេះ គឺថាសួរឲ្យសាក្សីទាយស្មានរួចទៅហើយ ដោយសារតែគឺសាក្សីមិនអាចឆ្លើយអំពីករណីខ្មែរក្រហមផ្សេងទៀតនោះទេ។ គឺគាត់អាចឆ្លើយអំពីបទពិសោធន៍ដែលគាត់បានឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ។ សំណួរនេះគួរតែរៀបចំឡើងវិញដើម្បីសួរទៅកាន់សាក្សី។ បើសិនមិនរៀបចំឡើងវិញទេ យើងខ្ញុំសូមជំទាស់នឹងសំណួរនេះ។

[១៥:២១:០១]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំមិនយល់ស្របជាមួយនឹងមេធាវីការពារក្តីនោះទេ ដែលថាប្រធានក្រុមកងនេះ

មិនអាចធ្វើការផ្តល់យោបល់លើបញ្ហាទាហានខ្មែរក្រហមនៅក្នុងសម័យនោះ។ យើងដឹងហើយថា នៅពេលនោះ គាត់បានបញ្ជាក់ហើយថា គាត់បានទទួលបញ្ជានៅក្នុងអំឡុងពេលប្រតិបត្តិការ។ ដូច្នេះហើយ សំណួររបស់ខ្ញុំនោះ គឺមានលក្ខណៈពិតជាត្រឹមត្រូវ។

[១៥:២១:២៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២១:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា មិនត្រឹមត្រូវទេ។ សេចក្តីជំទាស់គ្មានប្រសិទ្ធភាព សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញា!

**លោក គង់ គីម៖**

**ឆ៖** បាទ សំណួរដែលថា មានខ្មោចនៅតាមទន្លេនេះ ដោយខ្ញុំឃើញផ្ទាល់ថា មានអណ្តែតទឹកនៅតាមទន្លេមែន។ ប៉ុន្តែអារឿងខ្មោចនេះមិនដឹងជាត្រូវគ្រាប់ពេលប្រយុទ្ធគ្នា មិនដឹងជាគេយកទៅបាញ់ចោល គឺថាអត់ដឹងទេ។ ដោយឃើញជាក់ស្តែងវាអណ្តែតនៅក្នុងទន្លេ។ រីឯខ្មោចនៅតាមថ្នល់គឺថាសុទ្ធតែខ្មោចដែលស្លាប់ដោយសារប្រយុទ្ធគ្នា ព្រោះការប្រយុទ្ធនេះគឺថាចេញពីព្រែកឆ្មៀមកមានប្រយុទ្ធគ្នាតាមផ្លូវរហូត។ អ៊ីចឹងទាហាននិង ខាងក្នុង និងទាហានខាងក្រៅ អ៊ីចឹងបើទាហានខាងក្រៅគេយកចេញ បើទាហានខាងក្នុងវាសាកសពនៅលើថ្នល់។ អ៊ីចឹងក្រោយមកគេ ដើម្បីឲ្យថ្នល់ហ្នឹងវាៗទូលាយ គេយកអាត្រាក់ហ្នឹងឈូសខ្មោចហ្នឹងចូលទៅខាងទន្លេបាទ។

[១៥:២៣:១៤]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកគីម លោកហាក់ដូចជាមិនឆ្លើយនឹងសំណួររបស់ខ្ញុំនោះទេ។ ខ្ញុំចង់សួរថា នៅពេលដែលយើងមើលចម្លើយរបស់លោកនោះ គឺថាទាហានខ្មែរក្រហមអាចមានសិទ្ធិបាញ់សម្លាប់ប្រជាជនចោល។ ដូច្នេះ ខ្ញុំសួរលោកថា តើលោកបានឆ្លើយ ហើយវាត្រឹមត្រូវដែរឬទេដែលថា ខ្មែរក្រហមទាហានខ្មែរក្រហមមានសិទ្ធិបាញ់ប្រជាជនសម្លាប់ចោលដោយមិនមានទោសពៃរ៍នោះ?

**ឆ៖** បាទ សំណួរនេះ ខ្ញុំឆ្លើយពេលដែលមិនទាន់ចូលដល់ទីក្រុងភ្នំពេញទេ។ ដែលនៅខាងក្រៅ

ភ្នំពេញដែលមានខ្សែក្រវាត់ ពេលប្រយុទ្ធគ្នាខ្លាំងនោះ ពេលទាំងយប់ទាំងថ្ងៃហ្នឹង បើសិនជាមានមនុស្ស នៅក្នុងមុខសមរភូមិហ្នឹង ត្រូវតែបាញ់ ព្រោះធម្មតាតែមុខសមរភូមិគេត្រូវបាញ់ហើយ។ បាទ រីឯចូល ដល់ទីក្រុងភ្នំពេញ គឺវាអត់មានបទបញ្ជាថាឲ្យបាញ់ប្រជាជនក៏មិនថា អត់ឲ្យបាញ់ក៏មិនថា។ ដូច្នេះគឺថា ចូលដល់ទីក្រុងភ្នំពេញ នៅតាមផ្លូវមានប្រជាពលរដ្ឋខ្លះស្លាប់។ ហើយគ្រាប់ហ្នឹងក៏វាមានគ្រាប់បាញ់នឹង ដៃ គ្រាប់ផ្លោងក៏ចូលដល់ទីក្រុងភ្នំពេញដែរ។ អ៊ីចឹងការស្លាប់របស់គាត់មិនដឹងជាស្លាប់ដោយគ្រាប់ផ្លោង មិនដឹង ស្លាប់ដោយគ្រាប់ដែលគេបាញ់ផ្ទាល់មិនដឹង។ អ៊ីចឹងខ្ញុំគ្រាន់បានតែឃើញតែប៉ុណ្ណឹង។

[១៥:២៤:៤០]

**ស៖** ខ្ញុំចង់ឲ្យលោកនឹកឃើញឡើងវិញចំពោះបញ្ហាមួយចំនួន។ ឯកសារដដែល ខ្មែរ ERN គឺ 00054840, បារាំងគឺ 00403355, អង់គ្លេសគឺ 00633879។ សំណួរដែលសួរទៅលោកនោះ គឺថា "តើមានផែនការណាមួយប្រាប់លោកថា ប្រសិនឃើញវត្តកម្មេចចោលទៅ?" លោកឆ្លើយដូចតទៅ៖ "ក្នុងដំណាក់កាលដំបូងមិនមានផែនការឲ្យកម្ទេចវត្តនោះទេ។ អ្វីដែលយើងត្រូវធ្វើនៅពេលដែលចូលទៅ ដល់ភ្នំពេញនោះ គឺត្រូវការបង្ខំប្រជាជនចេញ រួមទាំងព្រះសង្ឃ។ ព្រះសង្ឃ និងប្រជាជន គឺចាត់ទុក ដូចគ្នា ត្រូវតែដេញចេញ។ និយាយជាទូទៅ គឺថាយើងមានសិទ្ធិបាញ់អ្នកទាំងអស់នោះ និងបង្ខំអ្នកទាំង អស់នោះឲ្យចាកចេញ"។ តើត្រឹមត្រូវដែរឬទេចំណុចនេះលោក គង់ គីម នៅពេលដែលលោកនិយាយថា និយាយជាទូទៅ គឺថាយើងមានសិទ្ធិក្នុងការបាញ់ និងបង្ខំអ្នកទាំងអស់នោះឲ្យចាកចេញ។ ដូច្នេះ ខ្ញុំចង់ សួរថាតើលោកនោះ ក្រុមរបស់លោកមានសិទ្ធិក្នុងការបង្ខំ និងបាញ់ប្រជាជនដែរឬទេ?

**ឆ៖** បាទ ជាខ្ញុំមើលឃើញជាក់ស្តែង ពេលដែលជម្លៀសប្រជាពលរដ្ឋហ្នឹង បើសិនជាអត់មាន ទាហានបាញ់ត បើមានតែប្រជាពលរដ្ឋសុទ្ធ គឺថាទាហានខាងក្រៅពុំដែលបាញ់ប្រជាជនដែលអត់មាន អាវុធទេ។ បាទ ប្រជាជនដែលស្លាប់ដោយសារគ្រាប់ហ្នឹង ដោយសារមានការប្រយុទ្ធគ្នាបាទ។ ដល់ អ៊ីចឹងការបាញ់ទៅ វាប៉ះពាល់ទៅដល់ប្រជាពលរដ្ឋ។ ហើយចំពោះព្រះសង្ឃ គឺជម្លៀសដូចប្រជាពលរដ្ឋ ជម្លៀសចេញ ប៉ុន្តែរឿងកម្ទេចវត្ត អត់មានកម្ទេចទេ។ វត្តនៅនឹងឡូត៍ដែលខ្ញុំទទួលខុសត្រូវ គឺថាវត្តនៅ ដដែល។

[១៥:២៦:៥៦]

**ស៖** នៅក្នុងអត្ថបទដែលយើងមើលអម្បាញ់មិញនេះ គឺខ្ញុំសូមដកស្រង់សម្តីដូចតទៅ៖ "យើង ប្រាប់ពួកប្រជាជនថា មេបញ្ជាការបញ្ជាឲ្យពួកគេចេញ ប្រសិនតវ៉ា នឹងបាញ់ចោល"។ តើលោកបាន

ប្រាប់ប្រជាជនស៊ីវិលឲ្យចាកចេញដែរឬទេ បានន័យថា តើលោកមានប្រាប់ថាឲ្យចាកចេញ បើសិនចេះតវ៉ានឹងបាញ់សម្លាប់ចោល? តើលោកមានប្រាប់ប្រជាជនដូច្នេះដែរឬទេ?

**ឆ៖** បាទ ពេលនុ៎ង ដូចខ្ញុំបានឆ្លើយថា កងខ្ញុំនេះគ្រាន់តែឈរទៅតាមគោលដៅ ហើយមានភារកិច្ច កងពិសេសមួយទៀតដែលគេជម្លៀសហើយ គេមានទីក្រុតាមដានឲ្យប្រជាពលរដ្ឋចុះពីលើផ្ទះមកក្រោម ហើយគេនឹងជម្លៀសបញ្ជូន។ នេះជាជំហានមួយដែលមានកងពិសេស។ ក្រោយមក បានគេប្រគល់ទៅតាមគោលដៅក្រោមអនុសេនាតូច ដែលប្រជាជនដែលសេសសល់ គេហៅថាប្រជាជនដែលរឹងនោះ ប្រជាជនដែលរួមចំនួនជាមួយទាហានដែលនៅសេសសល់ហ្នឹង ដែលមានតដែតអីហ្នឹង។ ក្រោយមកមានបញ្ហាអីចឹងមែន។ មានបទបញ្ជាថា ប្រសិនបើនៅ គឺចូលដាក់ដំណាក់កាលក្រោយ គឺដំណាក់កាលគេបាញ់បាទ។ តែជំហានមុនដំបូងអត់មានការបាញ់ទេ។ បាទ អត់មានបាញ់ដោយសារអត់តគ្នា។ បើសិនជាតបាញ់ បើសិនជាប្រជាជនស្លូតត្រង់ទាំងអស់ គឺគេផ្សព្វផ្សាយទៅតាមមីក្រូ បាទ ឲ្យចុះ ឲ្យចុះៗក្រោម គេនឹងបញ្ជូនចេញ។

[១៥:២៨:២៨]

**ស៖** សូមអរគុណដែលលោកបានបញ្ជាក់បញ្ជូនជូនយើងខ្ញុំ។ នៅពេលនេះ គឺយើងសុំឲ្យលោកពិនិត្យ និងមើលទៅលើរចនាសម្ព័ន្ធរបស់កងក្រុមរបស់លោក ឯកសារ ឌី.ស៊ី.ខេម ដដែល មជ្ឈមណ្ឌលឯកសារដដែល គឺខ្មែរលេខ 005454836 (ស៊ីក), បារាំង គឺ00403352 ហើយអង់គ្លេស 00638876។ គឺមានចំណុចមួយដែលខ្ញុំសុំឲ្យលោកពិចារណា និងពិនិត្យមើល។ “សំណួរ៖ តើទៅទិសណាមួយដែរ? ទៅទិសគ្រប់ទាំងអស់ គឺវាអាស្រ័យទៅលើយើង ដែលបញ្ជូនពួកគេបញ្ជូនពួកគេទៅតាមទិសណាក៏បានដែរ។ តួនាទីរបស់ខ្ញុំត្រូវតែពិនិត្យមើលតែប៉ុណ្ណោះ”។ ខាងក្រោមនេះ គឺលោកបានឆ្លើយទៀតថា “តើលោកមានអមដំណើរពួកគេដែរឬទេ? ខ្ញុំអត់ទេ។ មានក្រុមផ្សេងទៀតនៅតាមផ្លូវដែលប្រាប់ឲ្យប្រជាជនទៅតាមទិសណា ទិសណី។ ខ្ញុំគ្រាន់តែទៅមើលប៉ុណ្ណោះ។ តួនាទីរបស់ខ្ញុំ គឺដំបូងគឺថាទៅតាមផ្ទះ ហើយដេញប្រជាជនចេញតែប៉ុណ្ណោះ។ សំណួរ៖ តើលោកជាអ្នកដេញប្រជាជនចេញ ឬក៏យ៉ាងម៉េច? បាទ គឺខ្ញុំដេញប្រជាជនចេញ ហើយក្រុមផ្សេងទៀតជាអ្នកបញ្ជូនប្រជាជនទៅតាមទិសណាទិសណីស្រេចតែពួកគេ”។

ដូច្នេះដើម្បីឲ្យយើងយល់ច្បាស់ទាំងអស់គ្នា តើលោក ក្រុមរបស់លោកនេះមានតួនាទីត្រឹមតែដេញប្រជាជនឲ្យចេញពីផ្ទះ ហើយឲ្យដើរទៅតាមផ្លូវ ហើយមានក្រុមផ្សេងទៀតជាអ្នកឲ្យប្រជាជនទៅ

តាមទិសណាទិសណីដែលគេចង់ឲ្យទៅ តើអ៊ីចឹងដែរឬទេ?

**ឆៈ** បាទ កាលដែលដេញប្រជាពលរដ្ឋនេះ មិនចេះដើរដេញពេញទីក្រុងភ្នំពេញទេ គឺថាយើងមានតួនាទីដេញតែគោលដៅយើង គេឲ្យយើង ឧទាហរណ៍ចំណុចណា គឺយើងដេញតែកន្លែងយើងឈរជើងតែប៉ុណ្ណឹងទេ ព្រោះយើងមិនអ្នកប្រមូលទេ គឺថាដេញដើម្បីយកទីតាំងយើងហ្នឹងឈរជើង កុំឲ្យមានប្រជាពលរដ្ឋ អ៊ីចឹងយើងទទួលខុសត្រូវតែប៉ុណ្ណឹងទេ។ មែនថាក្រុមខ្ញុំហ្នឹង វាអាចតួនាទីវែងឆ្ងាយ អត់ទេ គេឲ្យចំណុចណានៅតែចំណុចហ្នឹង។ ហើយជម្លៀសដែលចំណុចដែលឈរជើងតែប៉ុណ្ណឹង។

[១៥:៣១:១៥]

**សៈ** សូមអរគុណចំពោះចម្លើយដ៏ច្បាស់លាស់នេះ។ បាទ ខ្ញុំមានសំណួរពីរបីទៀត ទាក់ទងទៅនឹងអំឡុងពេលនេះ។ មកពីខាងដើម យើងបាននិយាយគ្នាអំពីការប៉ះទង្គិចគ្នាជាមួយកម្លាំងទាហានរបស់របបសាធារណរដ្ឋ ហើយនិងការប្រព្រឹត្តទៅលើទាហានសាធារណរដ្ឋ។ នៅក្នុងកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺមានដូចតទៅ, ERN ជាភាសាខ្មែរ 00054839, ជាភាសាបារាំង 00403354 ហើយ ERN ជាភាសាអង់គ្លេស 00633879 (ស៊ីក)។ សំណួរថា "តើមានអ្វីកើតឡើងទៅនឹងព្រះសង្ឃដែលគង់នៅក្នុងវត្តនោះ?" ចម្លើយគឺថា "ព្រះសង្ឃគ្រប់អង្គ គឺត្រូវតែចាកចេញពីវត្តរួមទាំងទាហាននៃរបបចាស់ផង។ ចំពោះទាហាន គេ -- បើគេដោះឯកសណ្ឋានយោធាទាហានចេញ គេអាចនឹងអាចរស់បានយូរ ហើយបើថានៅពាក់ឯកសណ្ឋានគឺថាអាចនឹងបាញ់សម្លាប់"។ តើថាតើនេះជាចម្លើយរបស់លោកត្រឹមត្រូវដែរឬទេ ដែលថាទាហានរបបសាធារណរដ្ឋដែលនៅតែពាក់ឯកសណ្ឋានគឺថានឹងបាញ់ចោលតែម្តង?

**ឆៈ** បាទ ពេលដែលចូលដល់ភ្នំពេញនេះ ទាហានដែលជម្លៀសហើយ បើទាហានដែលទៅជាមួយប្រជាពលរដ្ឋដែលអត់មានការតដៃ អត់មានការបាញ់ អាហ្នឹងទ័ពខាងក្រៅក៏មិនបាញ់ដែរ។ ប៉ុន្តែកន្លងទៅដែលមានបាញ់នេះដោយសារទាហានដែលគេឲ្យដាក់អាវុធហើយ ប៉ុន្តែទាហានជាក្រុម ជាឯកជនហ្នឹងដោយក្រុមតូចៗមិនអាចដាក់ទាំងអស់ទេ គឺមានខ្លះនៅប្រយុទ្ធគ្នាទៅតាមប៉ែកៗអ៊ីចឹង។ អ៊ីចឹងពេលហ្នឹងហើយ ដែលធ្វើឲ្យទ័ពខាងក្រៅ និងទ័ព -- ទាហានហ្នឹងវាអាចបាញ់គ្នាដោយអាវុធទល់នឹងអាវុធបាទ។

[១៥:៣៣:៤៦]

**សៈ** សូមអរគុណលោក។ នៅក្នុងកិច្ចសម្ភាសន៍មួយ ដែលលោកឆ្លើយជូនសហចៅក្រមស៊ើប

អង្កេត លោកនិយាយអំពីការកម្ទេចគហារមួយ -- វិហារកាតូលិកមួយនៅទីក្រុងភ្នំពេញ ហើយនៅក្នុងឯកសាររបស់ ឌី.ស៊ី.ខេម ក៏ដូច្នេះដែរ។ ដោយសារតែយើងខ្ញុំមានពេលវេលាតិច ខ្ញុំមិនចង់និយាយឲ្យលម្អិតអំពីការកម្ទេចវិហារកាតូលិកនេះទេ។ បាទ នេះគឺនៅឯកសារ មជ្ឈមណ្ឌលឯកសារកម្ពុជាគឺនៅត្រង់លេខ ERN 000548--

**អ្នកបកប្រែ៖**

ហើយសុំអធ្យាស្រ័យលោកប្រធាន សូមឲ្យលោកសហព្រះរាជអាជ្ញាគាត់អាន ERN ម្តងទៀតតាមអត់ទាន់។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាអានលេខ ERN ឯកសារសាជាថ្មីម្តងទៀត អ្នកបកប្រែបកមិនទាន់ទេ។

[១៥:៣៤:៥៤]

**សួរដោយលោក អាប់ឌុលឡាក់ ចារីក៖**

**ស៖** បាទ ខ្មែរ ERN 0054856, បារាំង 00403369, ERN ជាភាសាអង់គ្លេស 0063892។ បាទ ខ្ញុំមិនចង់និយាយអំពីការកម្ទេចវិហារនេះឲ្យលម្អិតណាស់ណានោះទេ។ គេបានសួរលោកដូចខាងក្រោមនេះ “ថាតើធ្វើម៉េចបានជា លោកដឹងដូចជា គ្រឿងគ្រាប់រំសេវ ក៏ដូចសម្ភារៈដទៃទៀត ត្រូវតែបញ្ជូនទៅឲ្យមជ្ឈិម? ហើយម៉េចបានដឹងថា វាជារបស់របរដែលជាកម្មសិទ្ធិរបស់មជ្ឈិម។ ដូច្នេះ គេយកសម្ភារៈទាំងអស់នេះ ដូចជា ត្រាក់ទ័រ ដូចជា ប៊ុលដូស័រ។ កងពលនោះគឺថា អត់មានឡានបែបហ្នឹងទេតាមកងពលហ្នឹងគឺ អត់មានឡានបែបនេះទេ មានតែម៉ូតូ។ វរសេនាធំ មានតែម៉ូតូជិះប៉ុណ្ណឹង ហើយអ្នកតូចហ្នឹង”។ ដូច្នេះ សំណួររបស់ខ្ញុំ គឺនៅពេលដែលនិយាយថា ឡានធំៗនោះគឺថាជារបស់មជ្ឈិម។ តើកាលណានិយាយពាក្យថា “មជ្ឈិម” នោះលោកសំដៅទៅលើស្ថាប័នត្រឹមកម្រិតណា?

[១៥:៣៦:៣០]

**លោក គង់ គឹម៖**

**ឆ៖** បាទ កាលដែលយើងជម្លៀសប្រជាជនអស់រលីងហើយ គឺថាទីក្រុងភ្នំពេញមានការស្ងប់ស្ងាត់ហើយ មានផែនការដាក់បញ្ជាឲ្យកម្ទេច គេហៅថា “អង្គរកាតូលិក”។ អ៊ីចឹង ខ្ញុំទទួលបញ្ជាពីអនុសេនាធំ ហើយបានមកចុចកម្ទេច នៅក្នុងក្រុមខ្ញុំហ្នឹង ចុច គ្រាន់ជាតួនាទីអ្នកចុច។ បាទ ដាក់ តេ.អ៊ិន.តេ

ចុចឲ្យបាក់រលំរលមក ហើយក្នុងហ្នឹងឡាន ហៅថា -- ខ្ញុំនេះជាកងទ័ពមជ្ឈិមដែរ ព្រោះវាចូលក្នុងទីក្រុងភ្នំពេញវាលែងភូមិភាគហើយ ច្របាច់ចូលជាមជ្ឈិម។ អ៊ីចឹងនោះ ជាឡានសេនាធិការ បានន័យថាឡានមិនមែនឡានកងពល ព្រោះកងពលនៅចំណុះខ្ញុំហ្នឹង មិនដែលឃើញមានឡានទេ។ អ៊ីចឹង ខ្ញុំបាទពេលដែលកម្ទេចអស់ ឃើញមានឡានមកទាំងខ្សែៗដឹក ដឹកចេញទៅ។ តែត្រង់ដឹកទៅណាក៏ខ្ញុំមិនដឹងហើយផែនការដែលកម្ទេច វាមានមូលហេតុក៏ខ្ញុំអត់ដឹង ខ្ញុំដឹងតែបទបញ្ជាថាឲ្យកម្ទេច គឺគ្រាន់តែចុចកម្ទេចតែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ នៅក្នុងចំណុចដដែលនេះ គឺថាលោកនិយាយថា "វាស៊ីរយៈពេលអស់ប្រហែលជា៣ខែ ដើម្បីកម្ទេចវិហារហ្នឹងចោល"។ តើនេះគឺជាចម្លើយរបស់លោកត្រឹមត្រូវទេ ដែលថាក្នុងការកម្ទេចវិហារនោះគឺថា ត្រូវប្រើពេលអស់រយៈពេលដល់ទៅ៣ខែឯណោះ។ អ៊ីចឹងមែនទេ?

[១៥:៣៨:១៥]

**ឆ៖** បាទ ការកម្ទេចនេះ គឺជាការពិតមែន ព្រោះកម្ទេចនេះមិនមែនយកម្លាំងច្រើនទេ គឺថាយកតែក្រុមមួយក្រុម សម្រាប់តែចុច ហើយការចុចនេះ មិនមែនចុចរាល់ថ្ងៃទេបាទ។ ចុចទៅតាមផែនការដែលគេឲ្យចុច ថ្ងៃណាដែលគេឲ្យចុច គឺថាចុចជាបន្តបន្ទាប់រហូតដល់អស់។ អ៊ីចឹងពេលវេលាគឺមិនមែនកំណត់ថា ចុចរហូតទេ មានពេលចុច ពេលអត់។ អ៊ីចឹងបានជារយៈពេលវាវែង។ ប៉ុន្តែផែនការហ្នឹងចុចទាល់តែអស់បាទ។

**ស៖** សូមអរគុណ។ លោកដឹងទេថា អ្នកណាជាអ្នកដាក់បញ្ជាទៅដល់កងពលលោក គឺថាកងពលលោកទទួលបញ្ជាពីមជ្ឈិម លោកដឹងថា តើអ្នកណាដែលមានសិទ្ធិអំណាចនៅពីខាងលើកងពលរបស់លោកហ្នឹង?

**ឆ៖** បាទ ពេលដែលខ្ញុំទទួលបញ្ជាចុច គឺទទួលបញ្ជាពីអនុសេនាធំ ប៉ុន្តែដល់ពេលមានសកម្មភាពពេលដែលចុចហ្នឹងឃើញមាន វរសេនាធំ ដែលមានឈ្មោះ សុង, ឈ្មោះ ចិត្ត អាចចូលទៅត្រួតពិនិត្យពីលើ។ ហើយមានមនុស្សប្លែកៗជាងនោះទៅទៀត ដោយយើងខ្ញុំមិនបានស្គាល់។ គ្រាន់តែឃើញគេជួបជុំគ្នានៅក្បែរៗនោះ ប៉ុន្តែមិនដឹងថាជាតួនាទីប៉ុនណា គឺខ្ញុំអត់ដឹងដែរ។

[១៥:៤០:១០]

**ស៖** សូមអរគុណ។ ដោយសារតែខ្ញុំមានពេលវេលាខ្លី សូមបន្តចូលទៅទីតាំងមួយផ្សេងទៀតដែលលោកបានធ្វើការនៅទីនោះ ដើម្បីឲ្យលោកបង្ហាញជូនអំពីរចនាសម្ព័ន្ធខ្សែចង្វាក់បញ្ជានៅក្នុងកងពល

របស់លោក។ នៅក្នុងចម្លើយដែលលោកឆ្លើយ ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត D166/74 លោកនិយាយអំពីគុកមួយ ដែលគេបានចាត់តាំងឲ្យលោកធ្វើការជាឆ្មាំគុក។ ផ្នែកនេះគឺថានៅត្រង់ ERN ជាភាសាខ្មែរ 00270165, ជាភាសាបារាំង 00486098, អង់គ្លេស 00278683។ បាទ លោកនិយាយថា "នៅចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ ខ្ញុំត្រូវចាត់តាំងឲ្យយាមគុកមួយនៅខាងកើតវត្តភ្នំ។ គុក នោះជាគុកកងពល។ គ្នាខ្ញុំ មានគ្នាចំនួន៣២នាក់ ដើម្បីយាមគុកនោះ។ ចំពោះកិច្ចការសួរចម្លើយ អ្នកផ្សេងជាអ្នកធ្វើ។ អ្នកទោសទាំងនោះ គឺមានគណៈតំបន់ គណៈស្រុកជាដើម"។ បាទ ខ្ញុំសូមសួរសំណួរជាក់លាក់មួយ ដើម្បីផ្ទៀងផ្ទាត់ទៅនឹងចម្លើយរបស់លោក។ តើគុករបស់កងពលលេខ៣១០ ហ្នឹង គឺត្រូវបានបង្កើតនៅពេលណាដែរ?

[១៥:៤២:១០]

**ឆ៖** បាទ គុកនេះ គឺដែលខ្ញុំទទួលបទបញ្ជា ខ្ញុំជាអ្នកទទួលបទបញ្ជាពីអនុសេនាធំ អនុសេនាតូច អ៊ីចឹង ឲ្យខ្ញុំជាអ្នកទៅការពារគុកនេះ។ អ៊ីចឹង ពេលដែលខ្ញុំចូលទៅការពារនៅក្នុងឆ្នាំ ចុងឆ្នាំ៧៥ និងដើមឆ្នាំ៧៦។ អ៊ីចឹង ភារកិច្ចមួយអនុសេនាតូចនេះ គឺខ្ញុំដឹកនាំតែមួយក្រុមទេ ហើយក្រុមគេផ្សេងៗ មានមេក្រុមគេដោយឡែក។ អ៊ីចឹង ក្នុងនោះមានប្រធានអនុសេនាតូចមួយដែលជាអ្នកក្ដាប់រួមក្នុងបីក្រុម។ អ៊ីចឹង ភារកិច្ចគ្រាន់តែការពារទេ។ ប៉ុន្តែមុនដំបូងចូលទៅដល់កន្លែងគុកហ្នឹង ឃើញថាគុកហ្នឹងមិនមែនគុកទើបតែធ្វើទេ គឺគុកពីបរមបូរាណពីដើមមក។ មានកន្លែងគេ ក្នុងដីក៏មាន លើក៏មាន កន្លែងគុកស្រេច។ អ៊ីចឹង ពេលដែលខ្ញុំចូលទៅការពារមុនដំបូង គឺថារៀបចំនៅទីនុំង ការពារទីកន្លែងគុក។ តែក្រោយមក ឃើញមានពេលយប់ គឺនាំមនុស្សមក ដោយចងមុខដាក់ឡាន ហើយមកដល់ក្នុងនុំង គឺគេអ្នកនាំហ្នឹង គេស្រាយមុខស្រាយអី ចូលក្នុងគុកទៅ គេដាក់តាមថ្នាក់ គុកហ្នឹងមានថ្នាក់លើ មានថ្នាក់ក្រោម មានក្នុងដី។

[១៥:៤៣:២៤]

អ៊ីចឹង ភារកិច្ចខ្ញុំ គ្រាន់តែការពារ ប៉ុនដល់ការសួរទៅថា ដែលយកមកហ្នឹង គឺមានខាងគណៈតំបន់ គណៈស្រុក។ ដោយឡែក ក្នុងកងទ័ពដែលនៅខាងក្នុង អត់មានការចាប់នៅឡើយ។

**ស៖** សូមអរគុណ ចំពោះចម្លើយល្អិតល្អន់នេះ។ ខ្ញុំមិនចង់សួរទៅសំណួរមុនៗទេ បើសិនជាណាលោកដឹង ឆ្លើយថាដឹង បើមិនដឹង ឆ្លើយថាមិនដឹងតែម្ដងទៅ។ ថាតើគុកហ្នឹង បង្កើតនៅពេលណាដែរ? ភ្លាមៗ ក្រោយពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ឬក៏យ៉ាងម៉េច គុកដែលត្រូវបានចាត់ចែងគ្រប់គ្រង ដោយកងពល៣១០ហ្នឹង។ ពីព្រោះខ្ញុំដឹងថា អគារនោះ ត្រូវបានគេយកទៅប្រើប្រាស់ជា

គុក។ សំណួរខ្ញុំសួរថា តើកងពល៣១០ហ្នឹង ចាប់ផ្តើមប្រើប្រាស់អគារមួយដែលគេប្រើជាគុកហ្នឹង ពីពេលណាមកដែរ?

**ឆ៖** បាទ ដូចខ្ញុំបានឆ្លើយថា ចុងឆ្នាំ៧៥ និងដើមឆ្នាំ៧៦ បាទ ដែលប្រើប្រាស់គុកហ្នឹង។

[១៥:៤៤:៣៧]

**ស៖** សូមអរគុណលោក។ តើលោកដឹង ហើយប្រាប់ថាដឹង ប្រាប់ថាដឹង បើមិនដឹង ប្រាប់ថាមិនដឹង។ គឺអ្នកណាជាអ្នកបញ្ជាឲ្យយកទីតាំងហ្នឹងប្រើប្រាស់ធ្វើជាគុក?

**ឆ៖** បាទ អារឿងអ្នកបញ្ជាឲ្យបង្កើតទីតាំង យកទីតាំងហ្នឹង បង្កើតគុក ខ្ញុំអត់ដឹង។ ខ្ញុំដឹងតែត្រឹមបទបញ្ជាឲ្យខ្ញុំទៅយាមហ្នឹង។

**ស៖** សូមអរគុណ។ តើអ្នកណាជាអ្នកបញ្ជាលោក ឲ្យលោកទៅយាមនៅខាងក្នុងនៃគុកហ្នឹង? តើជាៗមេដឹកនាំមកពីកងពល៣១០ ហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ អ្នកដែលបញ្ជាខ្ញុំផ្ទាល់ គឺអនុសេនាធំឈ្មោះ រ៉េន នៅក្នុងវរសេនាធំខ្ញុំហ្នឹង គឺវរសេនាធំឈ្មោះ សុង បាទ ហើយបញ្ជាមកវរសេនាតូចឈ្មោះ យឹម ហើយខ្ញុំទទួលបញ្ជាពីឈ្មោះ រ៉េន ដែលជាអនុសេនាធំចាត់ចែងកម្លាំងទៅការពារកន្លែងគុកហ្នឹង។

**ស៖** សូមអរគុណ។ ឥឡូវប្រសិនបើយើងមើលទៅអ្នកទោសវិញម្តង។ ខ្ញុំ -- លោកថាអ្នកទោសហ្នឹងគឺមានគណៈតំបន់ និងគណៈស្រុក។ ហើយចម្លើយខាងក្រោមមកទៀត លោកបានឆ្លើយដូចតទៅ ERN ភាសាខ្មែរ 00270167 សូមកែប្រែគឺ 00270166, ERN ជាភាសាបារាំង 00486098, ERN ជាភាសាអង់គ្លេស 00278684។ លោកឆ្លើយដូចខាងក្រោម៖ “ក្រោយមក មេបញ្ជាការរបស់ខ្ញុំផ្ទាល់គឺ អឿន ជាមេបញ្ជាការកងពលរបស់ខ្ញុំត្រូវបានចាប់ខ្លួន គឺខ្ញុំឃើញគេដាក់ច្រវាក់គាត់ ហើយក្រៅពីគាត់នេះក៏មានមេបញ្ជាការវរសេនាធំ សុង ហើយនិង ហើយក្នុងនោះ យឹម ជាប្រធានវរសេនាតូចក៏ដូចជា ផូ ប្រធានអនុសេនាធំក៏ត្រូវបានចាប់ខ្លួនដាក់ក្នុងគុកនោះដែរ។ តើលោកអាចជម្រាបបានទេថា ហេតុអីបានជាមេបញ្ជាការកងពលឈ្មោះ អឿង ហ្នឹងត្រូវបានចាប់ខ្លួន?

[១៥:៤៧:៤១]

**ឆ៖** បាទ ភារកិច្ចខ្ញុំគ្រាន់តែយាមគុក ប៉ុន្តែក្រោយមក ខ្ញុំពិនិត្យឃើញថា នៅក្នុងដើមឆ្នាំ១៩៧៦នេះ ឃើញចាប់នូវមេៗអង្គភាពចាប់ពីកងពលវរសេនាធំ វរសេនាតូច និងអនុសេនាធំ។ អ៊ីចឹងយើងខ្ញុំស្គាល់ច្បាស់ហើយ គេចាប់យកទៅដាក់ក្នុងគុកនុំងដែរ។ អស់ មានតែប៉ុណ្ណឹង។ ហើយក្រោយមក ដល់

ពេលគេចាប់មេៗខ្ញុំហ្នឹង គេក៏ឈប់ឲ្យខ្ញុំយាមហ្នឹង គេបញ្ជូនខ្ញុំចេញពីនុំង។

**ស៖** សូមបន្តទៀត ដោយសារតែពេលវេលាខ្លី។ នៅក្នុងចម្លើយរបស់លោកដែលត្រូវបានខាងមជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាស។ សូមមើលផ្នែកពាក់ព័ន្ធ ERN ជាភាសាខ្មែរ 00054850, បារាំង 00403363, អង់គ្លេស 00633887។ លោកបាននិយាយអំពីការសួរចម្លើយអ្នកទោស។ ខ្ញុំចង់ដឹងអំពីវចនាសម្ព័ន្ធនៃការបញ្ជា។ "សំណួរ៖ ថាតើអ្នកដែលទទួលខុសត្រូវខាងសួរចម្លើយចាប់ខ្លួននោះ គឺមកពីកងពល៣១០ដែរ ឬក៏យ៉ាងណា ឬក៏មកអង្គភាពផ្សេង? ចម្លើយ៖ មិនមែនទេ ពួកគេមិនមែនមកពីកងពល៣១០ទេ គឺថាគេហៅថាមកពីអគ្គសេនាធិការ ឬកងទ័ពមជ្ឈិម"។ លោកអាចជម្រាបជូនតុលាការបានទេ តើលោកមានន័យថាម៉េច កាលណាលោកនិយាយថា គឺមកពីខាងអគ្គសេនាធិការ ឬក៏មកពីមជ្ឈិម? តើលោកសំដៅថាអ្នកណា ឬក៏អង្គភាពណាដែរ?

[១៥:៤៩:៤៩]

**ឆ៖** បាទ ភារកិច្ចខ្ញុំអ្នកយាមនេះ ដែលខ្ញុំពិនិត្យឃើញបាន អ្នកដែលសួរចម្លើយ អ្នកដែលធ្វើការងារផ្ទាល់ខាងសួរចម្លើយ ខាងនាំខ្លួននេះ មិនមែនជាអ្នកនៅក្នុងកងពលរបស់យើងខ្ញុំទេ។ ដោយឡែកសម័យនុំងគេមាន គេហៅថា សេនាធិការឲ្យកងពលនោះ បាទ ជាខ្ពស់ជាងកងពលទៀត។ អ៊ីចឹងមនុស្សនុំងជាមនុស្សសំខាន់របស់គេ គេឲ្យគ្រប់គ្រងការសួរចម្លើយ ហើយភារកិច្ចខ្ញុំហ្នឹងគ្រាន់តែបានមើលឃើញ ហើយនិងឮសួរ ហើយនិងឃើញនឹងភ្នែកនៅពេលដែលគេធ្វើទារុណកម្ម។

**ស៖** បាទ ចូលទៅក្នុងចម្លើយនេះ ដដែលនេះ គឺថានិយាយអំពីខាងអគ្គសេនាធិការឲ្យបានលម្អិតបន្តិច។ ERN ជាភាសាខ្មែរ 0009844, ERN ជាភាសាបារាំង 00403358, ERN ជាភាសាអង់គ្លេស 00633882។ លោកបាននិយាយអំពីការប្រជុំមួយហៅថា ដែលធ្វើឡើងក្រោយពីការចាប់មេៗនៅកងពល៣១០ មេៗនិងកម្មាភិបាលកងពល៣១០។

[១៥:៥១:៣០]

"សំណួរ៖ នៅពេលដែលគេមានការប្រជុំហ្នឹង តើអ្នកណាដែលអ្នកប្រាប់លោកថាមេបញ្ជាការរបស់លោកជាអ្នក ជាពួកក្បត់? ខ្ញុំអត់ដឹងទេ គឺគេបើកអង្គប្រជុំហើយប្រាប់ខ្ញុំថា មេកងពលរបស់ខ្ញុំត្រូវចាប់ខ្លួនដោយសារមេកងពលជាអ្នកក្បត់។ ដូច្នេះ គេផ្លាស់ប្តូរមេបញ្ជាការមកឲ្យគ្រប់គ្រងយើង។ សំណួរសួរថា៖ អ្នកមកពីអង្គភាពណាដែលបើកអង្គប្រជុំហ្នឹង? គឺគេមកពីខាងមជ្ឈិម ហៅថា សេនាធិការមជ្ឈិម"។ ពាក្យថា "សេនាធិការ" នេះ គឺជាសេនាធិការដូចគ្នាដែលថា លោកសំដៅទៅលើអ្នកដែលទៅ

ទទួលចាប់ខ្លួន បញ្ជូនខ្លួនហ្នឹងឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ពេលដែលគេចាប់មេ ចាប់ពីអនុសេនាធំឡើងទៅ ហើយអ្នកនៅសល់ត្រឹមអនុសេនាតូចមកក្រោម ហើយយុវជន។ អ៊ីចឹងគេបាននៅក្នុងឆ្នាំ១៩៧៦ហ្នឹង ដើមឆ្នាំ គេយកពួកខ្ញុំទាំងអស់យកទៅដាក់ព្រលានកំពង់ឆ្នាំង។ បាទ យកទៅធ្វើព្រលាន ព្រោះអង្គាល់នុំងមិនទាន់មានព្រលានទេ គឺថាយកទៅឲ្យធ្វើ។ ប៉ុន្តែទៅដល់ទីនោះ គេបានប្រជុំ គឺថាមានឈ្មោះ ផន បាទ អ៊ីចឹងក្នុងនុំងគេកំណត់ថា ខាងនិរតីហៅថា សេនាធិការរបស់ -- ហៅថាមជ្ឈិមបក្សគេហ្នឹង គឺមានយកនិរតីជាសេនាធិការឲ្យមជ្ឈិមបក្ស។ បានន័យថា ជាដៃស្ដាំរបស់មជ្ឈិម មជ្ឈិមបក្សនុំង។ អ៊ីចឹង គេយកខាងទ័ពនិរតីហ្នឹង យកមកគ្រប់គ្រងនៅកងកម្លាំងរបស់ខ្ញុំ ខ្ញុំនេះសុទ្ធតែយុវជន។ អ៊ីចឹងដល់ពេល មុននឹងគេផ្លាស់ប្ដូរសមាសភាពគឺថា ចាប់ពីមេក្រុមអនុសេនាតូចអី គេរំសាយអស់ហើយពួកខ្ញុំ ឲ្យនៅយុទ្ធជនទាំងអស់។ អ៊ីចឹងគេចាត់តាំងពីក្រុមពីអនុសេនាតូច អនុសេនាធំឡើងទៅ គឺគេយកពីនុំងមកគ្រប់គ្រង ហើយគេប្រជុំផ្សព្វផ្សាយថា មេៗខ្ញុំកន្លងទៅដែលគេចាប់ដោយសារក្បត់។ បាទ អាហ្នឹងជាការអប់រំរបស់គេ។

[១៥:៥៣:៤៥]

**ស៖** ខ្ញុំចង់ស្វែងយល់ឲ្យបានច្បាស់លាស់បន្តិច គឺលោកបាននិយាយថា ខាងអគ្គសេនាធិការរបស់មជ្ឈិមដែលបានចាត់តាំងកម្មាភិបាលពីភូមិភាគនិរតីទៅឲ្យគ្រប់គ្រងកងពលរបស់លោក។ តើអ៊ីចឹងឬយ៉ាងម៉េច?

**ឆ៖** បាទ ពេលនុំងគឺ ពិតប្រាកដមែនថា កម្លាំងនៅក្នុងកងពលខ្ញុំអស់មេ។ មេៗដែលគេចាប់អស់ទៅ គេយកពីភូមិភាគនិរតីហ្នឹងជាសេនាធិការឲ្យមជ្ឈិមបក្សហ្នឹង គេយកទៅគ្រប់គ្រងខ្ញុំជាយុទ្ធជនទាំងអស់ហ្នឹង។

**ស៖** សូមអរគុណ។ បាទ សូមស្វែងយល់ឲ្យបានស៊ីជម្រៅបន្តិចទៅលើប្រធានបទដែលពាក់ព័ន្ធទៅនឹងការចាប់ខ្លួនមនុស្សជាច្រើននេះ។ ខ្ញុំសូមសួរកិច្ច -- ពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍របស់លោកមួយជាមួយនឹងខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ERN ជាភាសាខ្មែរ 0054 --

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន ខ្ញុំតាមអត់ទាន់អម្បាញ់មិញ សូមអានម្ដងទៀត ខ្ញុំតាមអត់ទាន់។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាឲ្យលេខ ERN សាជាថ្មីម្ដងទៀត។ អ្នកបកប្រែបកប្រែ

មិនទាន់ទេ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ERN គឺខ្មែរ 00054843, ERN ជាភាសាបារាំង 00403357 ដល់ 8, ERN ជាភាសាអង់គ្លេស 00633881។ ចម្លើយរបស់លោកវែងណាស់នៅត្រង់នេះ ខ្ញុំគ្រាន់តែអានផ្នែកដែលពាក់ព័ន្ធប៉ុណ្ណោះ។ សូមដកស្រង់ "ពួកគេបាននិយាយថា អ្នកដែលត្រូវបានចាប់ខ្លួននេះ គឺជាពួកក្បត់។ ពួកគេបានអប់រំខ្ញុំ អ្នកយាមគុកដែលថាមេរបស់ខ្ញុំត្រូវបានចាប់ខ្លួន ដោយសារគាត់បានបង្កើតខ្សែបណ្ដាញក្បត់ ហើយអ្នកដែលត្រូវចាប់ខ្លួននេះឆ្លើយដាក់អ្នកដទៃទៀត នាំឲ្យមានការចាប់ខ្លួនយ៉ាងច្រើនទៅដល់មេបញ្ជាការកងវរសេនាធំផងដែរ"។ សូមឲ្យលោកជួយពន្យល់បន្តិច តើលោកមានន័យថាម៉េចពាក់ព័ន្ធទៅនឹងថាការបង្កើតខ្សែបណ្ដាញនោះ លោកចង់មានន័យថាម៉េច?

[១៥:៥៦:៤៤]

**លោក គង់ គីម៖**

**ឆ៖** បាទ ពេលនុ៎ង ខ្ញុំក្ដាប់បានថា គេប្រាប់ថា នៅមេៗខ្ញុំសុទ្ធតែក្បត់ ហើយជាខ្មាំង។ ដូច្នេះ ខ្ញុំក៏កាលនុ៎ងមិនយល់ពីខ្មាំងរបៀបម៉េច ពីខ្មាំងព្រោះនៅក្នុងជួរកងទ័ពសុទ្ធតែមេៗដឹកនាំដូចគ្នា។ អ៊ីចឹងគេចាប់ជាបណ្ដាញ គឺថាឲ្យតែបណ្ដាញថ្នាក់ដឹកនាំ។ អ៊ីចឹងដូចខ្ញុំឆ្លើយថា ចាប់ពីអនុសេនាធំ អនុសេនាតូច វរសេនាធំ កងពលគេចាប់ទាំងអស់។ អ៊ីចឹងមិនដឹងជាចំណុចអីដែលគេចោទថាខ្មាំងគេចាប់។ តែអ្នកដែលនៅសល់ ចាប់ពីអនុសេនាតូច ហើយនិងមេក្រុម យុវជនគឺគេអត់ចាប់ទេ។ បាទ អ៊ីចឹងអ្នកដែលគេចាប់ គេចោទថាខ្មាំង។

**ស៖** សូមអរគុណ។ យើងនៅសល់តែពីរបីនាទីទៀតទេ។ ចូលទៅដល់កិច្ចសម្ភាសន៍របស់លោកជាមួយនឹងសហចៅក្រមស៊ើបអង្កេតវិញម្ដង។ ERN ជាភាសាខ្មែរ 00270166, បារាំង 00486098, អង់គ្លេស 00278683។ ខ្ញុំសូមអានឃ្លាមួយឃ្លាជូនលោកដែលពាក់ព័ន្ធទៅនឹងការឃុំខ្លួនមនុស្សនៅក្នុងគុក "អ្នកទោសទាំងនេះគឺមកនៅកន្លែងខ្ញុំតែពីរ ឬបីថ្ងៃប៉ុណ្ណោះ។ មុននឹងគេបញ្ជូនអ្នកទោសទាំងនោះទៅទួលស្លែង"។ ខ្ញុំសូមឲ្យលោកជម្រាបជូនតុលាការថា លោកធ្វើម៉េចបានជាលោកដឹងថាអ្នកទោសទាំងហ្នឹងត្រូវគេបញ្ជូនទៅទួលស្លែង?

[១៥:៥៨:៣៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក អៀង សារី!

**លោក អាង ឧត្តម៖**

សូមគោរពតុលាការ អង្គសវនាការទាំងមូល។ ខ្ញុំគួរតែបានលើកការជំទាស់នេះយូរមកហើយ ប៉ុន្តែខ្ញុំរង់ចាំមើលថា ក្រែងលោថា ព្រះរាជអាជ្ញាគាត់ឈរនៅលើជំហរត្រង់ថា សួរទីតាំងគុកអីតែប៉ុណ្ណឹង ប៉ុន្តែឃើញថាចូលទៅជ្រៅទៅៗ។ បើពិនិត្យទៅមើលដីកា E124 វាប្រាសចាកចេញពីសំណុំរឿងហ្នឹងបាត់ទៅហើយ។ សាក្សីពណ៌នាពីគុក។ ក្នុងដីកាយើងនិយាយពីមន្ទីរឃុំឃាំង។ តើគុក និងមន្ទីរឃុំឃាំងហ្នឹងខុសគ្នាយ៉ាងម៉េច? ពីព្រោះក្នុងដីកាយើងមិនអនុញ្ញាតឲ្យសួរពីមន្ទីរឃុំឃាំងទេ។ ហើយគុកនេះក៏ដូចជាមន្ទីរឃុំឃាំងទេ។ ដូច្នេះ ខ្ញុំសូមជំទាស់នឹងសំណួរបែបនេះ ព្រោះវាចាកប្រាសចាកពីទំហំនៃសំណុំរឿង០០២/០១ នេះហើយ។ បាទ សូមអរគុណ។

[១៥:៥៩:៤០]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមឆ្លើយតបដោយខ្លីទេ លោកប្រធាន។ មេធាវីការពារក្តី ខ្ញុំគិតថាគាត់យល់ខុសទាំងស្រុងតែម្តង។ បញ្ហាដែលត្រូវគ្របដណ្តប់គឺរួមព្រមទាំងរចនាសម្ព័ន្ធយោធា និងតួនាទីរបស់ទ័ពបដិវត្តន៍កម្ពុជាគឺកថាខណ្ឌ១៤៦ នៃដីកាដំណោះស្រាយ។ ខ្ញុំប្រុងប្រយ័ត្នណាស់ គឺថាខ្ញុំមិនចង់ចូលទៅកាន់ការសួរទៅលើទីតាំងឧក្រិដ្ឋកម្មឲ្យល្អិតល្អន់នោះទេ។ ខ្ញុំគ្រាន់តែសួរពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរបស់កងពលហ្នឹង ហើយនិងកម្មាភិបាលជាន់ខ្ពស់ ដែលទទួលរងនូវផលប៉ះពាល់ដោយការចាប់ខ្លួនអ៊ីចឹងជាដើម ដូចជាកងពល ៣១០ នេះជាដើម។ ដូច្នេះ ខ្ញុំយល់ឃើញថាមេធាវីការពារក្តីលើកឡើងមិនសមស្របទេ ពីព្រោះខ្ញុំសួរនិយាយតែអំពីការដកហូតមេកងពលនេះតែប៉ុណ្ណោះ។ សូមអរគុណ។

[១៦:០០:៤៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០២:១០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះកំណត់សម្គាល់ឃើញថា ជាសំណួរ ដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញាចុងក្រោយនេះ គឺវាជាសំណួរដែលមិនពាក់ព័ន្ធដោយផ្ទាល់ទៅលើអង្គហេតុ ដែលអង្គជំនុំជម្រះ

ត្រូវកំណត់ថាត្រូវធ្វើសវនាការនោះទេ ប៉ុន្តែនេះជាសំណួរចុងក្រោយហើយសម្រាប់រសៀលនេះ ហើយទំនងជាសំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញាដែរ។ ដូច្នេះ អង្គជំនុំជម្រះអនុញ្ញាតឲ្យសាក្សីឆ្លើយតបចុងក្រោយទៅនឹងសំណួរនេះ។

**លោក គង់ គីម៖**

**ឆ៖** បាទ សំណួរចុងក្រោយនេះ ខ្ញុំនឹងឆ្លើយបំភ្លឺថា មូលហេតុដែលបានខ្ញុំកើត អ៎! ដឹងថាបញ្ជូនទៅគុកទួលស្លែង ព្រោះក្នុងនោះពេលដែលគេបញ្ជូនទៅ យកកងការពារហ្នឹងដែលនៅជាមួយខ្ញុំ យកជូនទៅ។ បាទ ដល់ពេលត្រឡប់មកវិញ អានេះដល់សួរគ្នាទៅគេប្រាប់ថាអ៊ីចឹងបាទ។

**លោក អាប់ឌុលឡាក់ ថារីក៖**

បាទ លោកសាក្សីសូមអរគុណចំពោះចម្លើយរបស់លោកឆ្លើយជូនតុលាការ។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា សំណុំរឿងនេះគឺមានចម្លើយសារភាព អ៊ុម ហៅ អឿន គឺ IS5.89 គឺដែលគាត់គឺជាមេបញ្ជាការកងពល៣១០។ ដោយសារតែពេលវេលាដល់ពេលទៅហើយ គឺថាខ្ញុំសូមផ្អាកត្រឹមនេះសិន។

សូមអរគុណលោកប្រធាន។

[១៦:០៣:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ ដោយសារថាថ្ងៃស្អែក ខ្ញុំពេលព្រឹកខ្ញុំនឹងមិនមានវត្តមានទេ ក៏ប៉ុន្តែមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវសួរទៅលើសាក្សីរូបនេះ ខ្ញុំសូមជម្រាបលោកប្រធាន និងអង្គសវនាការថា លោកស្រីមេធាវី ជេត វណ្ណលី និងហើយលោកស្រីមេធាវី បេនី យេ ជាមេធាវីទទួលសិទ្ធិ។ បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ អរគុណលោកសាក្សី។ ឥឡូវហ្នឹងកិច្ចដំណើរការសវនាការនៅថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី២៥ ខែតុលា ឆ្នាំ២០១២ ហើយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី គង់ គីម

សូមភាគី និងសាធារណជនជ្រាប។

លោក គង់ គីម ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មរបស់លោកបន្តនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*